ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-May-2017, 14:10
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៣០៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

កញ្ញា ម៉ាដាលេណា ហ្គេហ្សី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| កញ្ញា សុង ឆវន្ត | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ស៊ីន សុវ៉ន | ខ្មែរ |
| លោក សែន សុផុន (2-TCPP-220) | ខ្មែរ |
| លោក ម៉ម សឿម ហៅ ហេង សាម្បូត (2-TCW-858) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក សែន សុផុន** (2-TCPP-220)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ទំព័រ ៨

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី........................................ទំព័រ ២៣

សួរដោយលោក គង់ សំអុន ផ្តើមពី ........................................ទំព័រ ២៩

**ការសួរសំណួរទៅសាក្សី៖ លោក ម៉ម សឿម ហៅ ហេង សាម្ចួត** (2-TCW-858)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ៣៦

សួរដោយលោក ត្រាវីស ហ្វារ ផ្តើមពី ........................................ទំព័រ ៤០

សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី ........................................ទំព័រ ៦២

សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្តើមពី ........................................ទំព័រ ៦៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-858។ ហើយក៏សូមជម្រាបភាគី និងសាធារណជនផងដែរថា កាលពីម្សិលមិញ បុគ្គលិកអង្គការ ធី.ភី.អូ –សេង ហ៊ុនតាំង– អង្គុយក្បែរអមជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីពង្រឹងស្មារតីរបស់គាត់ក្នុងអំឡុងពេលដែលគាត់ផ្តល់សក្ខីកម្ម ប៉ុន្តែដោយសារបុគ្គលិកអង្គការ ធី.ភី.អូ –សេង ហ៊ុនតាំង– មានធុរៈមិនអាចចូលនៅក្នុងកិច្ចដំណើរការសវនាការនៅព្រឹកនេះបាន អង្គជំនុំជម្រះបានរៀបចំចាត់លោក ជួង សុភារិទ្ធ ដែលជាបុគ្គលិកអង្គការ -- បុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ អង្គុយក្បែរនឹងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅ ព្រឹកនេះ។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក សែន សុផុន។ លោកមានវត្តមានរួចហើយ នៅបន្ទប់សវនាការនេះ។ នៅថ្ងៃនេះ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-858។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណា

មួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះ បានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីម្សិលមិញនេះ។

សូមអរគុណលោកប្រធាន។

[០៩:០៤:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី អង្គជំនុំជម្រះសុំសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់លោក នួន ជា ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥។ ហើយមេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាង ក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៥:៣៩]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះរ៉ុាំរ៉ៃ វិលមុខ និងមិនអាចអង្គុយយូរបាន និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះសម្រេចយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោទស្សន៍ភ្ជាប់ប្រព័ន្ធសោទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាច

ចូលរួមនិងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តី ដែលដំបូងនេះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[០៩:០៦:៥៧]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរភាគី។ លោកប្រធាន មុនពេលដែលខ្ញុំចាប់ផ្តើមសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីនេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីឱ្យខ្ញុំអាចធ្វើការកត់សម្គាល់ ក៏ដូចជាធ្វើសំណើឱ្យមានការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងឯកសារដែលខ្ញុំចង់ដកស្រង់យកមកអានឱ្យដើមបណ្តឹងរដ្ឋប្បវេណីនេះស្តាប់។ ខ្ញុំមានបំណងអានអត្ថបទដែលមាន -- ដែលជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺឯកសារ E305/13.23.292។ នេះគឺជាឯកសារដែលមានលេខ E3 ផងដែរ គឺ E3/8991។ តាមដែលខ្ញុំដឹង <សំណើមួយពី>ព្រះរាជអាជ្ញា<ដើម្បី>បានដាក់បង្ហាញ<ឯកសារ> ក៏ដូចជាការពិនិត្យទៅលើ *ហ្សាយឡូប* គឺជា<កិច្ចសម្ភាសន៍មួយមួយ នៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន>៦៦ ទាក់ទងទៅនឹងទំនប់ត្រពាំងថ្ម។

ប្រសិនបើខ្ញុំយល់មិនខុសទេ ឯកសារនេះត្រូវបានដាក់បញ្ចូលហើយបង្កើតឡើងនៅក្នុង ហ្សាយឡូប នៅក្នុងពេលថ្មីៗនេះ គឺកាលពីខែមិថុនា <ឆ្នាំនេះ> គឺប្រហែលជាមួយខែជាងមុននេះ គឺប្រាំមួយសប្តាហ៍មុន>។ កាលពីម្សិលមិញ យើងមិនបានពិភាក្សាគ្នាអំពីបញ្ហាដែលថា យើងត្រូវធ្វើការដោះស្រាយបញ្ហាជាមួយនឹងសាក្សី និងដើមបណ្តឹង<រដ្ឋប្បវេណីដែលនឹងត្រូវមកបន្ទាប់នេះ> ដែលមានឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាជាង<២៥០០ទំព័រ>។ ដូច្នេះអ្វីដែលខ្ញុំចង់ឱ្យព្រះរាជអាជ្ញាបកស្រាយផងដែរគឺថា តើវាជាការត្រឹមត្រូវដែរឬទេ ដែលថាកំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងត្រូវបានបកប្រែទៅជាភាសាអង់គ្លេស<តែក្នុងចំនួនកម្រិតមួយតែប៉ុណ្ណោះ ហើយយើងដឹងច្បាស់ថាមិន>មានឯកសារ ឌី.ស៊ី.ខេម ណាមួយបកប្រែ<>ជាភាសាបារាំងទេ<>។ ប្រសិនបើ<អ៊ីចឹងមែន>នោះ<> ប្រហែលវាជាបញ្ហាមួយទៀតហើយសម្រាប់យើង<ក្នុងការអានឯកសារដែលមាន២៥០០ទំព័រ ក្នុងរយៈពេលខ្លីមួយនោះ។>។

ខ្ញុំគិតថា ក្រៅពីព្រះរាជអាជ្ញាគឺថា ភាគីដទៃទៀតរួមទាំងចៅក្រមផងដែរ គឺមិនអាចមានសិទ្ធិចូលពិនិត្យមើលឯកសារនេះនៅមុនពាក់កណ្ដាលខែមិថុនានោះឡើយ <គឺនៅមួយខែមុននោះ>។ ដូច្នេះ <គឺមានបញ្ហាពីរ ខ្ញុំគិតថាបញ្ហានៃ>ឯកសារចំនួន៦៦ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺវាមានទំព័រប្រហែលជា ២៥០០ទំព័រឯណោះ <គឺគួរតែជាបញ្ហាមួយ ដែលខ្ញុំគិតថា វាគួរតែត្រូវបានលើកឡើងកាលពីម្សិលមិញ ដើម្បីឲ្យយើងដឹងច្បាស់អំពីទំហំនៃការដាក់បង្ហាញឯកសារនោះ។ ប៉ុន្តែ>បន្ថែមពីលើនេះ យើងមានបញ្ហាមួយទៀត <គឺដោយសារផ្នែកមួយនៃក្រុមរបស់យើងនេះអាចអានភាសាខ្មែរបាន ប៉ុន្តែខាងផ្នែកអន្តរជាតិ មិនអាចអានជាភាសាខ្មែរបានទេ។ ដូច្នេះ ខ្ញុំមិនដឹងថា>ខាងព្រះរាជអាជ្ញា<អាចដឹងថា តើពេលណា>ឯកសារ ឌី.ស៊ី.ខេម បកប្រែជាភាសាអង់គ្លេស<រួចរាល់នោះ>។ ដូច្នេះសូមឲ្យមានការបញ្ជាក់បំភ្លឺ។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមបំភ្លឺបើសិនជាមានបញ្ហាបកប្រែទៅជាភាសាអង់គ្លេស។ គឺថាជាភាសាបារាំងយើងលែងនិយាយទៅហើយ ពីព្រោះថារហូតដល់ថ្ងៃនេះ ទៅតាមការផ្ទៀងផ្ទាត់របស់យើងហ្នឹង គឺថាមិនទាន់មានការបកប្រែជាភាសាបារាំងទាល់តែសោះតែម្ដង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដើម្បីឲ្យច្បាស់ទាំងអស់គ្នា តើអាចបញ្ជាក់ដែរឬទេ ថាឯកសារទាំងអស់នេះទទួលរងការសម្រេចថាជាឯកសារអាចទទួលយកបាន ជាឯកសារភស្តុតាង<ថ្មី> ឬក៏ឯកសារទាំងអស់នេះត្រូវបានដាក់ឲ្យភាគីប្រើប្រាស់ <> ហើយនិងឲ្យភាគីទាំងអស់ដឹងពីខ្លឹមសារ<ដែលមាននៅក្នុងនោះ?>

[០៩:១១:៤៥]

**កញ្ញា អង់តា ហ្គីសសេ៖**

ព្រះរាជអាជ្ញា <បានធ្វើតាមនីតិវិធីដូចគ្នា ក្នុងការដាក់បង្ហាញកំណត់ហេតុនៃការហេតុស្ដាប់ចម្លើយ> នៅក្នុងសំណុំរឿង០០៣, ០០៤ នោះ គឺថាដាក់ដើម្បីឲ្យ<ភាគី>ប្រើតែប៉ុណ្ណោះ។ <វាគឺជាគោលការណ៍ដូចតែគ្នា។>

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ លោកកំពុងតែធ្វើសំណើដើម្បីប្រើឯកសារនុ៎ង នៅពេលសួរសំណួរសាក្សីបច្ចុប្បន្ននេះ។ អ៊ីចឹងលោកចង់ឲ្យឯកសារនេះត្រូវបានទទួលយកធ្វើជាឯកសារភស្តុតាងថ្មី អ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនទេលោកចៅក្រម។ ខ្ញុំដឹងថាឯកសារនេះត្រូវបានទទួលយកចូលជាសំណុំរឿងហើយដោយសារតែវាមានលេខ E3។ ដូច្នេះ បញ្ហាអ្វីដែលខ្ញុំចោទសួរនៅពេលនេះ គឺថាសេចក្ដីសង្ខេបរបស់ឯកសារចំនួន៦៦ គឺឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គឺសេចក្ដីសង្ខេបហ្នឹងបានបង្ហាញ -- ដាក់បង្ហាញមកដល់ភាគីយើងទាំងអស់គ្នាហើយ។ ដូច្នេះឥឡូវនេះ គឺយើងមានឯកសារចំនួន៦៦ <ដែលបានដាក់បង្ហាញកាលពីពីរសប្ដាហ៍មុន>។ ខ្ញុំ មានឯកសារបកប្រែជាភាសាអង់គ្លេសចំពោះឯកសារ ឌី.ស៊ី.ខេម ដែលខ្ញុំចង់បង្ហាញ<សម្រង់មួយជូន>ដល់សាក្សីទាំងអស់នេះរួចទៅហើយ។ ប៉ុន្តែប្រសិនបើយើងចង់មើលឲ្យឃើញនូវទិដ្ឋភាពជារួមនៃកំណត់ហេតុស្ដាប់ចម្លើយមួយនេះ គឺថាយើងត្រូវការឲ្យមានការពិនិត្យទៅលើឯកសារដទៃទៀតចំនួន៦៥ ឯណោះ។

[០៩:១៣:៣១]

ដូច្នេះ ខ្ញុំងើបឡើងមកទីនេះនៅពេលនេះ គឺដើម្បីបន្ថែមទៅលើអ្វីដែលយើងបានពិភាក្សាកាលពីម្សិលមិញ <អ្វីដែលយើងកំពុងតែដោះស្រាយនៅក្នុងសំណុំរឿងនេះ និង>អំពីសំណុំរឿង<ដ៏ធំនេះ គឺនៅពេលពាក់ព័ន្ធនឹងការដ្ឋានទំនប់> ក៏ដូចជាបញ្ហានៃការបកប្រែជាភាសាអង់គ្លេសរបស់ឯកសារ៦៦ មកពីឌី.ស៊ី.ខេម ទាំងអស់នេះ។ យ៉ាងណាក៏ដោយ អ្វីដែលខ្ញុំកំពុងតែកាន់ និងចង់អានហ្នឹង គឺមានជាភាសាអង់គ្លេសរួចទៅហើយ។ <ហេតុដូច្នេះហើយ ខ្ញុំអាចអានវាបាន និងមានគម្រោងក្នុងការអានសម្រង់មួយនេះជូន>ដើមបណ្ដឹងរដ្ឋប្បវេណីស្ដាប់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍៖**

បាទ សូមអរគុណដែលបានបំភ្លឺ។ អ៊ីចឹង<>ឥឡូវនេះលោកចង់ប្រើចម្លើយមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា<មួយនេះ>ក្នុងការ<សួរដេញដោល។ ប៉ុន្តែលោកកំពុងតែសួរ ថាតើឯកសារទាំងអស់នេះនឹងត្រូវ>ទទួលយកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿងឬ<ក៏>យ៉ាងណា?

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនទេ ព្រោះថាឯកសារនេះត្រូវបានទទួលរួចទៅហើយ ដោយសារវាមានលេខ E3។ អ៊ីចឹងមានន័យថាឯកសារនឹងត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយករួចទៅហើយ។ ប៉ុន្តែចំពោះការបក

ប្រែខ្ញុំមិនច្បាស់ទេ។ ដូច្នេះដើម្បីជាការអនុវត្តជាក់ស្តែង ការដកស្រង់ចេញពីឯកសារដែលខ្ញុំគ្រោងនឹងយកដកមកហ្នឹង គឺត្រូវបានទទួលយកជាភស្តុតាង គឺឯកសារ E3/8991។ ប៉ុន្តែក្នុងបរិបទទូលំទូលាយនៃឯកសារទាំង ៦៦ហ្នឹង ខ្ញុំមិនដឹងថា មានលក្ខណៈបែបណានោះទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមទោសដែលនៅតែទទូចនិយាយដដែល។ <ប៉ុន្តែ ខ្ញុំហាក់បីដូចជាយល់ថា ឯកសារនេះ>ត្រូវបានដាក់នៅហ្សាយឡេប ត្រឹមតែខែមិថុនា ហ្នឹងទេ។ អ៊ីចឹងខ្ញុំឆ្ងល់ថា ហេតុអីបើទើបតែដាក់ចូលក្នុងហ្សាយឡេប ខែមិថុនានេះ ហើយលោកថាឯកសារទាំងអស់នោះ ត្រូវបានទទួលយកជាឯកសារភស្តុតាង<នៅក្នុងសំណុំរឿងបានដោយរបៀបណា?> អ៊ីចឹងខ្ញុំសុំឲ្យជួយបំភ្លឺខ្ញុំបន្តិចត្រង់ចំណុចនេះពីព្រោះថាដូចជាចម្លែកដែរ។ <ប៉ុន្តែ ប្រហែលជាខាងសហព្រះរាជអាជ្ញាអាចបកស្រាយបំភ្លឺចំពោះបញ្ហានេះ។>

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំទទួលស្គាល់ថា ខ្ញុំមិនយល់ច្បាស់អំពីការព្រួយបារម្ភដែលលើកឡើងនោះទេ អ្វីដែលខ្ញុំឃើញនៅក្នុងហ្សាយឡេប គឺថាឯកសារនេះ ត្រូវបានទទួលបញ្ចូលទៅក្នុងហ្សាយឡេប កាលពីខែមេសា ឆ្នាំនេះ ហើយនេះគឺជាឯកសារមួយដែលចុះថ្ងៃ១៦ មិថុនា ២០១១។ ហើយទាក់ទងទៅនឹងសំណួរអំពីទិដ្ឋភាពជាទូទៅ ទិដ្ឋភាពទូលំទូលាយទាក់ទងថាតើមានការបកប្រែជាភាសាអង់គ្លេសឬក៏អត់នោះ នៅពេលដែលមានការដាក់បង្ហាញនោះ គឺយើងចង់បញ្ជាក់ថា យើងដាក់បង្ហាញនូវឯកសារ<បកប្រែ>ដែលមាន។ ហើយយើងគិតថាចំពោះកាលបរិច្ឆេទនៃការបកប្រែ<នោះ>គឺជាសមត្ថកិច្ចរបស់អង្គភាពបកប្រែភាសា។ ហើយម្យ៉ាងទៀត ឯកសាររបស់ ឌី.ស៊ី.ខេម គឺជាឯកសារដែលមានលក្ខណៈសាធារណៈ <វាមិនមែនជាឯកសារផ្តាច់មុខ>សម្រាប់តែព្រះរាជអាជ្ញា <នៅមុនពេលដែលយើងជ្រើសរើសក្នុងការដាក់បង្ហាញនៅក្នុងសំណុំរឿ០០២នោះទេ>។ ដូច្នេះ ភាគីទាំងអស់អាចពិនិត្យមើលឯកសារនេះបានមុនមកម្ល៉េះ។ ហើយមេធាវីការពារក្តី ខៀវ សំផន ក៏បាននិយាយអំពីសេចក្តីសង្ខេបរបស់ឯកសារ ឌី.ស៊ី.ខេម ទាំងអស់ ឬក៏សឹងតែទាំងអស់ដែលថា សេចក្តីសង្ខេបទាំងអស់នោះ ត្រូវបានដាក់បង្ហាញនៅក្នុងសំណុំរឿង០០២ រួចទៅហើយ។ ដូច្នេះបញ្ហានៃការសង្ខេបឯកសារ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

<ថាតើត្រូវបាន>បកប្រែ ឬក៏អត់នោះ គឺជាបញ្ហាមួយ<បន្ទាប់បន្សំនោះទេ>។

[០៩:១៧:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា ឯកសារអម្បាញ់មិញនេះ ដែលលោកមេធាវី កូប៉េ ចង់ប្រើនៅថ្ងៃនេះហ្នឹង គឺជាកម្មវត្ថុនៃសំណើសុំឱ្យទទួលយកជាភស្តុតាងថ្មី ឬក៏យ៉ាងណា ឬក៏ឯកសារនេះ ត្រូវទទួលការសម្រេចពីតុលាការ ថាទទួលយកឯកសារនេះជាឯកសារភស្តុតាងហើយ ឬក៏ព្រះរាជអាជ្ញា ឬក៏មេធាវីនាំមុខនោះជំទាស់មិនឱ្យប្រើឯកសារនេះនៅក្នុងសវនាការនេះ?

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

ខ្ញុំចាំបាច់ត្រូវធ្វើការស្រាវជ្រាវអំពីប្រវត្តិនីតិវិធីនៃឯកសារទាំងអស់នេះ ក៏ដូចជាបញ្ហាដែលបានលើកឡើងនៅក្នុងតុលាការនៅពេលនេះ។ ដូច្នេះ ខ្ញុំស្នើសុំឱ្យមានការផ្តល់ពេលវេលាឱ្យខ្ញុំដើម្បីស្រាវជ្រាវ ហើយម្យ៉ាងទៀត ឯកសារនេះគឺឯកសារដែលមានលេខ E3 រួចទៅហើយ។ ដូច្នេះ មានន័យថាឯកសារនេះត្រូវបានទទួលយករួចទៅហើយ។ ប៉ុន្តែចំពោះខ្ញុំ ខ្ញុំមិនជំទាស់អ្វីចំពោះសំណើរបស់លោក កូប៉េ ក្នុងការដកស្រង់ឯកសារនេះ យកមកអានឱ្យដើមបណ្តឹងរដ្ឋប្បវេណីនេះស្តាប់នោះឡើយ។

**ប្រធានអង្គជំនុំ៖**

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានអ្វីចង់ចាប់អារម្មណ៍ពាក់ព័ន្ធនឹងបញ្ហាឯកសារដែលស្នើសុំដោយលោកមេធាវី វ៉ិចទ័រ កូប៉េ អម្បាញ់មិញនេះដែរឬទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន យើងមិនមានការជំទាស់អ្វីទេ ពីព្រោះថា បើសិនខ្ញុំមិនច្រឡំទេឯកសារដែលមេធាវី នួន ជា ចង់ប្រើនេះ ជាឯកសារដែលស្ថិតនៅក្នុងចំណោមឯកសារដែលដាក់បញ្ចូលទៅក្នុង *អ៊ីទធើហ្វេស* កាលពីម្សិលមិញហើយ អ៊ីចឹងបើតាមនីតិវិធីហ្នឹងគឺត្រឹមត្រូវហើយ គឺជាឯកសារ E3 ហ្នឹងវាជាឯកសារដែលទទួលយករួចមកហើយ។ អ៊ីចឹង ខ្ញុំដូចជាមិនយល់ថាមានបញ្ហាអីកើតឡើងនោះទេ ជារឿងធម្មតា លោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:២២:១៤]

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារឯកសារដែលលោក វ៉ិចទ័រ កូប៉េ មានបំណងចង់ដកស្រង់ដើម្បីសួរដេញដោលទៅលើដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះគឺជាឯកសារដែលមានដាក់លេខ E3 រួចហើយនោះ បានន័យថាឯកសារនេះអង្គជំនុំជម្រះបានសម្រេចទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿង ជាឯកសារភស្តុតាងរួចហើយ។ ដូច្នេះ គឺលោក វ៉ិចទ័រ កូប៉េ អាចផ្អែកលើមូលដ្ឋាននៃឯកសារនេះក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនេះបាន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកដើម្បីបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនដែលខ្ញុំចង់សួរលោកនៅព្រឹកនេះ។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេដែលថាលោកកើតនៅក្នុងខេត្តបាត់ដំបង? តើលោកធំពេញវ័យនៅបាត់ដំបង ឬមួយក៏លោកជាមួយនឹងឪពុកម្ដាយរបស់លោកហ្នឹងផ្លាស់ទីលំនៅមកភ្នំពេញភ្លាមៗក្រោយពេលដែលលោកកើត?

**លោក សែន សុផុន៖**

**ឆ៖** ខ្ញុំមកធំនៅភ្នំពេញ ព្រោះពុកខ្ញុំគាត់មកធ្វើទាហាននៅកាន់ការនៅភ្នំពេញ។

**ស៖** អ៊ីចឹង បានន័យថាក្នុងពេលដែលលោកអាយុ ៥ទៅ១០ឆ្នាំហ្នឹង គឺលោកបានមកនៅភ្នំពេញហើយ អ៊ីចឹងមែនទេ?

**ឆ៖** បាទមែន។

**ស៖** តើលោកដឹងថាឪពុករបស់លោកជាទាហាន លន់ នល់ ហ្នឹង មានឋានន្តរសក្តិអ្វីដែរ?

**ឆ៖** គាត់ពាក់ស័ក្តិ២ នៅខាង សេតបេអ៊ី។

[០៩:២៤:៣៤]

**ស៖** តើគាត់ឈរជើងនៅទីណាដែរ? តើឪពុករបស់លោកឈរជើងនៅភ្នំពេញ? ឬក៏ឈរជើងនៅខាងក្រៅទីក្រុងភ្នំពេញទេ?

**ឆ៖** គាត់នៅចំការមន ដល់ពេលនៅចំការមនទៅ គេឲ្យគាត់ទៅនៅត្រពាំងព្រាយ ភ្នំប្រសិទ្ធិ៍។

**ស៖** កាលពីម្សិលមិញលោកផ្តល់សក្ខីកម្មថា "ឪពុករបស់លោកត្រូវបានគេសម្លាប់ដោយសារតែគាត់គឺជាទាហាន លន់ នល់"។ លោកដឹងទេថាគេសម្លាប់ឪពុកលោកហ្នឹងនៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ខ្ញុំឮតែយាយដែលនៅកៀនផ្ទះគាត់និយាយប្រាប់ តែមើលទៅប្រហែលជាក្នុងអំឡុង៧៨ ដើមឆ្នាំ៧៨ ចុងឆ្នាំ៧៧ ព្រោះអីឆ្នាំហ្នឹងទឹកវាធំលិចអស់ភូមិហ្នឹង គេជម្លៀសគាត់ឡើងមក។

**ស៖** ដូច្នេះ ខ្ញុំយល់ខុស ឬក៏ត្រូវដែលថាឪពុករបស់លោកហ្នឹងនៅឆ្នាំ៧៧ហ្នឹង គាត់នៅមានជីវិតនៅឡើយទេ តើខ្ញុំយល់អ៊ីចឹងតើខុស ឬក៏ត្រូវ?

**ឆ៖** ៧៧ ប្រហែលជានៅរស់ អត់ទាន់ស្លាប់ទេ ដល់ចូល៧៨ភ្លាម ពួកយាយថែមចូលនេះអាហ្នឹង គាត់យកសម្លាប់ពេលហ្នឹងឯង។

**ស៖** លោកនិយាយថា "ប្រហែល" អ៊ីចឹងប្រសិនបើលោកនិយាយថាប្រហែលហ្នឹង មានន័យថាលោកស្មានដែរ។ អ៊ីចឹងប៉ុន្តែខ្ញុំចង់ដឹងថាហេតុអ្វីបានជាលោកនិយាយថា គាត់ប្រហែលជាត្រូវបានគេសម្លាប់នៅឆ្នាំ៧៨ហ្នឹង?

**ឆ៖** ព្រោះពេលហ្នឹងទឹកវាឡើង វាលិច ហើយគេក៏ជម្លៀសគាត់ចេញពីហ្នឹងទៅ ដល់ពេលទៅជិតដល់៧៩នេះ ខ្ញុំបានជួបយាយទ្រព្យ ហ្នឹង គាត់ប្រាប់ថាអ៊ីចឹងឯង ប្រហែលក្នុងខែហ្នឹងឯង ឆ្នាំហ្នឹងទឹកវាលិចពេញទាំងអស់មួយខែវស្សាហ្នឹង។

[០៩:២៧:៤៤]

**ស៖** គាត់ត្រូវបានគេជម្លៀសចេញដោយសារទឹកជំនន់ អ៊ីចឹងមែនទេ? ហើយហេតុអ្វីក៏លោកដឹង? ហេតុអ្វីក៏លោកនិយាយថាប្រហែលជាគាត់ត្រូវបានគេសម្លាប់នៅឆ្នាំ៧៨? ខ្ញុំស្តាប់លោកទៅខ្ញុំអត់យល់ ថាលោកចង់និយាយថាម៉េច លោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំអត់យល់សំណួរហ្នឹង មិនដឹងសួរថាម៉េចទេ។

**ស៖** អ្វីដែលខ្ញុំសួរពីដំបូង គឺថា ហេតុអ្វីបានជាលោកថាគាត់ប្រហែលជាត្រូវបានគេសម្លាប់ឆ្នាំ៧៨? ហើយលោកឆ្លើយថា "គាត់ត្រូវបានគេជម្លៀសចេញដោយសារទឹកជំនន់"។ ដូច្នេះខ្ញុំសួរលោកបន្តទៀតថា ហេតុអ្វីបានជាលោកគិតថាការជម្លៀសដោយសារទឹកជំនន់ហ្នឹងធ្វើឲ្យគេសម្លាប់ឪពុករបស់លោក ខ្ញុំអត់យល់ត្រង់ចំណុចហ្នឹង។ តើការជម្លៀសដោយសារទឹកជំនន់ ហើយការសម្លាប់ហ្នឹងវាមាន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទំនាក់ទំនងគ្នាយ៉ាងម៉េចដែរ?

**ឆ៖** ពេលជម្លៀសហ្នឹងៗ យាយទ្រព្យ ហ្នឹងគាត់នៅជាប់ផ្ទះខ្ញុំគាត់និយាយប្រាប់ គាត់ថាគេយកៗ គេយកឪពុកខ្ញុំហ្នឹងមក យកឪពុកខ្ញុំមក ម្ដាយខ្ញុំគាត់ថាមកដែរៗ ថាទឹកក៏វាឡើងខ្លាំង គេក៏យកមកៗបាត់ពេលទឹកឡើងហ្នឹង គឺថាស្លាប់ស្ងាត់ឈឹងអាពេលហ្នឹងឯង។

**ស៖** គឺថាខ្ញុំយល់ ប៉ុន្តែខ្ញុំចង់ដឹងថាហេតុអ្វីបានជាលោកនិយាយថា ឪពុកលោកត្រូវបានគេសម្លាប់ ដោយសារតែគាត់ជាអតីតទាហាន លន់ នល់។ តើលោកផ្អែកទៅលើប្រភព ឬក៏ផ្អែកទៅលើព័ត៌មានអ្វីដែលធ្វើឱ្យលោកអាចទាញបានថា ឪពុកលោកត្រូវបានគេសម្លាប់ដោយសារគាត់ជាអតីតទាហានលន់ នល់ នោះ?

[០៩:៣០:០០]

**ឆ៖** ព្រោះ យាយទ្រព្យ ហ្នឹងគាត់នៅជាមួយឪពុកខ្ញុំ គាត់ដាំថ្នាំនៅជាមួយពុកខ្ញុំ។ ដល់ពេលអ៊ីចឹងទៅ ដល់ពេលគេមកយកគាត់ទៅ ប្រាប់ថា "ឪឯងជាប់ពាក់ព័ន្ធទាហានហ្នឹង ឥឡូវគេមកចាប់យកទៅហ្នឹងឯង បានយកទៅសម្លាប់ហ្នឹងឯង" បានដឹង ហ្នឹងជាពិត បាននាំពុកខ្ញុំយកទៅ។

**ស៖** ប៉ុន្តែ តើលោកដឹងទេថា ឪពុករបស់លោកបានលាក់ប្រវត្តិរបស់គាត់ជាទាហាន អត់ប្រាប់គេនៅក្នុងឆ្នាំ៧៥, ៧៦, ៧៧ ហើយអាចទៅដល់ឆ្នាំ៧៨ផង តើក្នុងចន្លោះឆ្នាំនោះគាត់ព្យាយាមលាក់ប្រវត្តិរូបគាត់ដែរឬទេ?

**ឆ៖** គាត់ព្យាយាមលាក់ដែរ សូម្បីតែខ្ញុំនៅជាមួយ ក៏គាត់លាក់ដែរ គាត់ថា "ធ្វើម៉េចកុំប្រាប់គេឱ្យដឹងពីរឿងពុក ថាពុកជាទាហាន" ព្យាយាមលាក់ ប៉ុន្តែមិនដឹងថាយ៉ាងណា បានគេដឹងថា គាត់ជាទាហាន។

[០៩:៣១:០៦]

**ស៖** ប៉ុន្តែលោកនិយាយថា គេដឹងអំពីប្រវត្តិរូបឪពុករបស់លោកជាទាហានហ្នឹង ដោយសារ គេប្រាប់លោក <គឺ>លោកអត់មានព័ត៌មានផ្ទាល់ទេ<ថាហេតុអ្វីបានជាគាត់បាត់ខ្លួននោះទេ> តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកធ្លាប់ឮថាគាត់ជាជនរងគ្រោះដោយសារទឹកជំនន់ដែរឬទេ?

**ឆ៖** គេប្រាប់ដែរ គេថា អូ្ហ! ទឹកជំនន់លិចអស់ហើយ បាត់ភូមិបត់ត្រង់ លិចអស់ នៅកន្លែងផ្ទះ

ខ្ញុំនៅគឺថាទឹកជិតបីម៉ែត្រ ព្រោះអីវានៅជាប់ព្រៃរនាម ជិតបីម៉ែត្រ ម្ល៉ោះហើយគេជម្លៀសមកទាំងអស់ អត់មានឲ្យអ្នកណានៅទេ។

**ស៖** តើ<>អ្នកជិតខាង<នេះមានបាន>ប្រាប់លោកថា តើគេដឹងថាឪពុកលោកជាទាហានហ្នឹង ដោយរបៀបណា? ថាតើ<គាត់ទទួលបានព័ត៌មានផ្ទាល់អំពីរឿងនេះឬ>?

**ឆ៖** អត់ដឹង អត់បានសង្កេតអារឿងអីចឹង ថាគ្រាន់តែយាយទ្រព្យ ប្រាប់ថា "គេថាជាទាហានគេយកទៅសម្លាប់ចោល"។

**ស៖** ខ្ញុំបន្តទៅប្រធានបទថ្មីមួយទៀត លោកដើមបណ្ដឹងរដ្ឋប្បវេណី។ គឺខ្ញុំនិយាយអំពីការងាររបស់លោកនៅទំនប់ត្រពាំងថ្ម កាលពីម្សិលមិញលោកផ្ដល់សក្ខីកម្មថា លោកធ្វើការនៅទីនោះពីរខែ ហើយ <តាផុន> ដែលជាប្រធានសហករណ៍ចាត់តាំងលោកឲ្យទៅទីនោះ តើលោកចាំទេ ថាតើ -- តើគាត់មានប្រាប់ថា ហេតុអ្វីបានលោកត្រូវទៅធ្វើការនៅទីនោះពីរខែ? តើគាត់មានពន្យល់ ឬក៏មានផ្ដល់ហេតុផលអី ថាហេតុអ្វីបានជាលោកត្រូវទៅធ្វើការនៅហ្នឹងពីរខែទេ?

**ឆ៖** គាត់ថា ឲ្យកង -- យកកងចល័តនេះទៅជំនួយបុកដើម្បីធ្វើឲ្យហើយឆាប់ៗ នៅក្នុងរយៈពីរខែហ្នឹង បានគេយកអ្នកសមរភូមិក្រោយទៅថែមទៀត។

[០៩:៣៤:៣១]

**ស៖** ប៉ុន្តែគាត់អត់មានប្រាប់លោកថា ហេតុអ្វីបានជាត្រូវទៅតែពីរខែទេ? ថាតើពេលពីរខែហ្នឹងគឺជាពេលដែលអ្នកដទៃគេធ្វើការដូចគ្នា<ដែរឬទេ>? ថាតើពីរខែហ្នឹង <គឺកម្មករ>ទៅធ្វើតែពីរខែ ឬមួយក៏លោកអត់ដឹងអំពីព័ត៌មានហ្នឹងទេ?

**ឆ៖** អត់ដឹងទេ គ្រាន់តែគេថា ឲ្យសម្រុក ឲ្យតែលឿនឆាប់ ខ្លាចទឹកវាឡើង ឲ្យសម្រុក ឲ្យឆាប់ៗ ដើម្បីយកមកធ្វើស្ពានស្រែងទៀត។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកបន្ថែមអំពីពេលម៉ោងធ្វើការ។ នៅពេលនោះ គឺនៅពេលដែលលោកធ្វើការនៅទំនប់នុ៎ង តើលោកមាននាឡិកាដែរឬទេ ឬក៏ថាលោកអាចមានកន្លែងណាមួយឲ្យលោកមើលម៉ោងបានទេ?

**ឆ៖** អត់មាននាឡិកា អត់មានអីទេ ម៉ោងមិនដឹងម៉ោងប៉ុន្មាន មើលតែថ្ងៃ។ ឲ្យតែឃើញថ្ងៃខ្ពស់ស្មានៗ ស្មានយកថ្ងៃ ថ្ងៃខែក៏មិនដឹងថ្ងៃ ខែណាថ្ងៃណាឆ្នាំណា ក៏អត់ដឹងទេ ដឹងតែធ្វើការតែមួយមុខប៉ុណ្ណោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** កាលពីម្សិលមិញ លោកបានផ្តល់សក្ខីកម្មថា នៅក្នុងរយៈពេលពីរខែនោះ ដែលគឺពេលៗពីរខែដែលលោកធ្វើការនុំង នៅពេលព្រឹក។ <ខ្ញុំសូមដកស្រង់៖> “នៅពេល<ភ្លឺច្បាស់ មើលឃើញកម្មករផ្សេង>ទៀតធ្វើការដែរនុំង។” <ចំពោះបទពិសោធន៍របស់លោក តើលោកនៅពេលហ្នឹងវាម៉ោងប៉ុន្មានដែរ>?

[០៩:៣៦:៣៩]

**ឆ៖** មេឃភ្លឺស្រាងៗ ល្មមមើលគ្នាឃើញ គេឲ្យធ្វើហើយ។

**ស៖** តើលោកៗអាចបញ្ជាក់បានទេ នៅពេលដែលលោកថា “ភ្លឺស្រាងៗ”ហ្នឹង តើប្រហែលជាម៉ោងប៉ុន្មានដែរ ម៉ោងប្រាំមួយ ប្រាំមួយកន្លះ <ដោយសារនៅពេលនោះ គឺជារដូវប្រាំង>?

**ឆ៖** បើខ្ញុំស្មានខ្លួនខ្ញុំ ខ្ញុំថាប្រហែលជាម៉ោងប្រាំ ទៅប្រាំកន្លះប៉ុននុំងឯង ដែលភ្លឺស្រាងៗឡើង។

**ស៖** កាលពីម្សិលមិញ ក៏លោកបាននិយាយអំពីមីក្រូ តើមីក្រូហ្នឹង គេមានប្រកាសអំពីម៉ោងពេលវេលា <ចាប់ផ្តើម>ធ្វើការសម្រាប់កម្មករ<១០ ឬ១៥ ឬ២០,០០០នាក់?> ឬមួយក៏ថាមានការប្រកាសនៅពេលព្រឹកតាមមីក្រូហ្នឹង ឲ្យកម្មករទាំងអស់<ចាប់ផ្តើម>ធ្វើការដែរឬទេ?

**ឆ៖** អត់មានប្រកាសទេ មីក្រូទុកសម្រាប់តែវាចម្រៀងតែប៉ុន្មានបទហ្នឹងឯង។ បើហៅចេញទៅធ្វើការ គឺថាដើមដេញ បើនិយាយឲ្យដល់ទៅ ដូចសត្វគោអ៊ីចឹងឯង។

[០៩:៣៨:៤៧]

**ស៖** តើលោកថា “ពួកគេហ្នឹង”ៗ សំដៅទៅលើអ្នកណាដែល<ប្រាប់លោកឲ្យភ្ញាក់ពីដំណេកហើយចាប់ផ្តើមជីកដី និងសែងដី? តើ វ៉ា ឬ?>

**ឆ៖** ប្រធានកង ប្រធានកងហ្នឹងឯង ដែលដើរដេញ អ្នកមើលទាំងអស់ហ្នឹង ដើរដេញទៅ។

**ស៖** ថាតើអ្នកណាជាអ្នកប្រាប់លោក ហើយនិង<សមាជិកកង>របស់លោកឲ្យងើបឡើង ឲ្យទៅធ្វើការនៅពេលថ្ងៃមួយៗ។ ដូច្នេះខ្ញុំចង់ដឹងថាតើ អ្នកដែលប្រាប់លោកហ្នឹង តើជាអ្នកណា តើ វ៉ា មែនទេ? តើឈ្មោះ វ៉ា មែនទេ?

**ឆ៖** ប្រធានកងធំ ខ្ញុំអត់ដឹងទេ តែហ្នឹងគឺប្រធានកងតូចទេ គេក្រោមបញ្ជាពួកហ្នឹងដែរ តែពួកនុំងហៅ គេគង់តែហៅពួកខ្ញុំដែរ។

**ស៖** តើប្រធានកងរបស់លោកៗ គាត់មកពីសហករណ៍ជាមួយលោកមែនទេ?

**ឆ៖** អត់ទេនៅខុសគ្នា តែគេបញ្ចូលជាមួយគ្នា បញ្ចូលទៅមួយកងជាមួយគ្នាអ៊ីចឹង។

**ស៖** អ៊ីចឹងគាត់អត់នៅក្នុងសហករណ៍ជាមួយ តាផុន ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ គាត់នៅខុសគ្នា បានខ្ញុំអត់ស្គាល់គាត់។

**ស៖** កាលពីម្សិលមិញលោកបាននិយាយអំពីលទ្ធផល ប្រសិនបើមិនបានបំពេញបញ្ចប់ការងារតាមការកំណត់របស់គេ។ នៅក្នុងរយៈពេលពីរខែដែលលោកធ្វើការនៅទំនប់នោះ តើលោកធ្លាប់ -- តើមានពេលណាមួយដែលលោកបំពេញការងារអត់បានគ្រប់តាមចំនួនកំណត់របស់គេដែរឬទេ? ឧទាហរណ៍ថា ក្នុងមួយថ្ងៃលោកបំពេញការងារអត់បានគ្រប់ ៣ម៉ែត្រគូបតាមដែលគេកំណត់ហ្នឹងទេ តើលោកធ្លាប់ជួបបញ្ហាហ្នឹងទេ?

[០៩:៤១:៤៦]

**ឆ៖** ខ្ញុំធ្វើមិនបានទេ៣ម៉ែត្រគូបហ្នឹង ធ្វើអត់បាន រាល់តែថ្ងៃតាំងពីខ្ញុំទៅ ខ្ញុំធ្វើអត់បាន ៣ម៉ែត្រគូបទេ តែខ្ញុំបាយយប់រហូតម៉ោងដប់ ម៉ោងស្ទើរហូត ទាល់តែគេឲ្យឡើងទាំងអស់គ្នា "អើ! ឡើងទាំងអស់គ្នាបាននេះ" តែ៣ម៉ែត្រគូប ខ្ញុំធ្វើអត់រួចទេ។

**ស៖** ហេតុអ្វីបានជាដូច្នេះ?

**ឆ៖** កម្លាំងខ្ញុំវាខ្សោយ អត់មានកម្លាំង ក្បាលជង្គង់ធំពេក ធំជាងខ្លួន។

**ស៖** ដូច្នេះ លោកចង់និយាយថាក្នុងរយៈពេល ៦០ថ្ងៃ គឺពីរខែ ដែលលោកធ្វើការនៅទីនោះ គឺថាលោកមិនអាចបំពេញតាមផែនការកំណត់របស់គេបានគ្រប់ទេ។ តើលោកចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែន។

**ស៖** ម្សិលមិញលោកនិយាយថា អ្នកដែលមិនបំពេញបានតាមផែនការកំណត់ត្រូវគេកាត់របបអាហារ ឬក៏ត្រូវគេវ៉ៃ។ តើលោកធ្លាប់ត្រូវគេកាត់របបអាហារ ឬក៏ធ្លាប់ត្រូវគេវ៉ៃ ៦០ដងដែរឬទេ? តើខ្ញុំនិយាយអ៊ីចឹងវាត្រឹមត្រូវ ឬក៏ខុស?

**ឆ៖** អត់ទេ គេមិនកាត់ -- ថ្ងៃណា ៦០ដង ខ្ញុំដូចអត់មានទេ។ គ្រាន់គេមិនឲ្យៗយើងឡើងកំណត់ម៉ោងប៉ុណ្ណោះឯង។

[០៩:៤៤:១៧]

**ស៖** អ៊ីចឹងបានន័យថាគេមិនដែលធ្លាប់កាត់របបអាហារ ឬក៏គេមិនធ្លាប់វ៉ៃលោកទេ ក្នុងរយៈពេល៦០ថ្ងៃ ដែលលោកធ្វើការនុ៎ង។ តើអ៊ីចឹងមែនទេ?

**ឆ៖** មែន។

**ស៖** អ៊ីចឹងតើមានអ្នកណាផ្សេងដែលត្រូវគេវៃ ឬក៏ត្រូវគេកាត់របបអាហារដែរឬទេ? តើលោកធ្លាប់ឃើញថា សមាជិកកងរបស់លោកធ្លាប់ត្រូវគេវៃ ឬក៏ធ្លាប់ត្រូវគេកាត់របបអាហារដែរឬទេ?

**ឆ៖** អត់ទេ អត់ឃើញទេ។ គ្រាន់តែគេវៃពេលៗឡើងពីដេកពីព្រឹកឡើងហ្នឹងឯង ដែលគេវាយរគាំងគេនាំគ្នាដេកយូរ គឺនាំគ្នាគេដេញឲ្យៗចេញពីរោង។

**ស៖** ប៉ុន្តែតើអ្នកណាជាអ្នកកាន់រំពាត់ដើរវៃគេហ្នឹង? តើលោកស្គាល់ឈ្មោះគាត់ហ្នឹងទេ?

**ឆ៖** អត់ស្គាល់ទេ គេមេកងធំ អត់ស្គាល់ឈ្មោះទេ។

**ស៖** តើដោយសារតែលោកមិនចាំ ឬក៏ដោយសារតែលោកមិនបានដឹងទេនៅពេលនោះ?

**ឆ៖** ខ្ញុំអត់សូវចាំឈ្មោះគេផង ពួកនុ៎ង។

**ស៖** ពីម្សិលមិញលោកនិយាយពីឈ្មោះ តាវ៉ាល់។ សូមដកស្រង់៖ "គឺថាជាអ្នកគ្រប់គ្រងទូទៅនៅតំបន់៥"។ តើតាវ៉ាល់ ធ្លាប់បានឃើញមេកងប្រើរំពាត់អី ដើម្បីវាយមកលើសមាជិកកងរបស់ខ្លួនទេ?

**ឆ៖** បើតាមខ្ញុំសង្កេតមើល តាវ៉ាល់ គាត់គ្មាន គាត់មិននេះទេ ប៉ុន្តែគ្រាន់តែជាពាក្យបញ្ជា ឬមិនដឹង។ ប៉ុន្តែតាវ៉ាល់ គាត់ឮតែឈ្មោះទេ គាត់មិនដែលមកកន្លែងហ្នឹង។ យូរៗ គាត់មកមើលម្តងហើយគាត់ទៅបាត់ហើយ។

[០៩:៤៧:១៨]

**ស៖** លោកប្រធានខ្ញុំសូមការអនុញ្ញាតអានសម្រង់ដែលខ្ញុំបានលើកឡើងពីខាងដើម ដើម្បីជាប្រតិចារឹក គឺឯកសារ E305/13.23.292 ដូចខ្ញុំបានបញ្ជាក់<ពីមុនហើយ គឺឯកសារនេះមានលេខ E3 ផងដែរ គឺ> E3/8991, ERN ជាភាសាអង់គ្លេស 00969903, ខ្មែរ 00730232។ លោកសាក្សីនេះគឺជាសំណួរដែលគេបានសួរទៅមនុស្សម្នាក់ដែលធ្លាប់បានធ្វើការនៅការដ្ឋាននៅទំនប់នោះដែរ ហើយគេបានសួរបុគ្គលរូបនេះអំពីឈ្មោះ តាវ៉ាល់។ ខ្ញុំសូមអានចម្លើយរបស់បុគ្គលរូបនេះដើម្បីសួរមើល ថាតើលោកយល់ដូចម្តេចដែរ។ សំណួរពីអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅត្រង់ពាក់កណ្តាល ទំព័រ៖ "ចុះតាម៉ោង ហើយនិង តាវ៉ាល់ ដែលស្តីឲ្យពូទេ? ហើយបុគ្គលរូបនេះឆ្លើយ៖ អត់សូវដែលបានជួបគេទេ ព្រោះ<ខ្ញុំស្ថិតនៅក្នុងថ្នាក់កងវរសេនាធំ នៅក្រោមពួកគេ>។ តែ<ពួកហ្នឹងពូកែ>ស្តីឲ្យ<អ្នកដទៃណាស់> ហើយព្រោះពួកហ្នឹងកាចៗណាស់ កាចជាងយាយថែមឆ្ងាយៗណាស់<។> ខ្ញុំធ្លាប់ឮថាគេនិយាយហៅគាត់ថាជា គេហៅថា តាចង្កូមមាស"។ លោកដើមបណ្តឹងរដ្ឋប្បវេណី តាមបទពិសោធន៍របស់លោក តើតាវ៉ាល់ ជាមនុស្សកាចៗ ហើយនិយាយមិនពីរោះពិសាអ៊ីចឹងមែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៤៩:២៨]

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាល់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី ហុង គឹមសួន!

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមជំទាស់ចំណុចនេះ ដោយសារដើមបណ្តឹងគាត់បានឆ្លើយហើយថាគាត់មិនបានឃើញ តាវ៉ាល់ ផ្ទាល់ទេ។ យូរគាត់ឃើញមកម្តង តែគាត់មិនស្គាល់ទេ។ អ៊ីចឹងគាត់មិនអាចស្មានអំពីចរិតលក្ខណរបស់ តាវ៉ាល់ បានទេបាទ។ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាវាមិនចេញពីបទពិសោធន៍ផ្ទាល់របស់គាត់ មិនឃើញផ្ទាល់ភ្នែកទេ ប៉ុន្តែគាត់អាចធ្លាប់ឮពីគេ ទទួលបានព័ត៌មានពីអ្នកដទៃ ដូចជានិយាយអំពីជោគវាសនារបស់ឪពុកម្តាយគាត់ជាដើម។ ដូច្នេះ ខ្ញុំយល់ឃើញថា អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យខ្ញុំសួរសំណួរនេះ ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីបាន។

[០៩:៥០:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណួរដែលសួរនេះ។ ហើយប្រសិនបើស្តាប់យល់នូវសំណួរ គឺដើមបណ្តឹងរដ្ឋប្បវេណីអាចឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវីការពារក្តី នួន ជា។

**លោក សែន សុផុន៖**

**ឆ៖** ខ្ញុំឮតែគេថា "អូ៎! តាវ៉ាល់កាច តាវ៉ាល់ កាចណាស់ តែមិនដែល -- តែមុខតាវ៉ាល់ ក៏អត់ឃើញច្បាស់ផង ព្រោះអីខ្ញុំនៅក្រោមទំនប់ គាត់ដើរ បើថាដើរទៅ គាត់ដើរទទឹងលើខ្នងទំនប់ឡើងឆ្ងាយក៏មិនស្គាល់ផង មើលមុខក៏មិនឃើញ មិនដឹងថាមួយណាផង ឃើញដើរពីរបីនាក់ បួននាក់អ៊ីចឹង អត់ស្គាល់សោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ពីម្សិលមិញ លោកបាននិយាយពីឈ្មោះ យាយថែម។ ហើយពិតណាស់ថា ពីម្សិលមិញ

លោកបាននិយាយថា<> សូមដកស្រង់៖ "ឆ្នាំ១៩៧៨ យាយថែម គឺជាអ្នកដែលមកចាប់ តាវ៉ាល់ និង ឪពុកម្តាយរបស់ខ្ញុំយកទៅសម្លាប់ចោល"។ បុគ្គលរូបនេះ ពេលឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាថា "តាវ៉ាល់នេះ គឺកាចជាងយាយថែម ឆ្ងាយណាស់"។ តើនេះ គឺជាអ្វីដែលលោកធ្លាប់បានឮដែរឬទេ?

[០៩:៥២:២៧]

**ឆ៖** អត់ដឹងទេ ពាក្យហ្នឹងខ្ញុំអត់ដែលឮផង។

**ស៖** បាទ សម្រង់តូចមួយពាក់ព័ន្ធនឹងផ្នែកនេះដែរ គឺប្រជាជនហៅតាវ៉ាល់ថា "តាចង្កូមមាស" ពាក្យខ្មែរគឺថា តាមពិតគឺថា វាមានពាក្យខ្មែរពិសេសដែលហៅទៅលើរូបគាត់នេះ។ ដូច្នេះ មុននឹងខ្ញុំសួរសំណួរសូមឲ្យអ្នកបកប្រែជាភាសាខ្មែរប្រើពាក្យដែលប្រើប្រាស់នៅក្នុងអត្ថបទដើមជាភាសាខ្មែរ។ ឥឡូវចាត់ទុកថា អ្នកបកប្រែស្គាល់ពាក្យនេះទៅចុះ តើតាវ៉ាល់ នេះត្រូវបានគេហៅគាត់ថា "តាចង្កូមមាស" មែនទេ?

**ឆ៖** ខ្ញុំអត់ដឹង ខ្ញុំអត់ឮផង ពាក្យ "ចង្កូមមាស"ហ្នឹង។

**ស៖** ខ្ញុំសូមសួរលោកអំពីមនុស្សម្នាក់ទៀតនៅក្នុងតំបន់៥។ តើលោកធ្លាប់ឮសូរឈ្មោះ តាជាល ឬតាឆ្នាំង ដែរទេ?

**ឆ៖** អត់ឮ អត់ឮឈ្មោះ តាជាល តាឆ្នាំង អត់ឮ។

**ស៖** ខ្ញុំនិយាយសំដៅទៅលើមនុស្សតែមួយទេ គឺតាឆ្នាំង ហៅតាជាល គាត់ជាកូនប្រុសរបស់មេភូមិភាគពាយ័ព្យ រស់ ញឹម។ តើលោកនឹកឃើញទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ អត់ឮ។

**ស៖** មិនថ្វីទេ ខ្ញុំសូមបន្តទៅប្រធានបទមួយថ្មីទៀត។ លោកបាននិយាយអំពីថា មានការប្រព្រឹត្តខុសៗគ្នាមកលើប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន <ដែលកម្មាភិបាលមូលដ្ឋានអាចញែកដឹងពីភាពខុសគ្នាដោយសារតែសំនៀងបញ្ចេញសំឡេង>របស់ពួកគាត់។ <សូមលោកប្រាប់ថា តើវាប្រព្រឹត្តទៅដោយរបៀបម៉េចដែរ?> ឧទាហរណ៍ពាក់ព័ន្ធទៅនឹងការចែករបបអាហារ តើគេត្រូវមាននិយាយ<>មុនសិន ឬ<>មុននឹងគេចែក<បាយ ឬបបរឲ្យនោះ? ឬតើការអនុវត្តនោះធ្វើឡើងដោយរបៀបណាដែរ>?

**ឆ៖** គេអត់មាននិយាយអីទេ គេថា យើងខ្វះ ជីវភាពខ្វះខាត គេចែកឲ្យទៅ ម្នាក់មួយវែកៗទៅហើយ។ ហើយការបែងចែកហ្នឹង វាមានអីចេះ! ខាងប្រជាជនចាស់ គេហូបតែបាយ តែយើងប្រជាជនថ្មីគេដួសបបរឲ្យមួយវែកៗចែកគ្នាទៅ។

**ស៖** ខ្ញុំយល់ពីសក្ខីកម្មលោកហើយ លោកក៏បានឆ្លើយពីម្សិលមិញដែរ ឆ្លើយទៅនឹងសំណួរសហព្រះរាជអាជ្ញា ប៉ុន្តែនៅពេលដែលគាត់សួរលោកថា តើមានការប្រព្រឹត្តខុសគ្នាដែរទេ? ឧទាហរណ៍ដូចជាការផ្តល់របបអាហារជាដើម។ល។ ហើយលោកបានឆ្លើយថា ប្រជាជនមូលដ្ឋានហ្នឹងគឺថា គេនិយាយទៅគេមានសូរសៀង មានសម្តីហ្នឹងខុសពីប្រជាជនថ្មី។ តើគេអាចកត់សម្គាល់ស្តាប់បាននូវសូរសៀងរបស់ប្រជាជនទាំងហ្នឹងខុសៗគ្នាបានដោយរបៀបណា? <តើដំបូងគេត្រូវនិយាយខ្មែរសិន មុននឹងទទួលបានបាយ ឬក៏បបរឬ?> តើគេកត់សម្គាល់បានដោយរបៀបណាដែរ?

**ឆ៖** សំនៀងវាខុសគ្នា។ ខាងភ្នំពេញផ្សេង ខាងបាត់ដំបងនេះផ្សេង កន្លែងខ្ញុំនៅហ្នឹងផ្សេងគ្នា គឺគេនិយាយ "កឹកឹ" ខុសគ្នា ហើយគេដឹងទៀត គេចាត់ទុកថាប្រជាជនថ្មីនេះសម្រាប់អ្នកធ្វើការ, ប្រជាជនចាស់នេះ គឺសម្រាប់អ្នកមើលតែប៉ុណ្ណឹង។

[០៩:៥៧:៣៧]

**ស៖** ខ្ញុំដូចជាយល់ចម្លើយលោកមិនបានច្បាស់ទេ។ <សំនៀងសំឡេងរបស់បុគ្គលម្នាក់ គឺមិនអាចមើលដឹងតាមរយៈមុខរបស់បុគ្គលនោះទេ។ ដូច្នេះបុគ្គលនោះត្រូវនិយាយសិន នៅចំពោះមុខយើង> ដើម្បីស្តាប់តុងរបស់គាត់ហ្នឹង។ <ដូច្នេះអ្នកដែលចែកម្ហូបនៅក្នុងសហករណ៍ ឬក៏សូម្បីតែនៅការដ្ឋានទំនប់ តើមានអ្វីកើតឡើងនៅពេលគាត់ព្យាយាមកំណត់ថា បុគ្គលនេះគួរតែទទួលបានបាយ ឬក៏បបរនោះ?> តើគេឲ្យប្រជាជននិយាយជាមុនសិន ឬយ៉ាងម៉េចដើម្បីគេស្តាប់សំនៀងរបស់គាត់ហ្នឹងសិន មុននឹងចែករបបអាហារ ឬយ៉ាងណា?

**ឆ៖** ទេ គេមិនមែនធ្វើអ៊ីចឹងទេ។ គេធ្វើ -- ប្រជាជនថ្មីនេះទាំងអស់គឺថា ជាកូនក្រុមរបស់គេ គេជាមេក្រុម ជាអ្នកដឹកនាំ គឺថាគេចែកៗអ្នកក្រុមហ្នឹងឯង។ អ្នកដឹកនាំ គេហូបផ្សេងគ្នាគេ។

**ស៖** តាមដែលខ្ញុំយល់ ប្រជាជនជាច្រើនដែលត្រូវបានជម្លៀសចេញពីភ្នំពេញបានធ្វើដំណើរទៅកាន់តំបន់ ឬក៏ភូមិស្រុកដែលគេធ្លាប់រស់នៅ។ ដូច្នេះ ខ្ញុំគិតថា<អ្នកដែលត្រូវគេជម្លៀសដ៏ច្រើននេះអាចនិយាយ>ដោយមានសំនៀងសំឡេងហ្នឹងគឺថា ដូចគ្នានឹងអ្នកនៅបាត់ដំបងចាស់នោះដែរ។ <ខ្ញុំនៅតែមិនច្បាស់ថា តើនៅក្នុងការអនុវត្តចំពោះការបែងចែករបបអាហារបែបនេះ ធ្វើឡើងដោយរបៀបណាដែរ។>ដូច្នេះ ខ្ញុំព្យាយាមសួរលោកម្តងទៀត។ សូមលោកជម្រាបជូនអង្គជំនុំជម្រះមើល <ហេតុអ្វីបានជា> មានការប្រព្រឹត្តខុសគ្នា? ហើយធ្វើម៉េចបានជាគេកត់សម្គាល់ដឹងថាអ្នកនេះជាប្រជាជនថ្មី, អ្នកនោះជាប្រជាជនមូលដ្ឋាន?

**ឆ៖** ឲ្យតែអ្នកប្រជាជនមូលដ្ឋាន គេគ្រប់គ្រងអ្នកថ្មីហ្នឹងទាំងអស់។ ការគ្រប់គ្រងគេដឹងហើយ ដឹងថា អ៊ូ! នេះគេមូលដ្ឋាន គេគ្រប់គ្រងពួកយើងទាំងអស់គ្នា ដឹងនិយាយសំនៀងមកចេញមកអ្នកបាត់ដំបង អ្នកមូលដ្ឋានហ្នឹងឯង។ បានគេថាមានអ្នកចាស់ មានអ្នកថ្មី។

**ស៖** បាទ មិនអីទេលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំគិតថាខ្ញុំនៅសល់តែមួយសំណួរទៀតទេ។ នៅក្នុងសេចក្ដីរៀបរាប់អំពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក គឺឯកសារD22/1232, ERN ភាសាអង់គ្លេស 0523258 *(ស៊ីក)*។ លោកប្រធានមិនទាន់មានERN ជាភាសាខ្មែរ និងភាសាបារាំងទេ។ នៅក្នុងសេចក្ដីរៀបរាប់របស់លោកចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគឺមានផ្នែកមួយនិយាយ "<ឧក្រិដ្ឋកម្មដែលត្រូវ>ចោទប្រកាន់", <"កាលបរិច្ឆេទនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម",> "ព្យសនកម្ម" <"ការទាមទារសំណង"។> ហើយក៏មានផ្នែកមួយនៅក្នុងពាក្យសុំនេះ និយាយ<>អំពីការទទួលខុសត្រូវ<ចំពោះឧក្រិដ្ឋកម្ម>។ ដូច្នេះបុគ្គលដែលលោកគិតថាជាអ្នកទទួលខុសត្រូវចំពោះអ្វីដែលកើតមកលើរូបលោកនៅក្នុងរបបនោះ នៅក្នុងប្រអប់ត្រង់ផ្នែកនេះ លោកបំពេញមានឈ្មោះសម្ដេចព្រះ នរោត្តម សីហនុ ថាជាក្សត្រដែលត្រូវទទួលខុសត្រូវចំពោះព្យសនកម្មដែលកើតមកលើរូបលោក។ សូមលោកពន្យល់បន្តិចបានទេ ជម្រាបជូនអង្គជំនុំជម្រះ ចំណុចនេះបន្តិចបានទេ?

**ឆ៖** ថាម៉េចខ្ញុំអត់យល់ផងហ្នឹង។

[១០:០២:២៦]

**ស៖** ខ្ញុំព្យាយាមម្ដងទៀត។ លោកដើមបណ្ដឹងរដ្ឋប្បវេណីនេះ ខ្ញុំមានឯកសារនៅក្នុងដៃរបស់ខ្ញុំហើយ គឺឯកសារនេះហៅថា <របាយការណ៍ព័ត៌មាន>ដើមបណ្ដឹងរដ្ឋប្បវេណី<> ដែលទម្រង់នេះគឺថាត្រូវបានរៀបចំឡើងដោយ<>អង្គភាពគាំពារជនរងគ្រោះ។ <បុគ្គលិកនៅតុលាការនេះ គឺ>សរសេរត្រង់ផ្នែកមួយ ហើយផ្នែកហ្នឹង គឺលោកបានគិតថា បុគ្គលដែលត្រូវទទួលខុសត្រូវចំពោះការខូចខាតមកលើរូបលោកហ្នឹង លោកបានលើកឡើងថា "គឺសម្ដេច នរោត្តម សីហនុ"។ <ដូច្នេះ សំណួររបស់ខ្ញុំគឺ តើលោកធ្លាប់ប្រាប់បុគ្គលិកនៃអង្គភាពគាំពារសាក្សីថា> លោកគិតថាសម្ដេចព្រះ នរោត្តម សីហនុ នេះជាៗអ្នកទទួលខុសត្រូវចំពោះព្យសនកម្មដែលកើតមកលើរូបលោក?

**ឆ៖** អ៊ូ! ខ្ញុំនឹកឃើញហើយ។ អាហ្នឹងអីចេះ គឺថាមកពីគាត់ដែលដឹកនាំបក្សកុម្មុយនីស្តហ្នឹងចូលក្នុងប្រទេសកម្ពុជា។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកអាចរៀបរាប់ឲ្យបានលម្អិតបន្តិចបានទេ តើអតីតព្រះមហាក្សត្រនេះ <មានតួនាទី និងមុខតំណែងអ្វីឲ្យប្រាកដនៅក្នុងបក្ស>កុម្មុយនីស្តនេះ<>ដែរ?

[១០:០៤:១៦]

**ឆ៖** ខ្ញុំអត់ដឹងដែរ តែពុកខ្ញុំនិយាយប្រាប់អ៊ីចឹងឯងថា បក្សកុម្មុយនីស្តនេះ សម្តេចទេអ្នកនាំៗបក្សកុម្មុយនីស្តនេះចូលប្រទេសកម្ពុជាដើម្បីរំដោះលន់ នល់។

**ស៖** នៅក្នុងទម្រង់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរបស់លោក គឺលោកសុំទារសំណង<១០០០>ដុល្លារ។ ដូចដែលយើងដឹងហើយគឺថាសម្តេច នរោត្តម សីហនុ ព្រះអង្គសោយទិវង្គតហើយ។ <>តើលោកទារពីរាជទាយាទ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ គឺមិនពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីនេះទេ អ្នកដែលដើមបណ្តឹងរដ្ឋប្បវេណីថា ត្រូវតែទទួលខុសត្រូវចំពោះសំណងហ្នឹង គឺវាមិនពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា និងខៀវ សំផន ដូចដែលបានចោទប្រកាន់នោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហុង គឹមសួន!

[១០:០៦:០០]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។ ចំណុចនេះ ខ្ញុំបាទក៏សូមជំទាស់ផងដែរ ដោយសារវាទាក់ទងជាមួយនឹងសំណួរ គេបានសួរថា "តើអ្នកដែលអ្នកជឿ?" ភាសាខ្មែរសរសេរអ៊ីចឹង។ អ៊ីចឹងសំណួរសួរថាគាត់ជឿ មិនមែនគាត់ស្គាល់ច្បាស់ថាជនជាប់ចោទជានរណានោះទេ។ អ៊ីចឹងសំណួរនេះមិនទាក់ទងជាមួយនឹងការទារសំណងពីសម្តេច នរោត្តម សីហនុ ឬតែព្រះរាជទាយាទទេ ទាក់ទងតែជាមួយនឹងជនត្រូវចោទនៅក្នុងសវនាការនេះតែប៉ុណ្ណោះបាទ។ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំយល់ថា ខ្ញុំគួរត្រូវបានអនុញ្ញាតសួរតំណាងឲ្យកូនក្តីរបស់ខ្ញុំ តើកូនក្តីខ្ញុំត្រូវចេញសំណង <១.000>ដុល្លារ ដូចបានទាមទារ ឬក៏យ៉ាងណា បើរកឃើញថាមានពិរុទ្ធភាពនោះ ឬក៏ត្រូវទារអំពីទាយាទរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ។ <ខ្ញុំគិតថា ការទាមទារសំណង គឺជាផ្នែកមួយនៃសវនាការជំនុំជម្រះក្តីនេះ។>

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

លោកប្រធាន ខ្ញុំសូមឲ្យយើងពិចារណាឲ្យបានច្បាស់នៅចំពោះមុខអង្គជំនុំជម្រះនេះ គឺដើមបណ្តឹងរដ្ឋប្បវេណី គាត់មិនមានសិទ្ធិទាមទារសំណងជាលុយកាក់ទេ ហើយតាំងពីការស៊ើបអង្កេតមក គឺថាកូនក្តីរបស់មេធាវី កូប៉េ ហ្នឹងគាត់បានបញ្ជាក់ហើយថាគាត់ជាជនក្រីក្រ។ ដូច្នេះ គឺថាមិនមែនគាត់ជាអ្នកត្រូវផ្តល់សំណងទេ។ ដូច្នេះ សូមតុលាការកុំអនុញ្ញាតឲ្យសួរសំណួរនេះ ពីព្រោះថាសំណួរនេះ គឺមិនមានពាក់ព័ន្ធអីនឹងសវនាការយើងនេះទេ។

[១០:០៧:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ហើយនិងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណួរចុងក្រោយរបស់លោកមេធាវី កូប៉េ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺមានមូលដ្ឋានសមស្រប។ សំណួរនេះមិនពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីសវនាការនេះទេ ដូច្នេះអង្គជំនុំជម្រះមិនត្រូវការស្តាប់នូវចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះចំពោះសំណួរដែលសួរឡើងដោយមេធាវី នួន ជា ចំពោះដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយអម្បាញ់មិញនេះទេ។

អ៊ីចឹងម្តងទៀត អង្គជំនុំជម្រះទទួលយកការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ រួមនឹងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណួរចុងក្រោយរបស់មេធាវីការពារក្តី នួន ជា ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺមានមូលដ្ឋានសមស្រប។ សំណួរនេះ គឺមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំពុងធ្វើសវនាការនេះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនត្រូវការស្តាប់ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសំណួរដែលសួរចុងក្រោយឡើងដោយមេធាវីការពារក្តីលោក នួន ជា គឺ វ៉ិចទ័រ កូប៉េ នោះទេ។

ដើមបណ្តឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ!

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការពិតហើយលោកប្រធាន សំណួរនេះជាសំណួរចុងក្រោយហើយ ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:០៩:២៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំធ្វើការកត់សម្គាល់មួយចំនួន ពាក់ព័ន្ធទៅនឹងសំណើរបស់លោក កូប៉េ នៅពេលព្រឹកនេះ។ ខ្ញុំបានពិនិត្យផ្ទៀងផ្ទាត់ឯកសារ E305/13.23.292 កាលពីព្រឹកមិញនេះ មេធាវីការពារក្ដីលោក កូប៉េ បានបញ្ជាក់ថា បានដាក់ចូលនៅក្នុងហ្សាយឡេប នៅខែមេសា ឆ្នាំ២០១៥។ តាមពិតមិនត្រឹមត្រូវទេ។ បើសិនខ្ញុំអានសេចក្ដីបញ្ជាក់នៅក្នុងហ្សាយឡេបហ្នឹង គឺឯកសារនេះ ត្រូវបាន ដាក់ជូនឲ្យភាគី នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤។ សម្រាប់ជាភស្តុតាងបន្ថែម គឺថាឯកសារនេះ មាន បោះត្រាដែលបញ្ជាក់ថា ត្រូវបានបកប្រែនៅខែមករា ឆ្នាំ២០១៤។ ម្យ៉ាងវិញទៀត ឯកសារនេះ គឺជា ឯកសារដែលត្រូវបានទទួលយកដោយអង្គជំនុំជម្រះហើយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥។ ដូច្នេះ ខ្ញុំ មិនយល់អំពីភាពពាក់ព័ន្ធនៃអន្តរាគមន៍របស់លោកមេធាវីកាលពីព្រឹកមិញនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាវាមិនមានបញ្ហាអ្វីទេ ជាមួយនឹងឯកសារមួយនេះ។ ដូចដែលបានឃើញ គឺមានលេខ E3 ឯកសារនេះមានលេខ E3។ <យើងមានឯកសារហ្នឹងជាភាសាអង់គ្លេស។> អ្វីដែលខ្ញុំចង់និយាយអំពី ឯកសារនេះគឺថា<យោងតាម *ហ្សាយឡេប*>--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី ខ្ញុំសូមអភ័យទោសដែលកាត់ផ្ដាច់លោក ប្រសិនបើមិនមានបញ្ហាអីទេ អ៊ីចឹងព្រឹក មិញ ហេតុអីបានជាលោកសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីប្រើប្រាស់ឯកសារនេះទៅវិញនោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបានស្នើសុំការអនុញ្ញាតប្រើប្រាស់ឯកសារនេះ <ពីព្រោះខ្ញុំបានដាក់បង្ហាញ>ឯកសារនេះ <>នៅលើអ៊ីនធើហ្វេស<កាលពីម្សិលមិញ។ សំណួររបស់ខ្ញុំ គឺអំពីកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌល ឯកសារកម្ពុជាចំនួន៦៥ផ្សេងទៀត ដែលដាក់បង្ហាញនាពេលថ្មីៗនេះ។ យើងបាន>លើកឡើង<ថា-->

[១០:១១:៤៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវីការពារក្តី យើងបានស្តាប់ឮកាលពីព្រឹកមិញហើយថាលោកបានស្នើសុំ ដើម្បីទទួលបានការអនុញ្ញាតប្រើប្រាស់ឯកសារនៅពេលដែលសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះហ្នឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបានធ្វើយ៉ាងដូច្នេះហើយលោកចៅក្រម។ <ប៉ុន្តែខ្ញុំត្រូវបានអនុញ្ញាតឱ្យធ្វើដូច្នេះ ពីព្រោះខ្ញុំបានដាក់ឯកសារហ្នឹងបង្ហាញ>នៅលើអ៊ីនធើហ្វេស<កាលពីម្សិលមិញ>។ បញ្ហាមិនមែនឯកសារនេះទេ គឺឯកសារចំនួន៦៥ ពីមជ្ឈមណ្ឌលឯកសារកម្ពុជាទៅវិញនោះទេ។ ដោយសារឯកសារទាំងនោះ គឺថាមិនមានការបកប្រែទៅជាភាសាអង់គ្លេសទេ។ ខ្ញុំនិយាយឯកសារ៦៥ នេះក៏បានដាក់ចូលនៅក្នុង*ហ្សាយឡូប* ហើយដែរ ហើយក៏មានការកំណត់កាលបរិច្ឆេទគឺខែ -- ចុះថ្ងៃទី១៧ ខែមិថុនា ២០១៥។ ខ្ញុំមិននិយាយអំពីឯកសារមួយនេះ គឺនិយាយឯកសារចំនួន៦៥ ដែលបានទើបតែដាក់បញ្ចូលទៅក្នុង*ហ្សាយឡូប*។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ នៅពេលដែលលោកសួរលើកក្រោយនោះ សូមធ្វើសំណើឱ្យបានច្បាស់ ដើម្បីជាប្រយោជន៍សម្រាប់ភាគីទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ ប្រកាសសម្រាកចាប់ពីពេលតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់រួមទាំងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ បន្តទៅនេះផ្ដល់វេទិការជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរ សែន សុផុន។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំសួរសំណួរខ្លីៗទេ ដើម្បីសុំការបំភ្លឺពីលោក។ កាលពីម្សិលមិញលោកបាននិយាយហើយ ព្រឹកមិញក៏លោកបាន<បញ្ជាក់>ផងដែរ ថាលោកបានធ្វើការនៅទំនប់ត្រពាំងថ្មរយៈពេលពីរខែចាប់ពីខែឧសភា <ឆ្នាំ១៩៧៦>។ អ៊ីចឹងសំណួរខ្ញុំនឹងផ្ដោតតែទៅលើរយៈពេលពីរខែហ្នឹងទេ គឺពីឆ្នាំ៧៦ ពីខែឧសភា ទៅ។ ម្សិលមិញនៅពេលដែលលោកឆ្លើយទៅសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ លោកបាននិយាយថា នៅពេលដែលលោកចេញពីការដ្ឋានទំនប់ត្រពាំងថ្មនុ៎ង គឺការសាងសង់ហ្នឹងជិតចប់ទៅហើយ។ តើលោកដឹងថា <>តើការងារលើកទំនប់នោះចប់នៅពេលណាដែរឲ្យពិតប្រាកដទៅ?

**លោក សែន សុផុន៖**

**ឆ៖** មិនដឹងឲ្យចប់ពេលណាទេ ខ្ញុំអត់ដឹង។ គ្រាន់តែខ្ញុំដឹងថា គ្រាន់តែគេឲ្យខ្ញុំទៅធ្វើហើយភ្លាមក៏គេដកខ្ញុំចេញពីហ្នឹង ទៅធ្វើទំនប់ស្ពានស្រែង។

[១០:៣៣:១៥]

**ស៖** តើលោកដឹងថា គេចាប់ផ្ដើមលើកទំនប់ហ្នឹងនៅពេលណាដែរទេ?

**ឆ៖** ខ្ញុំអត់ដឹងថា គេចាប់ផ្ដើមពេលថ្ងៃណាអី អត់ដឹងទេ។ ប៉ុន្តែគ្រាន់តែដល់ពេលគេហៅខ្ញុំ គេហៅទៅតែម្ដង។

**ស៖** បាទ សំណួរចុងក្រោយទាក់ទងនឹងចំណុចហ្នឹង តើលោកមាន<ឮថា>គេមានសម្ពោធ

ការដ្ឋានទំនប់ហ្នឹងដែរទេ នៅពេលណាមួយ? ទោះបីថាលោកមិនចាំថាថ្ងៃណា ខែណា ដែល<គេ> បញ្ចប់<ការសាងសង់ទំនប់>ក៏ដោយចុះ។

**ឆ៖** គេមិនបានសម្ពោធអីទេ គេគ្រាន់តែប្រជុំធ្វើជាមីទ្ទិង។ ប៉ុន្តែខ្ញុំមិនចាំថ្ងៃ ចាំខែទេ គ្រាន់តែគេហៅធ្វើមីទ្ទិងទៅ លោកធំគេនិយាយទៅ តែប៉ុណ្ណឹងឯង។

**ស៖** អ៊ីចឹងពេលហ្នឹង គឺថានៅពេលចុងបញ្ចប់នៃការលើកទំនប់ហ្នឹងហើយ ឬក៏នៅពេលចាប់ផ្តើមទេ លោកនិយាយពាក្យថា គេធ្វើ "មីទ្ទិង" អម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំទៅយូរដែរ បានប្រហែលចង់បានមួយខែដឹង បានគេចាប់ផ្តើមធ្វើមីទ្ទិង គេបំពាក់បំពានគោលជំហរយើងប៉ុណ្ណោះឯង ឲ្យយើងខំប្រឹងធ្វើការងារទៅ ប៉ុណ្ណឹង។

[១០:៣៥:២០]

**ស៖** អ៊ីចឹងអ្វីដែលលោកនិយាយនេះ លោកនិយាយមិនសំដៅទៅលើការសម្ពោធទេ គឺលោកចង់និយាយថា មានការធ្វើទស្សនកិច្ចមួយនៅលើស្ពាននៃទំនប់ហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** អត់ទេ គេប្រជុំ ប្រជុំទៅ គេមិនមែនសម្ពោធអីកាត់ខ្សែបូ អត់មានដូចសម័យឥឡូវទេ។

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ ខ្ញុំសូមឲ្យលោកជួយបំភ្លឺចំណុចមួយចំនួនទៀត។ លោកបាននិយាយពីប្រភេទការងារដែលលោកបានធ្វើនៅទំនប់ហ្នឹង ឧទាហរណ៍ ដូចជារែកដីជាដើមនោះ។ អ៊ីចឹងតើក្នុងរយៈពេលពីរខែ ដែលលោកធ្វើការនៅទីនោះ គឺលោកធ្វើនៅកន្លែងដដែល កន្លែងតែមួយទេ ឬក៏យ៉ាងណា?

**ឆ៖** កន្លែងតែមួយទេ។

**ស៖** តើលោកអាចពន្យល់ជូនតុលាការបានដែរឬទេថា កន្លែងដែលលោកធ្វើការនោះ ស្ថិតនៅក្នុងឃុំណាដែរ? ហើយពីកន្លែងដែលលោកធ្វើការនោះ លោកអាចមើលឃើញស្ពានមួយដែរឬទេ? គឺជាសំណង់ធ្វើអំពីថ្មតែមួយគត់ គឺថា ស្ពាន ឬក៏ទ្វារទឹកហ្នឹង លោកឃើញទេពីកន្លែងដែលលោកធ្វើការ?

[១០:៣៧:១០]

**ឆ៖** កន្លែងខ្ញុំ កន្លែងគេហៅថា "ស្ពានរាប១"។ ខ្ញុំនៅតែមួយកន្លែងហ្នឹង អត់ដែលបានដើរទៅណាទេ។ គេមិនអាចឲ្យដើរទៅណាទេ គឺថា អ្នក -- កន្លែងយើងកន្លែងណា ឲ្យនៅហ្នឹង អត់មានឲ្យដើរ។

**ស៖** ប៉ុន្តែសំណួរខ្ញុំអម្បាញ់មិញនេះ ថាទីកន្លែងដែលលោករែកដីហ្នឹង១ លោកមានមើលឃើញស្ពានទេ ពីកន្លែងលោកធ្វើការហ្នឹងមើលឃើញអត់ ស្ពានហ្នឹង?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក សែន សុផុន៖**

**ឆ៖** កន្លែងនៅស្ពាន កន្លែងខ្ញុំហ្នឹងឯង គេហៅ “ស្ពានរាបៗ”។

**ស៖** ខ្ញុំសូមសង្កត់ធ្ងន់នោះដែរ ខ្ញុំសូមសួរដដែលទេថា តើពីកន្លែងដែលលោកធ្វើការហ្នឹង លោកមើលឃើញស្ពានទេ?

**ឆ៖** មើលឃើញនៅជិតហ្នឹង ជាប់ហ្នឹង មើលឃើញវាជាប់ គេហៅស្ពានរាបវាជាប់ហ្នឹងឯងមើលឃើញ។

**ស៖** តើលោកដឹងថា ស្ពានហ្នឹងគេហៅថា ស្ពានអីទេ?

**ឆ៖** ខ្ញុំឆ្លល់មេធាវី ខ្ញុំថាស្ពានរាបហ្នឹងហើយ លោកមេធាវីសួរខ្ញុំទៀត ខ្ញុំក៏ឆ្ងល់ដែរនេះ!

**ស៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត ជូនទៅលោកដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងភាគីទាំងអស់។ ថានៅក្នុងឯកសារមួយគឺឯកសារ E3/8050 ដែលជា<របាយការណ៍អំពីការ>កំណត់អត្តសញ្ញាណទីតាំង ដែលមានជាទំព័របារាំងគឺ 00450434, ERN ជាភាសាអង់គ្លេសគឺ 00428005, ជាភាសាខ្មែរគឺ 00464719 មានការបញ្ជាក់ថា ទំនប់នោះមានប្រវែង ១០គីឡូម៉ែត្រ ហើយនិងទទឹង ៧គីឡូម៉ែត្រ។ ក្នុងលក្ខខណ្ឌនេះ សំណួរខ្ញុំមានបំណងកំណត់ទីតាំងថា ទំនប់ដែលលោកធ្វើការៗ ស្ថិតនៅត្រង់ណាពិតប្រាកដ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកផ្តល់សេចក្តីបញ្ជាក់ ហើយនិងចង់ជម្រាបជូនលោកអំពីមូលហេតុដែលខ្ញុំចោទសំណួរទៅកាន់លោកដូចយ៉ាងដូច្នេះ។ លោកបានពន្យល់ថា លោកបានធ្វើការនៅក្នុងកងមួយដែលមាន <៧០>នាក់ ហើយនៅជុំវិញលោកនោះមានកងដែលមានគ្នាប្រហែលជា ១០០នាក់ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថានៅ<ក្នុងតំបន់>ដែលលោកធ្វើការនោះមានកងចំនួនប៉ុន្មានដែរ?

[១០:៤១:១៥]

**ឆ៖** ខ្ញុំអត់យល់ ប៉ុន្តែកន្លែងខ្ញុំមានគ្នាប៉ុណ្ណឹង ប៉ុន្តែមួយបណ្តោយមួយទំនប់ហ្នឹងពេញ វាយគ្នារហូត វាយគ្នាទាំងអស់ ពេញទាំងអស់ មិនដឹងថា ប៉ុនណាៗ មនុស្សរាប់ពាន់នាក់មិនមែនតែ ១០០, ២០០ នាក់ឯណា។

**ស៖** ទាក់ទងទៅនឹងដំណើរការកងនោះ តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថាលោកមិនដឹងថាកងផ្សេងទៀតនោះដំណើរការយ៉ាងណានោះទេ ពីព្រោះថាលោកធ្វើការតែនៅក្នុងកង <ដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានមនុស្សចំនួន៧០> ដែល លោកធ្វើការតែប៉ុណ្ណោះ<> លោកមិនស្គាល់កងផ្សេងទៀតទេ។ អ៊ីចឹងមិនដឹងពីដំណើរការនៃការកងផ្សេងទៀតទេ។ តើខ្ញុំនិយាយអ៊ីចឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវៗ។

**ស៖** អម្បាញ់មិញនៅពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវី កូប៉េ លោកបានឆ្លើយថា ប្រធានកងដែលលោកមិនស្គាល់ឈ្មោះ មិនចាំឈ្មោះទេ គាត់ហ្នឹងដាស់លោកពេលព្រឹក ហើយបើខ្ញុំមិនច្រឡំទេ លោកថាមានជួងមួយសម្រាប់វាយ។ តើជួងហ្នឹងគេប្រើសម្រាប់តែកងលោកទេ ឬក៏គេវាយជួងហ្នឹងសម្រាប់កងដែលស្ថិតនៅជុំវិញ ឬក៏នៅក្បែរកងលោកដែរ?

**ឆ៖** បើតាមខ្ញុំសង្កេតមើល កងខ្ញុំមានជួងមួយ កងគេៗមានជួងម្នាក់មួយៗ ទាំងអស់ ឲ្យតែអ៊ីចឹងមេកងគេចាប់ផ្តើមវាយម៉ឺងៗ ហើយ។

[១០:៤៣:២០]

**ស៖** ហើយជារាល់ រៀងរាល់ថ្ងៃរូបលោកផ្ទាល់ហ្នឹង ក្រៅពីពេលព្រលឹមឡើងហ្នឹងលោកឃើញមេកងលោកហ្នឹង លោកឃើញគាត់ដែរ ឬក៏លោកឃើញតែមេក្រុមដែលឈ្មោះ រ៉ា នោះទេ?

**ឆ៖** មេក្រុមនៅជាប់នៅហ្នឹងខ្លួន តែមេកងគាត់ដើរទៅដើរមក។ ខ្ញុំមិនសូវឃើញជាប់ទេ ជួនកាល ដើរមកមើលហើយទៅបាត់ៗ។

**ស៖** លោកក៏បាននិយាយផងដែរអំពីផែនការដែលគេដាក់ឲ្យធ្វើនៅក្នុងកងរបស់លោកគឺថា ត្រូវរែកដី៣ម៉ែត្រគូបក្នុងម្នាក់មួយថ្ងៃ។ តើលោកអាចជម្រាបជូនបានដែរឬទេ ថាតើអ្នកណាជាអ្នកផ្ទៀងផ្ទាត់អំពីផែនការដែលអ្នកធ្វើការត្រូវបំពេញឲ្យបាននោះ? មេកងរបស់លោក ឬក៏មេក្រុមរបស់លោក <ឈ្មោះ រ៉ា>?

**ឆ៖** មេក្រុមអ្នកផ្ទៀងផ្ទាត់ ហើយប្រាប់មេកង។

**ស៖** តើការផ្ទៀងផ្ទាត់ហ្នឹង គេធ្វើយ៉ាងម៉េចដែរ? តើគេធ្វើយ៉ាងណាដើម្បីឲ្យដឹងថា លោករែកដីបាន ៣ម៉ែត្រគូបបានមួយថ្ងៃ?

**ឆ៖** គេកាច់ឈើវាស់ វាស់ជាម៉ែត្រៗ យកមកដាក់ទឹមស្មើចង្កេះ ស្មើល្មម១ម៉ែត្រហ្នឹងគេស្មានថា ១ម៉ែត្រហើយ គេវាស់ៗហើយ គេឲ្យយើងកាប់។

**ស៖** កាលពីម្សិលមិញ នៅប្រហែលជាម៉ោង១៥:៣៧នាទី លោកបាននិយាយថា ពីដំបូងលោកហូបក្នុងមួយថ្ងៃបីដង ហើយបន្ទាប់មក លោកមានតែបបរខាប់នោះទេ។ ខ្ញុំសុំដកស្រង់៖ "បើសិនជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកមិនបានទទួលអាហារបីដងមួយថ្ងៃនោះ ដោយសារតែអស់អង្ករ"។ អ៊ីចឹង សំណួរខ្ញុំសួរថា ក្នុងរយៈពេលពីរខែដែលលោកធ្វើការនៅទំនប់ហ្នឹង តើលោក<ទទួលបាន>អាហារបី<ដងក្នុងមួយថ្ងៃ>ហ្នឹងរយៈពេល ប៉ុន្មានដែរ?

**ឆ៖** ខ្ញុំអត់ដឹងពាក្យនេះ ខ្ញុំមិនដឹងថាម៉េច? "បីថ្ងៃហូបមួយដង"។

[១០:៤៧:០២]

**ស៖** ខ្ញុំចោទសំណួរឡើងវិញម្តងទៀត។ ម្សិលមិញ សំណួរគេសួរទៅលោកថា "នៅពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង តើលោកហូបប៉ុន្មានដងក្នុងមួយថ្ងៃ? លោកឆ្លើយដូចតទៅនេះ៖ ពីដំបូងគេឱ្យយើងហូបបាយ<>បីដងមួយថ្ងៃ<> ហើយបន្ទាប់មកបានហូបតែបបរខាប់នោះទេ"។ សំណួរបន្ទាប់ទៀតដែលគេសួរទៅលោក៖ "ចុះពេលក្រោយមកហ្នឹង លោកហូបបីដងមួយថ្ងៃដដែល? លោកឆ្លើយថា៖ ទេ អស់អង្ករ <ក្រោយមកទៀត>គេឱ្យយើងហូបបាយតែពេលថ្ងៃត្រង់<> ហើយនិង<ហូបម្តងទៀតនៅពេល>ល្ងាច<ប៉ុណ្ណោះ>"។ អ៊ីចឹង សំណួរខ្ញុំចង់សួរថា តើក្នុងរយៈពេលពីរខែដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង តើចាប់ពីពេលណាទៅ? ឬក៏នៅពេលណាជាក់លាក់តែម្តងដែលលោកលែងបានទទួលអាហារបីដងក្នុងមួយថ្ងៃនោះ?

**ឆ៖** លោកមេធាវីសួរវែងពេក ខ្ញុំមិនដឹងឆ្លើយយ៉ាងម៉េច។

**ស៖** សំណួរខ្ញុំវែងព្រោះថាខ្ញុំរំឭកឱ្យលោកចាំអ្វីដែលលោកនិយាយកាលពីម្សិលមិញ។ ឥឡូវ ខ្ញុំសួររបៀបផ្សេងទៀត។ នៅក្នុងរយៈពេលពីរខែដែលលោកធ្វើការនៅលើទំនប់ត្រពាំងថ្មហ្នឹង ដំបូងលោកបានអាហារហូបបីដងមួយថ្ងៃ បន្ទាប់មកទៀតពីរដងមួយថ្ងៃ។ អ៊ីចឹង ខ្ញុំសួរលោកថាតើពេលដែលលោកបានហូបបីដងមួយថ្ងៃហ្នឹងមានរយៈពេលប៉ុន្មានដែរ?

**ឆ៖** ប្រហែលមួយខែ ដែលបានហូបបាយពេញៗ មួយខែ។ តែចុះមកក្រោយ ចុះមកៗរហូត។

**ស៖** លោកបានឆ្លើយថា"អស់អង្ករ"។ អ៊ីចឹងខ្ញុំចង់ដឹងថា អ្នកណាអ្នកប្រាប់លោកថាអស់អង្ករ? ហើយតើលោកដឹងដែរឬទេថា ស្បៀងដែលគេយកមកធ្វើម្ហូបអាហារឱ្យកងលោកហ្នឹង គេយកមកពីណាដែរ ស្បៀងអាហារហ្នឹង?

[១០:៤៩:៥០]

**ឆ៖** អត់ដឹងយកមកពីណា អត់ដឹង ដឹងតែ ពេលបបរទៅហូបទៅៗ អត់ដឹងអ្នកណាអ្នកយកស្បៀងមក អ្នកណាអ្នកអី អត់ដឹងទេ។ ដឹងតែធ្វើការ គិតតែធ្វើការខ្លួនឯង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អ៊ីចឹងខ្ញុំត្រូវយល់ថាគ្មានអ្នកណាគេពន្យល់ពីមូលហេតុថា គេកាត់បន្ថយរបបអាហារហ្នឹងទេ អ៊ីចឹងមែនទេ គឺថាគ្មានអ្នកណាគេពន្យល់ប្រាប់លោកទេ?

**ឆ៖** មែន គ្មានអ្នកណាពន្យល់ប្រាប់ទេ។

**ស៖** លោកបាននិយាយថាលោកបានចូលរួមប្រជុំមួយ តើនៅពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង មានគេប្រាប់លោកនៅពេលណាមួយនោះអំពីមូលហេតុនៃការលើកទំនប់ហ្នឹងដែរឬទេ?

**ឆ៖** អត់យល់ពាក្យនេះ។

**ស៖** លោកបាននិយាយថាលោកបានចូលរួមប្រជុំយ៉ាងហោចណាស់ក៏ចូលប្រជុំម្តងដែរ។ តើនៅក្នុងពេលប្រជុំនោះ ឬក៏ពេលប្រជុំផ្សេងមួយទៀតនោះ មានគេពន្យល់ប្រាប់លោកអំពីមូលហេតុ ឬក៏ថាគេប្រាប់លោកថា ហេតុអ្វីបានជាគេលើកទំនប់ <នៅកន្លែង>ហ្នឹងដែរឬទេ? លើក ឬក៏លើកទំនប់ហ្នឹងដើម្បីបំណងអ្វីមួយដែរឬទេ?

**ឆ៖** អត់មានទេ អត់មានពន្យល់ពីហ្នឹង។ គេប្រជុំហ្នឹងសម្រាប់តែឲ្យខំសម្រុកក្នុងការងារគេប៉ុណ្ណឹង អត់មានពន្យល់ពីហេតុផលលើកម៉េច អីម៉េចអត់មានទេ។

[១០:៥២:១៥]

**ស៖** តើលោកមានដឹងដែរឬទេ ថាតើទំនប់នៅតែបន្ត<ប្រើប្រាស់>ក្រោយឆ្នាំ១៩៧៩ដែរឬទេ?

**ឆ៖** អត់យល់ន័យពាក្យហ្នឹង។

**ស៖** តើក្រោយឆ្នាំ១៩៧៩ ហ្នឹង ទំនប់ហ្នឹងនៅតែមានគេប្រើដើម្បីស្រោចស្រពដំណាំដែរឬទេ ឬក៏ដើម្បីស្រោចស្រពស្រែស្រូវអីជាដើមនោះ លោកមានដឹងទេ?

**ឆ៖** សូមមេធាវីសួរសាថ្មីម្តងទៀត ខ្ញុំអត់យល់។

**ស៖** អត់បញ្ហាអីទេ។ ខ្ញុំសួរលោកថាតើទំនប់ហ្នឹងនៅក្រោយឆ្នាំ១៩៧៩ នៅតែមានគេប្រើដើម្បីប្រកបរបរកសិកម្មដែរឬទេនៅតំបន់ហ្នឹង?

**ឆ៖** ខ្ញុំអត់ដឹងដែរព្រោះអីខ្ញុំមិនបានទៅដល់ តាំងពីនេះមកខ្ញុំអត់ដែលបានទៅដល់សោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយៗសហវិតារបស់ខ្ញុំលោក គង់ សំអុន គាត់មានសំណួរបន្តិចបន្តួចដើម្បីសួរបន្ថែមលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

[១០:៥៤:០៨]

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក សែន សុផុន! ខ្ញុំចង់សួរបញ្ជាក់លោកបន្តិចទាក់ទងនឹងចម្លើយរបស់លោកកាលពីព្រឹកមិញផងដែរ លោកបញ្ជាក់ថា លោកបានដឹងពី យាយថែម ជាអ្នកបញ្ជាឲ្យមានការសម្លាប់ឪពុករបស់លោក។ ខ្ញុំចង់សួរថាលោកស្គាល់ យាយថែម ហ្នឹងដែរទេពីមុនមក ជាពិសេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក សែន សុផុន៖**

**ឆ៖** ខ្ញុំអត់ស្គាល់ យាយថែម ផង ឮតែឈ្មោះ យាយថែមៗ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងពេលវេលាដែលលោកបានឆ្លើយជាមួយលោកមេធាវី កូប៉េ មុននេះថាឪពុករបស់លោកប្រហែលជាស្លាប់នៅចុងឆ្នាំ៧៧ ឬក៏ដើមឆ្នាំ៧៨ ហើយក្រោយមកលោកបានឆ្លើយថា ក្នុងកាលៈទេសៈមួយ គឺមានទឹកជំនន់ឆ្នាំ១៩៧៨ នៅពេលនោះ ដែលយាយទ្រព្យ បាននិយាយប្រាប់លោក ក្រោយពីរត់ទឹកជំនន់នោះ គេចភៀសខ្លួនពីទឹកជំនន់នោះ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើពេលវេលាណាជាក់លាក់ លោកបញ្ជាក់បានទេថា ឪពុករបស់លោកស្លាប់នៅក្រោយពេលឆ្នាំមួយពាន់ -- ទឹកជំនន់ឆ្នាំ១៩៧៨ ឬក៏ចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ៧៨?

**ឆ៖** អានេះ ខ្ញុំក៏ស្មានៗដែរ។ ខ្ញុំមិនដឹងថា ដើមឆ្នាំ ឬចុងឆ្នាំទេ ដែលគាត់ស្លាប់ហ្នឹង។ ប៉ុន្តែអ៊ីចេះ ខ្ញុំដឹងថា ចាំតែពេលខែទឹក គឺខែវស្សា ពេលខែអស់ទឹកទៅ គឺខែប្រាំង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា កាលៈទេសៈដែលច្បាស់លាស់សម្រាប់លោក គឺនៅពេលទឹកជំនន់ នៅពេលមានទឹកជំនន់។ អ៊ីចឹងមានន័យថា ជាខែវស្សានៃឆ្នាំ១៩៧៨។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ។

[១០:៥៧:០០]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា យាយទ្រព្យ ដែលជម្រាបលោកហ្នឹង ជាពេលវេលា

មួយ នៅពេលទឹកជំនន់ហ្នឹងកំពុងតែឡើង ឬក៏ពេលក្រោយទឹកជំនន់ហើយ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ទឹកស្រកអស់ហើយ ពេលហ្នឹងទឹកស្រកអស់ទឹកហើយ។

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំសូមឲ្យលោកបញ្ជាក់ គឺតាមភូមិសាស្ត្រនៅស្រុកខ្មែរយើង រដូវវស្សា ជាពិសេសនៅពេលដែលមានទឹកជំនន់ ទឹកទន្លេឡើង គឺនៅក្នុងអំឡុងពេលនៃរដូវភ្ជុំបិណ្ឌ ហើយជាក្នុងខែ៩ ទៅខែ១០។ តើលោកយល់ស្របតាមខ្ញុំអ៊ីចឹងទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា កាលៈទេសៈដែលយាយទ្រព្យ បានជម្រាបលោក ថា ឪពុករបស់លោកត្រូវគេចាប់យកទៅហ្នឹង អាចនៅក្នុងខែ៩ ឬខែ១០ នៃឆ្នាំ១៩៧៨ មិនមែនដើមឆ្នាំ ១៩៧៨ ឬក៏ចុងឆ្នាំ៧៧ នោះទេ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ប្រហែលជាពាក់កណ្ដាលឆ្នាំហ្នឹងឯង បាទ ពេលទឹកឡើងលិចហ្នឹង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងទំនប់ លោកបានបញ្ជាក់អំពីការវាស់ដីឲ្យធ្វើការពីមេកង របស់លោក ក្នុងអំឡុងពេលពីរខែ ដែលលោកបានទៅធ្វើការនៅទំនប់ត្រពាំងថ្ម។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ អំពីការបែងចែកការងារជាក់ស្ដែង តើគេបែងចែកការងារតាមក្រុម ឬក៏ធ្វើជាកងរួម ឬក៏ធ្វើជាបុគ្គល ម្នាក់ៗ លោកអាចបញ្ជាក់បានទេ?

**ឆ៖** កន្លែងខ្ញុំធ្វើក្រុម មួយក្រុម ធ្វើមួយក្រុម។

[១១:០០:០២]

**ស៖** លោកអាចបញ្ជាក់ចំនួនសមាជិកក្នុងក្រុមរបស់លោកមានប៉ុន្មាននាក់ ដែលធ្វើការជាក្រុម?

**ឆ៖** ក្រុមខ្ញុំ១០នាក់ មួយក្រុម១០នាក់។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់រួចហើយអំពីទំហំការងារដែលលោកថា ក្នុងក្រុម របស់លោកធ្វើ (សូមទោស) ក្នុងម្នាក់សម្រាប់លោក គឺ៣ម៉ែត្រគូប ដែលគេឲ្យជីកដីដាក់ទំនប់។ អ៊ីចឹងខ្ញុំ ចង់សួរបញ្ជាក់ថា តើការងារដែលធ្វើជាក្រុម ក្នុងក្រុម ដែលលោកបញ្ជាក់ពីដើមថា លោកជាទូទៅ លោកបានធ្វើមិនហើយទេការងារដែលគេកំណត់ឲ្យធ្វើនោះ ហើយលោកត្រូវចំណាយធ្វើពេលយប់ ទៀត។ អ៊ីចឹងតើការងារហ្នឹងត្រូវធ្វើជាក្រុមទាំងអស់គ្នា ឬមួយក៏មានតែលោកម្នាក់ទេដែលធ្វើការនៅ ពេលយប់?

**ឆ៖** ក្រុមខ្ញុំទាំងអស់គ្នា ក៏មិនបានឡើង ធ្វើទាំងអស់គ្នាមិនថាក្រុមខ្ញុំ ឬក្រុមផ្សេងៗដទៃទេ នៅ

ទាំងអស់គ្នារហូតទាល់តែដល់ម៉ោងដប់យប់ ទម្រាំគេហៅទៅចូលបានហើយ។ វាអត់មាននរណាហើយទេ ទាំងអស់ មករហូតមកបណ្ដោយទំនប់ អត់មានឃើញហើយទេ។

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីទំហំនៃការវាស់ដីប្រគល់ឱ្យក្នុងក្រុមរបស់លោកប្រចាំថ្ងៃ គេវាស់បែបម៉េច? ហើយទំហំប៉ុន្មានដែរលោកអាចបញ្ជាក់បានទេ?

**ផៈ** ដីហ្នឹងវាធំមែន ៣ម៉ែត្រ ១០ដង វា៣០។ មើលឃើញធំ នាំគ្នាគ្រាន់តែវាស់ហើយ អង្គុយអស់កម្លាំងដូចគ្នា នរណាកាប់ៗទៅ នរណារែកៗទៅ នរណាកាយដាក់បង្គីក៏កាយទៅ។ តែម្នាក់ៗនៅក្នុងក្រុមទាំងអស់ហ្នឹងគឺថា អស់ បាក់ទឹកចិត្តអស់ហើយ ដែលធ្វើមិនហើយច្បាស់ជាអត់បាយរហូតហ្នឹងឯង។

[១១:០២:២៦]

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ឱ្យច្បាស់ថែមទៀតបានទេ អំមិញនេះលោកថា ៣ម៉ែត្រ ១០ដង ៣០ ហើយឃើញធំនេះ លោកអាចបញ្ជាក់ពីការកំណត់ជាក់ស្ដែង ក្នុងការវាស់វែងហ្នឹងថាវាទទឹងយ៉ាងម៉េច បណ្ដោយយ៉ាងម៉េច ជម្រៅយ៉ាងម៉េចបានទេ?

**ផៈ** គេឱ្យវាស់ទៅអ៊ីចឹង ៣០មកអ៊ីចឹងៗ ៣០ចុះ ជម្រៅចុះក្រោមកន្លះម៉ែត្រ គេឱ្យកាប់។

**សៈ** តាមការរៀបរាប់របស់លោកហ្នឹងមានន័យថា ជ្រុងនីមួយៗ៣០ ហើយជម្រៅចុះក្រោមកន្លះម៉ែត្រ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ផៈ** បាទ ត្រឹមត្រូវ។

**សៈ** ខ្ញុំចង់បញ្ជាក់ឡើងវិញ គឺថាជ្រុង៣០ហ្នឹង គឺបានន័យថាជ្រុងបួន ៣០ មានប្រវែង៣០ម៉ែត្រ ជ្រុងនីមួយៗ ហើយជម្រៅកន្លះម៉ែត្រ។ តើអ៊ីចឹងមែនទេ?

**ផៈ** បាទ មែន។

**សៈ** បាទ សូមអរគុណ។ ចុះសម្រាប់ក្នុងទំហំនេះ ដែលលោកថាជ្រុងនីមួយៗ ៣០ ជម្រៅកន្លះម៉ែត្រនេះលោកធ្វើការសម្រាប់រយៈពេលប៉ុន្មានក្នុងក្រុមរបស់លោក? សូមបញ្ជាក់ គឺក្នុងក្រុម១០នាក់របស់លោក។

**ផៈ** ខ្ញុំអត់យល់ផង។

**សៈ** បាទ ខ្ញុំសួរបញ្ជាក់ឡើងវិញ។ នៅក្នុងទំហំការងារដែលគេវាស់ឱ្យលោកគឺ ១០ ក្នុងចំណោមសមាជិក ១០នាក់ហ្នឹង គឺមានផ្ទៃដី ជ្រុងនីមួយៗ ៣០ម៉ែត្រ ហើយជម្រៅកន្លះម៉ែត្រ។ ខ្ញុំចង់សួរ

ថា នៅក្នុងទំហំហ្នឹង តើគេតម្រូវឱ្យលោកធ្វើការជីកក្នុងរយៈពេលប៉ុន្មាន?

**ឆ៖** ក្នុងរយៈពេលមួយថ្ងៃ។

[១១:០៥:៤៣]

**ស៖** អ៊ីចឹងត្រឹមត្រូវហើយ លោកបញ្ជាក់មិញថា ក្នុងរយៈពេលមួយថ្ងៃ។ លោកអាចគណនាពីទំហំជាម៉ែត្រគូបបានទេសម្រាប់ជ្រុងនីមួយ ៣០ម៉ែត្របួនជ្រុង ហើយជម្រៅកន្លះម៉ែត្រនេះមានផ្ទៃដីប៉ុន្មានម៉ែត្រគូបដែរ?

**ឆ៖** ហ៊ឺះ! អាហ្នឹងគេដឹងហើយ ប៉ុន្តែគ្រាន់តែហៅថាធ្វើម៉េចកាប់ឲ្យហើយអាហ្នឹងសិន។ ប្រសិនកាប់ឲ្យហើយលើសហ្នឹង ឲ្យកាប់បន្តទៅទៀតធ្វើម៉េចឲ្យគ្រប់ទាំងៗអស់គ្នាហ្នឹងឲ្យគ្រប់ម៉ែត្រគូប ម្នាក់៣ម៉ែត្រគូប។ ប៉ុន្តែអាហ្នឹងធ្វើមិនហើយផង អាជ្រុង បីជ្រុង បួនជ្រុង អំមិញធ្វើមិនហើយផងណា នាំគ្នានៅដេកដល់ម៉ោងដប់ម៉ោងអីណោះ។

**ស៖** អំមិញខ្ញុំសួរពីៗចំនួនម៉ែត្រគូប ខ្ញុំអត់បានសួរពីការងារហើយ ឬមិនហើយទេ។ ខ្ញុំចង់ឲ្យលោកគណនាប្រសិនជាលោកអាចគណនាបាន តែបើលោកមិនអាចគណនាបានទេ ហ្នឹងខ្ញុំក៏អត់សួរដែរបាទ។ បាទ សំណួររបស់ខ្ញុំថា លោកអាចគណនាបានទេ?

**ឆ៖** អ៊ូ! អាហ្នឹងវា បើគិតទៅវាមិនពេញម្នាក់ ៣ម៉ែត្រគូបទេ។ ខ្ញុំគ្រាន់តែគិតថា មិនពេញម្នាក់៣ម៉ែត្រគូបទេ ទាល់តែអ៊ីចឹងពីរដងចុះទៅក្រោម ១ម៉ែត្រ បានៗៗពេញ ៣ម៉ែត្រគូបម្នាក់។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក ផុន។ លោកប្រធានខ្ញុំអស់សំណួរហើយបាទ។

[១១:០៧:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក សែន សុផុន ជាចុងក្រោយនេះ លោកអាចថ្លែងរៀបរាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលធ្វើឲ្យប៉ះពាល់ចំពោះលោកក្នុងអំឡុងរបបកម្ពុជាប្រជាធិប-តេយ្យ ដែលនាំឲ្យលោកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ ពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកជាអាទិ៍ គឺការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតឡើងពិតប្រាកដរហូត

ដល់ពេលបច្ចុប្បន្ននេះ ប្រសិនជាលោកមានបំណង់ធ្វើដូច្នេះ។

សូមអញ្ជើញបាទ!

[១១:០៨:៣៥]

**លោក សែន សុផុន៖**

តាំងតែឆ្នាំ១៩៧៥ ដែលខ្ញុំធ្វើឲ្យខ្ញុំជម្លៀសចេញពីទីក្រុងភ្នំពេញនោះមក ដូចថាមានការវេទនាលំបាកគ្រប់បែបយ៉ាង រហូតទៅដល់ព្រែកវាំង១ រហូតទៅដល់បាត់ដំបង បាយហូបមិនគ្រប់ អ្វីៗក៏ត្រូវខ្វះគ្រប់សព្វ សម្លៀកបំពាក់ក៏គ្មាន។ នេះហើយធ្វើបាបរូបខ្ញុំនិងក្រុមគ្រួសារខ្ញុំ និងញាតិសន្តានយ៉ាងខ្លាំង។ ហេតុដូច្នេះ ដល់រហូតដល់មក៧៧ទៀត ឲ្យហូបបាយមិនគ្រប់គ្រាន់ បបរមួយវែក១រហូត។ ធ្វើឲ្យខ្ញុំនេះបាក់ទឹកចិត្ត អត់មានអ្វីជាទីពឹង ឪពុកម្ដាយក៏ស្លាប់អស់ ប្អូនក៏ស្លាប់អស់។ ធ្វើឲ្យផ្ទះសម្បែងខ្ញុំគ្មាននៅ។

**ប្រធានអង្គជំនុំ៖**

លោក សុភារិទ្ធ ជួយសម្រួលគាត់បន្តិចទៅ ហើយឲ្យគាត់ពីរបីមីនុតសិនទៅ ឲ្យបានស្រួលសិនណាសឹមបន្តទៀតណ៎ា។

**លោក សែន សុផុន៖**

ធ្វើឲ្យខ្ញុំរស់នៅដូចកូនអនាថា គ្មានម៉ែឪបងប្អូន គ្មានញាតិសន្តាន សម្លាប់អស់គ្មានសល់។មិនដឹងរកអីទីពឹង អត់មានអីទីពឹងសោះ រហូតមកដល់សព្វថ្ងៃនេះ។ មានតែការវេទនាធ្វើបាប មិនថា រូបខ្ញុំ ឬបងប្អូនទាំងអស់ក្នុងប្រទេសកម្ពុជាទេ ទាំងអស់គ្នា គ្មានអ្នកណាដែលរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងទេ។ ការណ៍ខ្ញុំនិយាយនេះ គឺជាការពិតទាំងអស់។ ខ្ញុំធ្លាប់នៅជួបប្រទះនៅក្នុងហ្នឹង ទាំងអស់។ ហេតុដូច្នេះ ទុក្ខវេទនារបស់ខ្ញុំនេះ ខ្ញុំសូមឲ្យតុលាការជួយវិនិច្ឆ័យឲ្យខ្ញុំចុះ តើទង្វើនេះ គាត់ ធ្វើហ្នឹង តើសមស្របហ្នឹងប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងរូបខ្ញុំដែរឬទេ? ហេតុដូច្នេះ រូបខ្ញុំនេះ ចង់ឲ្យលោកតុលាការផ្ដន្ទាទោសគាត់ ដាក់ទោសគាត់អស់មួយជីវិត។ ខ្ញុំសូមអស់យោបល់ហើយ។

[១១:១២:៤០]

**ប្រធានអង្គជំនុំ៖**

មានអីដែលលោកចង់និយាយទៀតដែរឬទេ?

**លោក សែន សុផុន៖**

ខ្ញុំចង់សុំសួរលោក នួន ជា ពីរសំណួរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសួរ ប៉ុន្តែលោកតាំងសំណួរតាមរយៈយើងជាប្រធានអង្គជំនុំជម្រះណា៎ះ!

**លោក សែន សុផុន៖**

បាទ សូមលោកតុលាការជួយប្រាប់សំណួរនេះទៅដល់ចុងចោទផង។ ខ្ញុំសូមសួរថា ឲ្យប្រជាពលរដ្ឋចេញពីទីក្រុងភ្នំពេញនេះ ហើយថាឲ្យចូលទៅវិញ ក្នុងរយៈ៣ថ្ងៃឲ្យចូលទៅវិញ ផ្ទុយទៅវិញអត់។ ទីពីរ ឲ្យខ្ញុំជម្លៀសចេញពីព្រៃកវាំងនេះ ប្រាប់ថា ឲ្យចូលមកក្នុងទីក្រុងភ្នំពេញវិញ ប៉ុន្តែមកដល់ទីក្រុងភ្នំពេញ គាត់គ្មានយកខ្ញុំចូលក្នុងទីក្រុងភ្នំពេញផង ឲ្យខ្ញុំមកនៅខេត្តបាត់ដំបង។ ពាក្យទាំងពីរនេះហើយគឺថា ពាក្យកុហកបោកប្រាស់របស់របបខ្មែរក្រហម និងរបបអ្នកដឹកនាំហ្នឹងឯង។ តើពាក្យទាំងពីរនេះ អ្នកណាជាអ្នកបញ្ជាមកឲ្យធ្វើយ៉ាងនេះ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក សែន សុផុន។ អង្គជំនុំជម្រះសូមជម្រាបលោកថា នៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ កន្លងទៅបន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់នូវចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ឆ្លើយបញ្ជាក់ ដែលពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ អង្គជំនុំជម្រះក៏បានធ្វើការកត់សម្គាល់ថា ជនជាប់ចោទទាំងពីររូបនៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលព័ត៌មានជាក់លាក់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្តីឲ្យជនជាប់ចោទ។

នៅក្នុងសវនាការថ្ងៃនោះអង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និង ឬមេធាវីការពារក្តីជនជាប់ចោទ ត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពប្រសិនបើជនជាប់ចោទបានសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមមកឆ្លើយតបទៅនឹងសំណួរដោយអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធទៅនឹងដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។ ក៏ប៉ុន្តែរហូតដល់ពេលនេះអង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបមកជាការយល់ព្រមឆ្លើយតបនឹងសំណួររបស់ចៅក្រមនៃអង្គជំនុំជម្រះ ឬក៏របស់ភាគីនៅឡើយទេ។ សូមលោកជ្រាប។

[១១:១៥:៤៩]

ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានចប់ហើយ ហើយសវនាការបន្តនូវរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-858។ សូមភាគីជ្រាប។

អង្គជំនុំជម្រះសូមអរគុណ លោក សែន សុផុន សវនាការស្តាប់សក្ខីកម្ម និងថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលលោកអះអាងថាបានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានដល់ទីបញ្ចប់ហើយ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយលោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ ហើយនិងវិលដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព ហើយអង្គជំនុំជម្រះក៏សូមអរគុណ លោក ជួង សុភារិទ្ធ បុគ្គលិកអង្គការ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដែលបានជួយសម្របសម្រួលអារម្មណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលស្តាប់សក្ខីកម្មព្រឹកនេះ ហើយលោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក សែន សុផុន វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ។

*(សវនាការសម្រាកពីម៉ោង ១១:១៧ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៥:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះគឺ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-858។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្ដីលោកសាក្សី! តើលោកឈ្មោះអី?

**លោក ម៉ម សឿម៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ម៉ម សឿម។

**ស៖** បាទ អរគុណលោក ម៉ម សឿម។ ហើយនៅក្នុងឯកសារកាលពីមាននៅក្នុងសំណុំរឿងគឺមិនមានឈ្មោះ ម៉ម សឿម ទេ។ មានឈ្មោះ ហេង សាម្ឃួត។ ចុះ ហេង សាម្ឃួត ហ្នឹងអ្នកណាគេ?

**ឆ៖** រូបតែមួយ តែឈ្មោះពីរបាទ។

**ស៖** ឥឡូវនេះ លោកប្រើប្រាស់ឈ្មោះផ្លូវការ ឈ្មោះអីគេពិតប្រាកដ?

**ឆ៖** បាទ ផ្លូវការឈ្មោះ ម៉ម សឿម។

**ស៖** ចុះឈ្មោះ ហេង សាម្ឃួត នេះលោកប្រើប្រាស់នៅពេលណា? ហេតុអីបានជាពីមុនមកលោកឆ្លើយថា លោកឈ្មោះ ហេង សាម្ឃួត ដោយមិនមានឈ្មោះក្រៅ ឬក៏ឈ្មោះទី២របស់លោកថាឈ្មោះ ម៉ម សឿម ទេ?

**ឆ៖** បាទ អឺចេះ ខ្ញុំជម្រាប ព្រោះកាលពី កាលខ្ញុំមិនទាន់បានធ្វើការ នៅពេលនោះ ខ្ញុំបានយកឈ្មោះខ្ញុំ ហេង សាម្ឃួត។ ដល់ពេលខ្ញុំចូលធ្វើការ ខ្ញុំដាក់ដឹម៉ងទៅ ដល់ពេលឈ្មោះខ្ញុំបញ្ជូនទៅក្រុងលល់អង្គភាពខ្ញុំគេបានបញ្ជូនខ្ញុំជំនួសឈ្មោះគេ។ ដូច្នេះ បានន័យថាខ្ញុំប្រើឈ្មោះគេតែម្ដង។ ដូច្នេះ ហេង សាម្ឃួត អត់បាននេះទេ គេទទួលស្គាល់តែ ម៉ម សឿម បាទ។

[១៣:៣៩:១៤]

**ស៖** ឈ្មោះកំណើតរបស់លោក ឈ្មោះអីគេ?

**ឆ៖** ឈ្មោះកំណើតរបស់ខ្ញុំបាទ ឈ្មោះ ហេង សាម្ឃួត។

**ស៖** ហើយលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៥៦។

**ស៖** ហើយទីកន្លែងកំណើតរបស់លោក លោកកើតនៅទីកន្លែងណា?

**ឆ៖** ទីកន្លែងខ្ញុំបាទកើតនៅភូមិថ្មីខាងត្បូង ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង សព្វថ្ងៃនៅខេត្តបន្ទាយមានជ័យ។

**ស៖** ចុះទីលំនៅបច្ចុប្បន្នរបស់លោកៗរស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅខ្ញុំបាទបច្ចុប្បន្ន គឺនៅភូមិថ្មីខាងត្បូង ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

**ស៖** លោកប្រកបមុខរបរធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** ឥឡូវខ្ញុំបាទ ប្រកបមុខរបរសព្វថ្ងៃ អត់មានមុខរបរអីទេ ធ្វើស្រែចម្ការ។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកម្ដាយខ្ញុំ -- ឪពុកខ្ញុំឈ្មោះ អ៊ុយ សាមឿន ស្លាប់ហើយ។ ម្ដាយ ជិន យ៉ាន ក៏ស្លាប់ដែរ។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំបាទមានកូនបួននាក់។ ហើយប្រពន្ធឈ្មោះ ស៊ីម ឡុន។

**ស៖** ឥឡូវហ្នឹងចំពោះមុខអង្គជំនុំជម្រះហ្នឹង លោកប្រើឈ្មោះអីពិតប្រាកដដើម្បីអង្គជំនុំជម្រះកំណត់អត្តសញ្ញាណលោកឲ្យបានច្បាស់លាស់ សំខាន់គឺឈ្មោះហ្នឹងទី១ដើម្បីឲ្យច្បាស់លាស់។ តើលោកសម្រេចប្រើឈ្មោះអី ពីព្រោះឯកសារ ទៅជាដល់អ៊ីចឹងវាមានឈ្មោះពីរវាខុសគ្នា មិនមែនឈ្មោះហៅក្រៅទេឥឡូវនេះ។

**ឆ៖** បាទ ឥឡូវគេទទួលស្គាល់ខ្ញុំបាទក្នុងឈ្មោះបញ្ជីគឺ ម៉ម សឿម តែម្ដង ព្រោះខ្ញុំធ្វើការវាដាក់គេដាក់ ម៉ម សឿម ហើយ ឈ្មោះៗ ម៉ម សឿម។

**ស៖** ហើយលោក ម៉ម សឿម ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ ថាតាមសមត្ថភាពដែលលោកអាចដឹង និងថាលោកមិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដី០០២ នេះទេ។ តើពិតមែនដែរទេ?

**ឆ៖** បាទ មិនមានអីទេ ខ្ញុំពាក់ព័ន្ធ មិនស្គាល់ឈ្មោះ។

**ស៖** ហើយថាលោកបានស្បថរួចហើយ មុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ តើពិតមែនដែរទេ?

**ឆ៖** បាទ ខ្ញុំបានចូលស្បថរួចហើយ។

[១៣:៤៣:៣២]

**ស៖** លោក ម៉ម សឿម នៅក្នុងនាមលោកជាសាក្សី នៅក្នុងកិច្ចដំណើរនីតិវិធីសវនាការចំពោះ

មុខអង្គជំនុំជម្រះ លោកអាចបដិសេធក្នុងការឆ្លើយនឹងសំណួរ ឬការសុំឱ្យលោកធ្វើអត្ថាធិប្បាយដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនប្រឆាំងធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ករណីយកិច្ចក្នុងនាមលោកជាសាក្សី ត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឱ្យការឆ្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នៅព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោក ម៉ម សឿម តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក ហើយប្រសិនបើមានធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? នៅពេលណា? លោកចាំដែរទេ?

**ឆ៖** បាទ ខ្ញុំបានធ្វើនៅផ្ទះរបស់ខ្ញុំនៅភូមិថ្មី ឃុំណាំតៅ ស្រុកភ្នំស្រុក នៅឆ្នាំ២០០៩ ខែមករា។

**ស៖** លោក នៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុននោះ ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំអានដែរ ក៏វាដូចភ្លេចនិយាយទៅភ្លេចមុខ ភ្លេចក្រោយ មិនសូវបានច្បាស់លាស់ទេ។

[១៣:៤៥:៣៩]

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹងបានហ្នឹង តើលោកអាចបញ្ជាក់បានដែរឬទេ ថាកំណត់ហេតុដែលលោកបានអានដើម្បីរំឭកការចងចាំ គឺពិតជាត្រឹមត្រូវ ឬសមស្របស៊ីចង្វាក់គ្នាទៅនឹងកិច្ចសម្ភាសន៍ដែលលោកបានធ្វើជាមួយអ្នកស៊ើបអង្កេតកាលពីពេលមុន នៅនឹងផ្ទះរបស់លោកដែរឬទេ?

**ឆ៖** បាទ ឥឡូវនៅនេះខ្ញុំសូម នៅពេលដែលខ្ញុំបានសម្ភាសជាមួយក្រុមដែលចុះទៅ ខ្ញុំបាននិយាយជាមួយ តែមានចំណុចខ្លះក៏មិនទាន់បានច្បាស់លាស់នោះដែរ ព្រោះការនិយាយទៅហើយ វាមានការខុស។ ដូច្នេះ ខ្ញុំសូមលើកយកចំណុចខ្លះៗមកជូនអង្គប្រជុំ ព្រោះកាលសម័យ គិតទៅឆ្នាំ១៩៧៥ គឺថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥--

**ស៖** យើងៗអត់ទាន់ចង់ដឹងអ៊ីចឹងទេ យើងចង់ដឹងគ្រាន់តែខ្លឹមសារ និងទម្រង់នៃកំណត់ហេតុដែលលោកបានអានមុននេះ ដើម្បីរំឭកការចងចាំអំពីអ្វីដែលលោកបានឆ្លើយពីពេលមុន វាសមស្រប វា

ដូចគ្នា ឬក៏វាប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់ ឬក៏ទៅនឹងចម្លើយរបស់លោក ដែលបានឆ្លើយតបជាមួយអ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៩ នៅនឹងផ្ទះរបស់លោកនោះដែរឬទេ? យើងអត់ទាន់សួរលម្អិតទេ រឿងលម្អិតភាគីគេនឹងសួរនាពេលក្រោយ។

**ឆ៖** បាទ ដែលគាត់ចុះទៅ ខ្ញុំ សំណុំរឿងដែលបាននិយាយហ្នឹងគឺបាន ដូចថាខ្ញុំបាននិយាយជាមួយ ហើយនៅពេលដែលគាត់បាននិយាយសួរខ្ញុំ ខ្ញុំក៏បានឆ្លើយត្រឹមត្រូវជាមួយនឹងសំណួរនោះ។

**ស៖** អំមិញនោះ មុន ពីព្រឹកមករហូតដល់ពេលនេះ លោកបានអានទេ អានឯកសារហ្នឹងទេ? អានឡើងវិញទេ?

[១៣:៤៧:៥០]

**ឆ៖** អានដែរ ក៏ប៉ុន្តែដូចថាចាំអត់បាន។

**ស៖** លោកចាំដែរទេថា អង្កាល់ពីគេសួរលោកនៅឆ្នាំ២០០៩ នៅផ្ទះរបស់លោកហ្នឹង តើលោកប្រើឈ្មោះអី?

**ឆ៖** ខ្ញុំបាទប្រើ ដាក់ ខ្ញុំដាក់ឈ្មោះ ហេង សាម្បួត។

**ស៖** ក្នុងរយៈពេលមិនយូរផង ម៉េចក៏លោកប្រើខុសគ្នា ហើយកាលនោះ ហេតុអ្វីលោកមិនប្រើឈ្មោះ ម៉ម សឿម លោកបែរជាប្រើឈ្មោះ ហេង សាម្បួត ហើយដល់ពេលមកចំពោះមុខនាពេលនេះ លោកថាខ្លួនលោកឈ្មោះ ម៉ម សឿម មានហេតុផលយ៉ាងម៉េចទៅ?

**ឆ៖** ខ្ញុំអត់បានគិតថា ខ្លួនខ្ញុំនៅពេលដែលគេចុះសម្ភាស មិនបានគិតដល់ថា រឿងនេះវាជារឿងមួយដែលថាសម្រាប់គេយកមកជាផ្លូវការនោះទេ និយាយត្រង់។

**ប្រធានអង្គជំនុំ៖**

បាទ ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃ គឺពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកចៅក្រម ជម្រាបសួរសហការីទាំងអស់។

[១៣:៤៩:៥៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ជម្រាបសួរលោក ម៉ម សឿម ខ្ញុំគឺជាតំណាងការិយាល័យសហព្រះរាជអាជ្ញា មានសំណួរមួយចំនួនសួរទៅកាន់លោកនៅរសៀលនេះ។ នៅក្នុងចម្លើយរបស់លោក លោកបាននិយាយពាក់ព័ន្ធទៅនឹងចំណុចមួយចំនួន ក៏ប៉ុន្តែពេលនេះ ខ្ញុំសូមសួរលោកពាក់ព័ន្ធបទពិសោធន៍លោកនៅឯការដ្ឋានទំនប់ត្រពាំងថ្ម។ ដូច្នេះ តាមការដែលលោកចងចាំល្អបំផុត ដែលអាចចាំទៅបាននោះ តើ<នៅពេលណាដែលគេបញ្ជូនលោកទៅ>ធ្វើការនៅឯការដ្ឋានទំនប់ត្រពាំងថ្មដែរទេ?

**លោក ម៉ម សឿម៖**

**ឆ៖** បាទ គឺនៅអាងត្រពាំងថ្ម នៅខាងកើតអាងត្រពាំថ្ម ខ្ញុំបាទចុះប្រឡូកបាទ បានធ្វើ បានលើកទំនប់ ហើយនិងលើកស្ពាននៅក្នុងអាងត្រពាំងថ្មតែម្តង។

**ស៖** នៅពេលដែលលោកទៅដល់ការដ្ឋានទំនប់ត្រពាំងថ្មដំបូង តើទំនប់នោះបានចាប់ផ្តើមខ្លះៗហើយឬនៅ?

**ឆ៖** ខ្ញុំបាទបានចូលប្រឡូកនៅក្នុងការដ្ឋានឆ្នាំកាលនោះ គឺខ្ញុំបាទបានចូលប្រឡូកធ្វើ គឺបានរែកដីរែកអី ចាក់ទំនប់ប្រឡាយនៅកន្លែងនោះគេដែរ កន្លែងស្ពាន កន្លែងអីនោះ។

**ស៖** ខ្ញុំព្យាយាមចង់ស្វែងយល់អំពីពេលវេលាដែលលោកស្ថិតនៅទីនោះ។ លោកអាចជម្រាបជូនតុលាការបានអំពីថ្ងៃខែឆ្នាំ ដែលលោកបានទៅដល់<ទី>នោះដំបូងបានទេ?

**ឆ៖** ឥឡូវខ្ញុំសូមជម្រាបថា នៅពេលដែលខ្ញុំទៅដល់នៅក្នុងអាងត្រពាំងថ្ម គឺខ្ញុំបាទចល័តច្រើនកន្លែងណាស់ ចល័តច្រូតស្រូវ បែកពីច្រូតស្រូវបានមកកន្លែងអាងត្រពាំងថ្ម។ ដូច្នេះពេលវេលាដែលការដែលធ្វើគឺខ្ញុំអត់ដឹងថ្ងៃទីប៉ុន្មាន ខែប៉ុន្មានទេ គឺដឹងតែក្នុងឆ្នាំ -- ចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ បានខ្ញុំបានប្រឡូកបានចុះជីកប្រឡាយ ចុះអី ចុះជីកធ្វើទំនប់ ធ្វើអី បាទ។ ប្រសិនបើថ្ងៃទីអី គឺខ្ញុំមិនចាំទេ ខែមិនចាំ។ ពេលនោះខ្ញុំមិនគិតគូររឿងខែរឿងនេះទេ គឺដឹងតែឆ្នាំបណ្តោយ។

[១៣:៥២:៥៤]

**ស៖** ហើយថាតើលោកស្ថិតនៅការដ្ឋានទំនប់ត្រពាំងនោះ រហូតដល់ពេលគេលើកទំនប់រួចរាល់ហើយឬក៏យ៉ាងម៉េច?

**ឆ៖** ទំនប់អាងត្រពាំងថ្ម ខ្ញុំបាទនៅៗដល់ឆ្នាំ៧៧។ ដើម -- ចុងឆ្នាំ៧៧ ខ្ញុំបាទចេញ ព្រោះខ្ញុំរត់ចេញពីអាងត្រពាំងថ្ម ព្រោះសភាពការណ៍វាមិនស្រួលខ្ញុំរត់ចេញ បានធ្វើបានតែពី៧៦ ដើម -- ចុងឆ្នាំ៧៦ និងចុងឆ្នាំ៧៧។

**ស៖** សូមអរគុណ។ នៅពេលដែលលោកទៅធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម គេបញ្ជូនលោកទៅទីនោះ ឬក៏លោកទៅទីនោះដោយស្ម័គ្រចិត្ត?

**ឆ៖** បាទ អត់មាននេះទេ គេបញ្ជូនទៅដោយ អានេះជាទិសរបស់គេ នេះអត់មានយើងចង់ទេ។

**ស៖** តើគេដកលោក បញ្ជូនលោកចេញពីការដ្ឋានមួយណា ទៅកាន់ទំនប់ត្រពាំងថ្មហ្នឹង?

**ឆ៖** ខ្ញុំគេដកចេញពីអង្គភាពឃុំនៅតាមចល័តភូមិឃុំ។ គេឲ្យទៅច្រូតស្រូវនៅថ្មពួក ដល់ពេលចប់ពីថ្មពួក បានច្រូតស្រូវរួចនៅថ្មពួក បានគេបញ្ជូនយើងខ្ញុំមកអាងត្រពាំងថ្ម មកលើកទំនប់ ហើយធ្វើស្ពាន ហើយស្រេចគេត្រូវការនៅពេលនោះ គេចង់ប្រើទៅណាក៏បាន អត់មានអីទេ គឺចេះតែធ្វើទៅ។

[១៣:៥៤:៥៥]

**ស៖** តើអ្នកណាជាអ្នក<បញ្ជូល>លោកទៅការដ្ឋានទំនប់ត្រពាំងថ្ម?

**ឆ៖** ព្រោះការបញ្ជូនរបស់គេ គឺនិយាយរួមនៅក្នុងការងារនោះ ខ្ញុំក៏នេះដែរ វាមានប្រធានរបស់គេ ប្រធានកង ប្រធានក្រុមគេក្នុងអង្គភាព គេចាត់កម្លាំង ចែកកម្លាំងគ្នាទៅ មួយទៅនេះ មួយទៅនោះ ចែកតាមគេចាត់តាំង។ ខ្ញុំអត់ដឹងថា គេចាត់ទៅណាអីទេ ត្រូវតែទៅក៏ចេះតែទៅ មិនបានគិតទេ។ ព្រោះពេលនោះ មិនមានបានគិតអីទាំងអស់ ចេះតែដើរ ចេះតែទៅហើយ។

**ស៖** ដូច្នេះ លោកឆ្លើយថាគេបញ្ជូនលោកទៅណាក៏បានដែរ ហើយលោកត្រូវតែគោរពតាមការចាត់តាំងហ្នឹង។ ហេតុអីបានជាលោកត្រូវតែគោរពតាមការចាត់តាំងយ៉ាងដូច្នេះ?

**ឆ៖** នោះខ្ញុំជម្រាប បើខ្ញុំមិនទៅម៉េចបានព្រោះការងារទាំងអស់នោះ វាត្រូវតែទៅ បង្ខំចិត្តត្រូវតែទៅ បើមិនចង់ក៏ត្រូវតែចង់។

**ស៖** ហើយហេតុអ្វីបានជាលោកមានអារម្មណ៍គិតថា លោកគ្មានជម្រើសត្រូវតែទៅ?

**ឆ៖** បើមិនទៅគេថា យើងរឹងទទឹងនឹងអង្គការ រឹងទទឹងនឹងច្បាប់។

**ស៖** អ៊ីចឹងលោកគិតយ៉ាងម៉េចដែរ បើសិនណាជាគេ<ថាលោកហ្នឹងរឹងទទឹង?>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់លោកប្រធាន នេះជាសំណួរសួរឲ្យស្មានៗហើយ។

[១៣:៥៧:០២]

**លោក ត្រាវីស ហ្វារ៖**

លោក លោកស្រីចៅក្រម ខ្ញុំមិនបានសួរឲ្យសាក្សីឆ្លើយដោយស្មាន គឺសួរអំពីជំហាររបស់គាត់ពាក់ព័ន្ធទៅនឹងថាតើគាត់ទៅធ្វើការនៅទីនោះ ដោយស្ម័គ្រចិត្ត ឬក៏យ៉ាងណា?

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា។ សំណួរនេះអាចសួរបាន។ អង្គជំនុំជម្រះត្រូវការស្ដាប់ចម្លើយតបរបស់សាក្សីទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយអំមិញ ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក គង់ សំអុន៖**

លោកប្រធាន តាមរយៈការបកប្រែអំមិញ សំណួរមិនទាន់បានបកប្រែជាភាសាខ្មែរពេញលេញទេ ដូច្នេះ ខ្ញុំគិតថា ទាំងសាក្សី និងខ្ញុំក៏ចង់ដឹងសំណួរហ្នឹងសិនដែរបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តាំងសំណួរចុងក្រោយសាជាថ្មីម្ដងទៀត ឲ្យបានច្បាស់លាស់។

**លោក ត្រាវីស ហ្វារ៖**

បាទ លោកប្រធាន ខ្ញុំនឹងសួរឡើងវិញ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា លោកជឿថាមានអ្វីកើតឡើងបើលោកបដិសេធមិនទៅធ្វើការ ហើយបើសិនណាជាគេចាត់លោកថា លោកនេះរឹងទទឹង?

**លោក ម៉ម សឿម៖**

**ឆ៖** បាទ ការធ្វើអីបដិសេធ អត់បានដាច់ខាង។ គឺអង្គការចាត់តាំងហើយត្រូវតែទៅ ព្រោះយើងអត់មានរឹងទទឹងបានទេ។ ធ្វើអីនៅក្រោមការចាត់តាំងទាំងអស់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ អរគុណ។ ឥឡូវនេះខ្ញុំសូមសួរលម្អិតបន្តិចអំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងនៅ ការដ្ឋានទំនប់ត្រពាំងថ្ម។ ដំបូងសូមលោកឆ្លើយមើលថា តើលោកនៅពេលហ្នឹងស្ថិតនៅកងណា?

[១៣:៥៩:៥៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

**លោក ម៉ម សឿម៖**

**ឆ៖** នៅអាងត្រពាំងថ្មដែលខ្ញុំបាទទៅធ្វើនោះ គេហៅថា កងតំបន់ កងចល័តតំបន់។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ហើយតើកងរបស់លោកហ្នឹងស្ថិតនៅចំណុះឲ្យតំបន់លេខប៉ុន្មាន?

**ឆ៖** បាទ តំបន់នោះគេហៅតំបន់៥ នៅតំបន់៥ បាទ។

**ស៖** លោកដឹងទេតើអ្នកណាជាអ្នកគ្រប់គ្រងទូទៅនៅកងហ្នឹង នៅក្នុងតំបន់៥ ហ្នឹង?

**ឆ៖** ខ្ញុំចាំមិនច្បាស់ដែរព្រោះតំបន់ ដូចថាតំបន់៥ហ្នឹង ដែលឃើញអ្នកដឹកនាំទៅដល់ស្គាល់វាមិនច្បាស់ដែរ ឃើញតែមុខ។ ថាតាវ៉ាល់ៗ តាមគេទៅ ខ្ញុំមិនសូវដែលប៉ានស្គាល់ទេ គាត់អ្នកគ្រប់គ្រងនៅតំបន់នោះ។

**ស៖** នៅពេលលោកថា តាវ៉ាល់ គឺជាមេដឹកនាំក្តាប់រួម តើគាត់មានតួនាទីអ្វីដែរ?

**ឆ៖** គាត់គ្រប់គ្រងតំបន់ គាត់គ្រប់គ្រងចល័ត ដឹកនាំធ្វើការនៅអាងត្រពាំងថ្មហ្នឹងឯង។

**ស៖** ក្រៅពីកងដែលចំណុះឲ្យតំបន់៥ តើលោកមានដឹងថាមានកងណាផ្សេងទៀតមកពីក្រៅពីតំបន់៥ មកការដ្ឋានទំនប់ត្រពាំងថ្មនោះដែរទេ?

**ឆ៖** ខ្ញុំក្តាប់មិនបានទេ ព្រោះតំបន់ផ្សេងៗវាអត់មានទាក់ទងគ្នាបានទេ គេមកតាមគេ ខ្ញុំក៏តាមខ្លួនឯងទៅមិនសូវបានស្គាល់ ព្រោះមនុស្សវាច្រើនទៅ មិនដឹងពីណាពីណីទេ។ ពេលនោះមិនបាន ច្របូកច្របល់គ្នាបានទេ អ្នកណានៅកន្លែងណា គឺកន្លែងនោះ។

[១៤:០២:២១]

**ស៖** តើលោកដឹងថាចំនួនកម្មករ ពលករ ធ្វើការសរុបទាំងអស់នៅការដ្ឋាន<ទំនប់ត្រពាំងថ្ម> ហ្នឹងមានទាំងអស់ប៉ុន្មាននាក់ដែរ?

**ឆ៖** លោកសួរអ៊ីចឹងខ្ញុំមិនដឹងទេ ព្រោះវាច្រើនដឹងតែច្រើន បើថាចំនួនប៉ុន្មានខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវនេះ ខ្ញុំសូមលើកឈ្មោះម្នាក់ដែលលោកលើកឡើង ឈ្មោះម្នាក់លោកយកមកនិយាយថាឈ្មោះ ជាមេរបស់លោក<នៅក្នុងកងចល័តតំបន់ហ្នឹង>។ តើ ញ៉ាវ នេះ គ្រប់គ្រងមនុស្សប៉ុន្មាននាក់ដែរ?

**ឆ៖** តាញ៉ាវ គាត់គ្រប់គ្រងមួយក្រុម និយាយរួមគេហៅកងធំ គេកងវរៈ មានកម្លាំងប៉ុន្មានកម្លាំងបីៗកងតូច មួយកងតូច ៣០នាក់។

**ស៖** ដូច្នេះតើត្រឹមត្រូវទេដែលថាកងធំគឺមានសមាជិកប្រហែលជា <៩០>នាក់។ ត្រឹមត្រូវដែរទេ?

**ឆ៖** ទេ កាលនោះដូចជាមិនគ្រប់ទេ ព្រោះចល័តមានតែកងទេ អត់ ដូចជាមិនគ្រប់ចំនួនប៉ុន្មានទេ ខ្លះ២០ជាង ខ្លះ៣០ អត់ទៀងគ្រប់តាមចំនួនដែលរៀបទេ។

[១៤:០៤:១៩]

**ស៖** ពេលដែលលោកហៅថា “កងធំ” តើៗកងធំហ្នឹង តាមដែលលោកដឹងហ្នឹង វាៗធំប៉ុន្មានអីប៉ុន្មានដែរ?

**ឆ៖** កងធំ វាស្មើនឹងបីកងតូច ព្រោះក្នុងក្រុមចល័តគេចែកជាកងច្រើនមានកងតូច កងធំ មានក្នុងបីកងតូចនេះ វាស្មើនឹងគេមួយវរៈ ប្រើកងធំ។ អានេះខ្ញុំវាមិនសូវច្បាស់ដែរណាអារឿងកងធំ កងតូចគ្រាន់តែថាក្រុម ក្នុងក្រុមរបស់ខ្ញុំ គេហៅមួយកងតូចៗ វាមាន៣០នាក់។

**ស៖** តើៗលោកមានដែលធ្លាប់ឮពាក្យកងអនុសេនាតូច អនុសេនាធំ វរសេនាតូចអីចឹងដែរទេ? តើគេមានប្រើប្រាស់ពាក្យទាំងអស់នេះដែរទេ សម្រាប់កងចំណុះឲ្យ<កងចល័ត>តំបន់៥នេះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក ម៉ម សឿម៖**

**ឆ៖** វាមិនដឹងៗអាកងតូចហ្នឹងយ៉ាងម៉េច កងធំយ៉ាងម៉េច គ្រាន់តែថាក្នុងមួយកងតូច គេថា៣០នាក់ គេរៀបអីចឹងឯងតាមចល័តក្នុងចល័តក្រុមនីមួយៗ។ ក្នុងមួយក្រុមវាមាន១០ -- ១២នាក់ ឬក៏១០នាក់ តាមចំនួនមនុស្សដែលគេអាចរៀបទៅបាន។ បើរៀបមិនបានប៉ុន្មាន ក៏គេបង្គ្រប់ៗចំនួនកងគេដែរ ដើម្បីងាយស្រួល កងនេះ កងនោះទៅ។ ព្រោះខ្ញុំនៅកងផ្សេងទៅ គេនៅកងផ្សេងទៅ។

[១៤:០៦:២៧]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ដូច្នេះ ឥឡូវនិយាយអំពីឈ្មោះ ញ៉ាវ វិញ គឺថាប្រធានកងធំ។ តើគាត់ធ្លាប់បង្គាប់បញ្ជា ឬក៏ចាត់តាំងឲ្យលោកធ្វើការណាមួយនៅការដ្ឋានទំនប់ត្រពាំងថ្មដែរឬទេ?

**ឆ៖** គាត់ប្រធានហើយ គាត់ណែនាំខ្ញុំបាទឲ្យៗទៅធ្វើនេះធ្វើនោះ បញ្ជា ព្រោះគាត់ត្រូវ -- ធ្វើអីគាត់ប្រជុំបាន ដាក់ទិសបណ្ដោយ ដាក់ទិសធ្វើ ត្រូវធ្វើផែនការអី គាត់ហ្នឹងអ្នកបង្គាប់បញ្ជា ត្រូវសម្រុកធ្វើអាណាៗអី មានផែនការអីគេមកប្រាប់តាមក្រុម តាមកងអីទៅ។ ឥឡូវលោកឯងត្រូវសម្រេចផែនការនេះ ផែនការនោះ ត្រូវធ្វើឲ្យបាន គាត់អ្នក -- ដូចថាគាត់ទទួលទិសពីលើមក គាត់មកដាក់តាមក្រុម តាមកងអ៊ីចេះទៅ។

**ស៖** លោកទើបតែបានឆ្លើយថា ញ៉ាវ ទទួលបញ្ជាពីលើហើយ គាត់មកបញ្ជាបន្តមកលោកមកថ្នាក់ក្រោមៗ។ ធ្វើម៉េចបានជាលោកដឹងថា ញ៉ាវ នេះ ទទួលបញ្ជាពីលើមក?

**ឆ៖** ចុះបើគាត់ពេលគាត់ទៅប្រជុំ គាត់ប្រាប់កូនចៅថា "ឥឡូវអញទៅប្រជុំហើយ"។ ពេលទៅប្រជុំ មិនដឹងទៅប្រជុំឯណា បើខ្ញុំអ្នកតូចៗអ៊ីចេះ។ ដល់ពេលមកវិញ គាត់ធ្វើផែនការខ្លួនគាត់។

**ស៖** លោកឆ្លើយថា មិនដឹងថាគាត់ទៅប្រជុំនៅឯណាទេ ប៉ុន្តែថាតើគាត់ លោកដឹងថា គាត់ទៅប្រជុំជាមួយអ្នកណាទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ ព្រោះការប្រជុំអ៊ីចេះៗ មិនដឹងទេ។

[១៤:០៨:៤៥]

**ស៖** តើលោកអាចជម្រាបបានទេ ញ៉ាវ នេះ នៅធ្វើជាប្រធានកងធំពេញមួយរយៈពេល<ដែលលោកនៅ>លើកទំនប់ត្រពាំងថ្មហ្នឹងឬក៏យ៉ាងណា?

**ឆ៖** ពេល ញ៉ាវ នេះ គឺធ្វើៗបាន ក៏ប៉ុន្តែអត់ -- ដល់ពេលនេះ ខ្ញុំនៅចុងឆ្នាំ៧៧ -- ដើមឆ្នាំ៧៧ ឬក៏ចុងឆ្នាំ៧៧ ខ្ញុំបាទនៅពេទ្យជាមួយគាត់ហ្នឹង ដល់ពេលនេះទៅ ដូចថាគាត់គេចាប់គាត់បាត់ គាត់អត់ដឹងទៅណា ស្រាប់តែបាត់គាត់។ ដល់ពេលអ៊ីចឹងទៅ ពួកខ្ញុំក៏ចាប់ផ្ដើមបែកបាក់គ្នា។ ធ្លាប់ឮតែនិរតីៗ ខ្ញុំមិនដែលដឹងច្បាស់ដែរ ដល់ពេលប៉ប្រូសប៉ប្រះអ៊ីចឹងទៅ វាអត់ដឹងថាអ្នកណាទៅឯណា អ្នកណាទៅឯណី ខ្វែងវៀងខ្លួន។ បាត់អ្នកដឹកនាំធំៗដែលតែងមក ក៏បាត់ទៅក៏ -- ខ្ញុំបែរជារត់ ដូចថាខ្ចាយគ្នាទៅ មាននរណាបាននៅ ខ្លះទៅនេះ ខ្លះទៅនោះ តាមក្រុម តាមកង។ ខ្លះគេប្រមូលគ្នានៅវិញទៅ ខ្លះ ខ្ញុំរត់មកផ្ទះវិញមក។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01483185



**ស៖** ខ្ញុំចង់យល់ឲ្យបានច្បាស់បន្តិចថា នៅពេលណា តើ តាញ៉ោវ បាត់ខ្លួននៅពេលណា? បើគិតពីពេលវេលាដែលលោកនៅធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម? តើបាត់ខ្លួននៅពេលគេលើកទំនប់ត្រពាំងថ្មហ្នឹងរួចរាល់ហើយ ឬក៏យ៉ាងណា?

[១៤:១០:៣២]

**ឆ៖** បាត់នៅពេលលើកអាងត្រពាំងជិតហើយៗ ជិត វាមិនទាន់ហើយស្រួលបួលទេ វាដូចថាទំនប់នៅតែថែមថយ ដូចថាទឹកក៏ហូរច្រើនទៅ ចេះតែដេកនៅធ្វើ ដូចថារបស់អីវាលើទប់ទឹក ទឹកដូចថាទំនប់វាថ្មីណ៎ា។ ដូច្នេះ ទឹកវាមកច្រើនទៅ បាក់ទៅ ក៏ពួកខ្ញុំពួកអីនាំគ្នាទៅនៅតាមតែលើទំនប់ដើម្បីយកដីថែមទំនប់ដើម្បីកុំឲ្យបាក់។ កាលហ្នឹងអត់ទាន់អីទេ ក្រោយពីហ្នឹងទៀត ជិតរួចហើយអស់ហើយ បានបាត់ អត់មាននរណានៅ បាត់ ព្រោះពេលហ្នឹងមើលទៅវាខ្លាំងពេកទៅ វាមិនមាននរណាហ៊ាននៅទេ។ មិនដឹងអ្នកណាទៅឯណាៗទេ ដល់ពេលដឹងតាមរយៈគ្នាទេ ក៏ខ្លះគេថាអ៊ីចេះ ខ្លះថាអ៊ីចុះទៅ វាបាត់រៀងខ្លួនទៅ។ ថាគេត្រូវគេចាប់គេអី ខ្ញុំដល់ឮគេថាគេចាប់គេអីយក អើនៅម៉េចបានរត់ទៅទាំងអស់តែគ្នា កូនចៅ ខ្លាចគេចាប់មេហើយ ចាប់កូនផង រត់ទាំងអស់តែគ្នាទៅ។ ព្រោះនៅតំបន់នោះ វាមិនមាននេះឯណាដូចថាការងារអីក៏ដោយ ធ្វើមិនដឹងធ្វើមិនឮល្អជាង បើដឹងហើយមិនបានទេ ធ្វើជាមិនដឹងមិនឮ ធ្វើអីធ្វើនឹងគេទៅ។

**ស៖** លោកទើបតែឆ្លើយថា លោកមានការភ័យខ្លាចនៅពេលដែលមេរបស់លោកត្រូវបានគេចាប់ខ្លួន ហើយលោកថា លោកវាអាចគេចាប់ខ្លួនលោកនៅពេលបន្ទាប់។ ម៉េចបានលោកភ័យខ្លាច?

**ឆ៖** ព្រោះយើងជាកូនជាចៅ ខ្លាចគេចាប់ចង់ដឹង ព្រោះយើងមិនដឹងថាម៉េចទេ ចេះតែមានអារម្មណ៍ ចេះតែខ្លាច។ ខ្ញុំមិនមានតួនាទី ឬក៏ធ្វើអីទេ គ្រាន់តែក្នុងនាមជាក្រុម ជាកូនក្រុមចល័តជាមួយគាត់ទៅ ក៏នឹកឃើញ ចេះតែខ្លាចទៅ។

[១៤:១២:៣៨]

**ស៖** ត្រឡប់ទៅពេលវេលាមុនពេលចាប់ខ្លួន តាញ៉ោវ។ តើលោកមានដឹងថា តាញ៉ោវ មានទំនាក់ទំនងអ្វីជាមួយ តាវ៉ាល់ ដែរទេ?

**ឆ៖** ទេ អារឿងកង ព្រោះគាត់នៅចំណុះកង តាវ៉ាល់ ហ្នឹងឯង ព្រោះកូនក្រុម។ បើនិយាយរួមគាត់នៅក្នុងចន្លោះចល័តតំបន់ បានន័យថានៅក្នុងលោកតាវ៉ាល់ហ្នឹងឯង ព្រោះ តាវ៉ាល់ គាត់អ្នកគ្រប់គ្រងការដ្ឋាន គ្រប់គ្រងចល័តរងនៅក្នុងតំបន់នោះ។ បើតាមដែរ នៅខ្ញុំនៅជាមួយ -- នៅក្នុងចល័តក្នុងតំបន់

នោះ ព្រោះតាញ៉ារ បើនិយាយរួមគាត់នៅក្នុងក្រុម តាវ៉ាល់ តែម្តង ព្រោះគាត់អ្នកក្តាប់រួម។

**ស៖** ហើយលោកបានឆ្លើយថា "តាមលោកកត់សម្គាល់នៅពេលនោះ" តើលោកអាចរៀបរាប់លម្អិតបន្តិចទេ ដែលមានមូលហេតុអ្វីខ្លះដែរ ដែលនាំឲ្យលោកសន្និដ្ឋានបែបនេះ?

**ឆ៖** ព្រោះអីចេះ បានជាខ្ញុំចង់និយាយថាសន្និដ្ឋានក៏បាន ព្រោះការធ្វើការងារក្នុងការដ្ឋាន គឺអត់បានទៅណាក្រៅពីការដ្ឋានទេ។ នៅអាងត្រពាំងថ្មគឺ ព្រឹកឡើងទៅទំនប់ ទៅអាងត្រពាំងថ្ម, ល្ងាចគឺមកកន្លែងវិញ ព្រឹកទៅ។ ធ្វើជាប្រចាំ។ ដូច្នេះ ដើរទៅមានឃើញ មានមិនឃើញ។ ដូច្នេះ ខ្ញុំអាចសន្និដ្ឋានថា ការដែលបាត់ ឬក៏ការដែលធ្វើអីដែលខុសប្លែក អាចចាប់អារម្មណ៍ថា អ្ហ៎! សភាពការណ៍ដូចជាមិនស្រួល ឬក៏សភាពការណ៍យ៉ាងម៉េចៗ គិតតែក្នុងចិត្តខ្លួនឯង។ មិនមែនថា អ្វីដែលឃើញហើយនិយាយ អត់ហ៊ាននិយាយទេ គ្រាន់តែថា បើសិនជាទៅដល់កន្លែងអាងត្រពាំងថ្មគឺអត់មានពិបាកអីទេ គឺម្នាក់ៗ គឺទៅតែការងារ អាងការងារធ្វើលើកដីលើកអីហ្នឹងឯង។ ទាំងខ្ញុំទាំងគេ ឲ្យតែក្នុងអាងត្រពាំងថ្មគឺមិនសូវមានការធ្វេសប្រហែសទេ បើថាការងារធ្វើការមិនសកម្ម ធ្វើការមិនល្អអី ពិបាកណាស់។

[១៤:១៥:០៧]

**ស៖** តើលោកនៅបន្តធ្វើការងារនៅទីនោះដដែលឬយ៉ាងម៉េច ក្រោយពេល តាញ៉ារ បាត់ខ្លួន? ហើយបើលោកនៅធ្វើការនៅទីនោះដដែលក្រោយពេលគេចាប់ខ្លួន តាញ៉ារ តើអ្នកណាជាអ្នកមកជំនួស តាញ៉ារ ក្នុងឋានៈជាមេកងធំ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា នៅពេលដែល តាញ៉ារ ស្លាប់ ពេលតាញ៉ារ បាត់ខ្លួនទៅ គឺខ្ញុំបាទរត់ចេញពីនោះហើយ អត់ដឹងថាអ្នកណាគ្រប់គ្រងបន្តទេ។ ព្រោះខ្ញុំបាទបាននិយាយពីដើមហើយថា ពេល តាញ៉ារ គេចាប់បាត់ គឺខ្ញុំបាទគឺចេញពីនោះហើយ ខ្ញុំទៅមូលដ្ឋានវិញ ខ្ញុំទៅផ្ទះវិញ។ គឺទី១ ដែលខ្ញុំទៅផ្ទះវិញ គឺដោយសារខ្ញុំ ខ្ញុំឈឺ ខ្ញុំហើម ខ្ញុំធ្វើការដូចថាវាអត់ពេញលេញទៅ ខ្ញុំនឹកឃើញសភាពការណ៍វាមិនស្រួលទៅ ខ្ញុំក៏មានការគេច ឬក៏ដោះខ្លួនទៅនៅៗតាមសហករណ៍ដើម្បីព្យាបាលខ្លួនផង ហើយដូចថាគេចពីកន្លែងតំបន់នោះផង។

**ស៖** ខ្ញុំគិតថាខ្ញុំនៅសល់តែសំណួរមួយទៀតទេ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ<កងរបស់លោក។ នៅផ្នែកចុងបញ្ចប់>នៅក្នុងចម្លើយរបស់លោកៗនិយាយពីឈ្មោះម្នាក់ទៀត ឈ្មោះៗ ផាន។ តើ ផាន នេះ ជាអ្នកណាដែរ?

**ឆ៖** តាផាន នេះប្រធានក្រុមខ្ញុំបាទ។ ព្រោះនៅធ្វើគេអ្នកមេក្រុមនីងៗក្រុមដូចថា គេជាមេក្រុម

គេដឹកនាំធ្វើការ។

**ស៖** តើមានមនុស្សប៉ុន្មាននាក់នៅក្នុងក្រុមដែលលោកទើបតែនិយាយអម្បាញ់មិញហ្នឹង?

**ឆ៖** ក្នុងក្រុមខ្ញុំបាទ វាគិតទៅតែ១០នាក់ទេដែលនៅតំបន់ហ្នឹង មានតែ១០នាក់។ សព្វថ្ងៃមិនដឹងទៅឯណាឯណីទេ បែកបាក់គ្នារកអ្នកនៅ មិនដឹងថាបែកទៅឯណាហើយ វាយូរណាស់ទៅហើយ រក -- ខ្ញុំស្រួលៗភ្លេចក្នុងក្រុមខ្លួនឯងទៀត។

[១៤:១៧:៣៦]

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីការចាប់ខ្លួននៅការដ្ឋាន ហើយខ្ញុំចាប់ផ្ដើមសួរលោកដំបូងអំពីអ្វីដែលលោកបានឆ្លើយនៅក្នុងចម្លើយរបស់លោក គឺខ្មែរមានទំព័រ 00279088, អង់គ្លេសមានលេខ 00289999, និងបារាំងមានលេខ 00483959។ អ្វីដែលលោកនិយាយគឺថា "ប្រសិនបើគេចង់ចាប់ពួកយើង នោះគេចាប់ផ្ដើមឡើងដោយមានគិញ ហើយបន្ទាប់មកគេសួរអំពីប្រវត្តិសាច់ញាតិ ឬក៏ប្រវត្តិ<ឪពុកម្ដាយ> សួរអំពីតួនាទី ហើយនិងឋានៈពីសម័យមុន"។ ដូច្នេះ ខ្ញុំចង់សួរថា តើគិញហ្នឹង<ជានរណាដែរ? តើលោកដឹងថាមានគិញហ្នឹងដោយរបៀបណាដែរ>?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំពីព្រឹកមិញបានជំទាស់ទៅនឹងសំណួរប្រហែលគ្នាដែរដែលថាគេជំទាស់ខ្ញុំមិនឲ្យខ្ញុំអាននូវសម្រង់ ហើយឥឡូវនេះ គឺតាមការសម្រេចរបស់តុលាការកំពូល គឺយើងមិនគួរបែបនេះទេ គឺថាព្រះរាជអាជ្ញាគាត់សួរសំណួរអ្វីដែលមិនច្បាស់ ហើយវាធ្វើឲ្យវាមានភាពមិនច្បាស់លាស់គ្នា ហើយគាត់គ្រាន់តែអានដើម្បីឲ្យសាក្សីគាត់ឆ្លើយតប ហើយបន្ទាប់មកគ្រាន់តែឲ្យសាក្សីគាត់បញ្ជាក់។ ហេតុដូច្នេះហើយទើបខ្ញុំជំទាស់ទៅនឹងបែបផែននៃការសួរសំណួរបែបនេះ។

[១៤:១៩:២២]

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអន្តរាគមន៍ទេ ព្រោះថានេះជាបញ្ហាដែលកើតឡើង

សម្រាប់សាក្សីបន្តបន្ទាប់មកទៀត។ ខ្ញុំក៏បានយល់ផងដែរ អំពីវិធានដែលបង្កើតឡើងដោយតុលាការកំពូល ដូចតែពីព្រឹកមិញអ៊ីចឹងដែរ គឺមានសេចក្តីណែនាំ<សម្រាប់>អង្គជំនុំជម្រះ។ ខ្ញុំឃើញថាសហព្រះរាជអាជ្ញាបានចោទសំណួរ<ថាតើនរណាជាគិញ ប៉ុន្តែមុននឹងឈានដល់សំណួរហ្នឹង គាត់>មិនបានសួរ<សំណួរ>បើក<ពាក់ព័ន្ធនឹងការចាប់ខ្លួនជាទូទៅ>នោះទេ <ហើយក្នុងករណី>បើសិនជា<សាក្សី>មិនចាំ<អ្វីដែលពួកគាត់មិនបាននិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយមុនៗ នោះ>អាចអាន<សម្រង់នោះជូនសាក្សីបាន។ ប៉ុន្តែវានឹងល្អប្រសើរក្នុងការទទួលបានចម្លើយពីសាក្សី ជាជាងការអានសម្រង់ដ៏វែងមួយ ពីកំណត់ហេតុស្តាប់ចម្លើយពីមុនរបស់សាក្សី ហើយបន្ទាប់មកសួរសំណួរតូចមួយ ដោយមិនអនុញ្ញាតឲ្យសាក្សីនិយាយអ្វីដោយឯកឯងនៅចំពោះមុខអង្គជំនុំជម្រះ។ ទាំងអស់នេះ គឺជាសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល។ សូមអនុញ្ញាតឲ្យខ្ញុំដើម្បីរំឭកអង្គជំនុំជម្រះផងដែរថា នេះគឺជាអ្វីដែលបាននិយាយនៅពេលចាប់ផ្តើមដំណើរការសវនាការនេះ នៅពេលដែលយើងត្រូវបានគេជំទាស់ទៅនឹងអង្គហេតុ គឺសាក្សីគួរតែមានលទ្ធភាពក្នុងការអានកំណត់ហេតុស្តាប់ចម្លើយពីមុនៗរបស់ពួកគាត់ មុនពេលមកបង្ហាញមុខចំពោះអង្គជំនុំជម្រះ។ ក្នុងករណីណាក៏ដោយ> នៅពេលដែលភាគីទាំងអស់សួរសំណួរទៅសាក្សីនោះ សុំឲ្យចាប់ផ្តើមដោយសួរសំណួរ<បើក>សិន ចៀសវាងកុំឲ្យនាំមុខ ឬក៏ដាក់ពាក្យបញ្ចុកចូលមាត់ទៅសាក្សី <ដោយអានអ្វីដែលគាត់បាននិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយមុនៗរបស់គាត់នោះ>។

**លោក ត្រាវីស ហ្វារះ**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ទី១ គឺថាខ្ញុំមិនមែន<>អានចម្លើយរបស់សាក្សី ហើយឲ្យសាក្សីបញ្ជាក់ទៅលើខ្លឹមសារនោះឡើយ។ ខ្ញុំគ្រាន់តែអានទៅលើផ្នែកដែលគាត់បានឆ្លើយរួចមកហើយ ហើយបន្ទាប់មក ខ្ញុំនឹងសួរសំណួរបញ្ជាក់បំភ្លឺមួយ ឬក៏ច្រើន។ ដូច្នេះ ខ្ញុំគ្រាន់តែចង់ទាញចំណាប់អារម្មណ៍របស់សាក្សីទៅលើប្រធានបទ ក៏ដូចជាទៅលើអ្វីដែលគាត់បាននិយាយរួចមកហើយ។ ព្រឹកមិញនេះ ខ្ញុំចាំច្បាស់ថា មេធាវីការពារក្តី នួន ជា បានសួរទៅដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់គិតថាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺ<គិតថានរណាដែលទទួលខុសត្រូវចំពោះ>ឧក្រិដ្ឋកម្ម<> ហើយមេធាវីការពារក្តីបាន<លើកយកការបកប្រែមួយនៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ហើយ>និយាយថា៖ “កន្លងមក <លោកបាន>និយាយថា សម្តេច សីហនុ គឺជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម<នឹងរូបលោក។ ហេតុអ្វីបានជាលោកនិយាយដូច្នេះ?” មេធាវីមិនបានសួរថា៖ “តើនរណាដែលលោកគិតថា

01483189



ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងរូបលោក?” ខ្ញុំគិតថា នេះមិនមែនជាវិធីដើម្បីជំទាស់នោះទេ> ព្រោះប្រសិនបើ<គាត់សួរ>ថា <តើនរណាដែលលោក>គិតថា<ត្រូវ>ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មហ្នឹង <នោះប្រហែលជា សាក្សីនឹង>និយាយអំពីមេ<កងរបស់គាត់ ហើយគាត់ប្រហែលជាលើកឡើងអំពីអ្នកផ្សេងទៀត។ ប្រាំនាទីក្រោយមក យើងអាចនឹង>ទៅដល់សម្តេចសីហនុ។ <មេធាវីអាចធ្វើបែបនេះបាន។ ខ្ញុំគិតថា យើងពុំមានពេលវេលាក្នុងដំណើរនីតិវិធីបែបនេះទេ។ ខ្ញុំយល់ វាមិនត្រូវបានអនុញ្ញាតឲ្យសួរគ្រាន់តែសុំការបញ្ជាក់ធម្មតានោះទេ។ ហើយនេះមិនមែនជាអ្វីដែលខ្ញុំកំពុងតែធ្វើនោះឡើយ។>

[១៤:២២:១៨]

<ខ្ញុំសូមផ្តល់មតិយោបល់មួយបន្ថែមទៀត> គឺថាខ្ញុំ<មិន>ចង់ឲ្យអង្គជំនុំជម្រះ<>យល់ច្រឡំអំពីអ្វីដែល<ធ្វើឡើងនៅចំពោះមុខ>អង្គជំនុំជម្រះតុលាការកំពូល<>នោះឡើយ។ <កំណត់ហេតុស្តាប់ចម្លើយដែលត្រូវសួរទៅកាន់សាក្សី>នៅចំពោះមុខ<អង្គជំនុំជម្រះ>តុលាការកំពូល <គឺសាក្សីទាំងអស់នោះត្រូវ>បានស្នើឡើងដោយមេធាវីការពារក្តី នួន ជា។ ហើយ<ជាឧទាហរណ៍ គឺ>សាក្សី SCW-5 នៅពេលដែលគេ<>សួរគាត់ នៅថ្ងៃ០៦ កក្កដា <គឺតាំងសំណួរដោយ>មេធាវីការពារក្តី នួន ជា <គឺ> ពួកគេបានសួរគាត់ដូចគ្នា ដូចដែលខ្ញុំបានសួរសាក្សីនៅពេលនេះអ៊ីចឹងដែរ។ ខ្ញុំអាចអាននូវឧទាហរណ៍បាន។ <សាក្សីម្នាក់នោះគឺស្នើឡើងដោយក្រុម>មេធាវី<ការពារក្តី> នួន ជា។ ដូច្នេះ មិនមែនជាការសួរដេញដោលនោះឡើយ។ <ពួកគាត់និយាយថា៖ “លោកបាននិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយនឹង>អ្នកស៊ើបអង្កេត<ថាមានពេលមួយនោះ>លោកប្រមូលអាវុធ ប្រហែលជា២ម៉ឺន គឺប្រមូលពីទាហានលន់ នល់ ហើយមានម្តងនោះ លោកយកអាវុធហ្នឹងទៅទុក។ លោកទទួលស្គាល់ថាលោកគឺជាអ្នកប្រមូលអាវុធ។ <លោកទើបតែបញ្ជាក់ថា លោកគឺជាអ្នកប្រមូលអាវុធ។ តើលោករក្សាទុកអាវុធទាំងអស់នោះនៅកន្លែងណា?> ហេតុអ្វីបានជា<អាវុធទាំងអស់នោះ>ចាំបាច់ត្រូវ<>រក្សាទុក។” គឺថាមេធាវីការពារក្តី នួន ជា ក៏សង្ខេបចម្លើយ ហើយបន្ទាប់មកទៀតគាត់សួរបញ្ជាក់។ <សាក្សីបានឆ្លើយ> ហើយមេធាវីការពារក្តីបន្ទាប់មកទៀតបានសួរថា៖ “លោកបានរក្សាអាវុធទាំងអស់ហ្នឹងនៅក្នុងឃ្លាំង នៅព្រៃឫស្សី តើវាជាការត្រឹមត្រូវដែរឬទេ?” ដូច្នេះ មេធាវីការពារក្តី គាត់គ្រាន់តែបញ្ជាក់សួរបញ្ជាក់<ធម្មតា>តែប៉ុណ្ណោះ <ហើយបន្ទាប់មកប្រើប្រាស់វាដើម្បីជាមូលដ្ឋានដើម្បីសួរបញ្ជាក់បន្ថែមទៀត>។ ដូច្នេះ ខ្ញុំគិតថាយើងគួរតែច្បាស់លាស់អំពីស្ថានភាពទាំងអស់នេះ ដែលថាតើ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងយកផ្នែកណាមួយនៃចម្លើយយកមកនិយាយ គឺថា ដំបូងយើងប្រើប្រាស់សំណួរដើម្បីទាញចំណាប់អារម្មណ៍របស់សាក្សី បន្ទាប់មកទៀត យើងប្រើប្រាស់មូលដ្ឋានហ្នឹងដើម្បីសួរទៅលើសាក្សី។

[១៤:២៤:១៥]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំគិតថាវាមានខុសគ្នាយ៉ាងខ្លាំង<>រវាងសាក្សីដែលត្រូវបានគេសួរសំណួរនៅក្នុងបណ្ដឹងសាទុក្ខ ហើយនិងសាក្សី<រូបនេះ ក៏ដូចជាសាក្សីផ្សេង>ទៀត<នៅក្នុងសំណុំរឿងនេះ> គឺមិនមែនជាសាក្សីនៃបណ្ដឹងសាទុក្ខឡើយ ព្រោះសាក្សីគាត់បានអាននូវឯកសារចម្លើយរបស់គាត់រួចទៅហើយ គឺខាងអង្គភាពគាំពារសាក្សី អ្នកជំនាញ បានផ្ដល់ឯកសារ<ចម្លងមួយច្បាប់>ជូនគាត់រួចទៅហើយ។ នេះគឺជាការអនុវត្តមួយ ក៏ប៉ុន្តែយើងនឹងលើកឡើងអំពី>បញ្ហានេះ<នៅពេលផ្សេង។ វាគឺជាការអនុវត្តមួយដែលត្រូវបានហាមឃាត់ផងដែរ ដោយអង្គជំនុំជម្រះ>តុលាការកំពូល។ <អង្គជំនុំជម្រះតុលាការកំពូលបាន> បង្គាប់ទៅដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញមិនឲ្យផ្ដល់<កំណត់ហេតុស្ដាប់ចម្លើយសាក្សីពី>មុនទៅដល់សាក្សីនោះឡើយ។ ហើយខ្ញុំចង់បញ្ជាក់បន្ថែមទៀតថា ការលើកយកឧទាហរណ៍មួយដោយមិនមានការបញ្ជាក់អំពី ថាតើខ្ញុំសួរសំណួរសាក្សីជាទូទៅឬក៏អត់នោះ គឺជាការមិន<មានប្រយោជន៍>នោះឡើយ។ <ប៉ុន្តែបញ្ហាច្រើននោះ គឺថា>សាក្សីនៅពេលនេះ និងសាក្សីផ្សេងៗទៀត គាត់ទទួលបានឯកសារកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់មុនរួចមកហើយ។ នេះគឺជាចំណុច<ខុសគ្នា>ដ៏សំខាន់មួយ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ដែលផ្ដល់វេទិកាឲ្យខ្ញុំ ខ្ញុំមិនចង់កាត់ផ្ដាច់សហភាតា សហព្រះរាជអាជ្ញារបស់ខ្ញុំនោះទេ ក៏ប៉ុន្តែខ្ញុំយល់ឃើញថា ជាបញ្ហាគោលការណ៍ដែលនឹងកើតមានឡើងដដែល អ៊ីចឹងយើងគួរតែនិយាយឲ្យដាច់ស្រេចនៅពេលនេះតែម្ដងអំពីអ្វីដែលកើតនៅចំពោះមុខតុលាការកំពូល ហើយដើម្បីឲ្យសាលាដំបូង<អាចចេញសេចក្ដីសម្រេច ជូនដំណឹងដ៏ពេញលេញមួយ>។ តុលាការកំពូលបានចេញអនុស្សរណៈទាក់ទងទៅនឹងការដឹកនាំសវនាការ ក៏ប៉ុន្តែមិនបាន<ចេញសេចក្ដីសម្រេចអំពីចំណុចដែលលើកឡើងដោយមេធាវីការពារក្ដី នួន ជា និងខៀវ សំផន នោះទេ ពាក់ព័ន្ធ>ទៅនឹងការប្រើប្រាស់កំណត់ហេតុស្ដាប់ចម្លើយ ហើយនិងការអានកំណត់ហេតុស្ដាប់ចម្លើយ<ទាំងអស់នោះ នៅមុនពេលមកបង្ហាញខ្លួន>នៅចំពោះមុខ<អង្គជំនុំជម្រះនោះឡើយ>។ អ៊ីចឹងនេះគ្រាន់តែជាអនុស្សរណៈតែបណ្ដឹងនោះទេ អ៊ីចឹង<យើងទាំងអស់គ្នាច្បាស់ហើយអំពីតម្លៃផ្លូវច្បាប់នៃឯកសារ ដែលយោងដោយមេធាវី

ការពារក្តីកាលពីម្សិលមិញ។ ខ្ញុំសូមយោងទៅលើសេចក្តីសម្រេចរបស់>លោកចៅក្រម ឡាវ៉ែន៍ បានបំភ្លឺកាលពីម្សិលមិញហើយថា ការបកស្រាយឯកសារនេះវាមានលក្ខណៈមួយ ហើយលោកចៅក្រមក៏បាន<ក្រើនរំឭក និងបង្គាប់បញ្ជា>ផងដែរថា កុំឲ្យប្រើប្រាស់ជារបៀបទូទៅ គឺថាលើក ដកសម្រង់ដដែលៗចេញពីកំណត់ហេតុស្តាប់ចម្លើយ។ ដូច្នេះយើងត្រូវតែស្ថិតនៅក្នុងក្របខ័ណ្ឌនេះ។ លោកចៅក្រមប្រាប់ថា កុំឲ្យប្រើ អនុវត្តបែបហ្នឹងជាទូទៅ ដែលថាដកស្រង់ចេញជាលក្ខណៈទូលាយ ហើយដដែលៗនៃកំណត់ហេតុស្តាប់ចម្លើយ ហើយសុំឲ្យរក្សាការអនុវត្តដែល<យើងបានធ្វើតាំងពីពេលចាប់ផ្តើមដំបូងនៃសំណុំរឿងនេះ ហើយមេធាវីការពារក្តីត្រូវតែមានការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់ពាក្យពេចន៍របស់ពួកគេ។ អង្គជំនុំជម្រះ>តុលាការ<កំពូលមិនមានចេញសេចក្តីសម្រេច នៃបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងចំណុចទាំងអស់នេះទេ។ វាគ្រាន់តែជាអនុស្សរណៈមួយ ដែលបង្គាប់បញ្ជាអំពីរបៀបដែលដំណើរការនីតិវិធីនឹងបន្តទៅមុខទៀតប៉ុណ្ណោះ។ ដូច្នេះយើងទាំងអស់គ្នាត្រូវច្បាស់អំពីអ្វីបានកើតឡើងនោះ។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ បានប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយទាំងអស់នោះ នៅក្នុងអំឡុងពេលសវនាការដើម្បីសួរដេញដោលផ្ទៀងសាក្សីជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគាត់។ ដូច្នេះយើងទាំងអស់គ្នាបានអនុវត្តត្រឹមត្រូវល្អជាងអ្វីដែលក្រុមមេធាវីការពារក្តីបានលើកឡើងនៅថ្ងៃនេះ។>

[១៤:៣០:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវហ្នឹងអង្គជំនុំជម្រះសូមជម្រាបជូនភាគីថា ក្នុងករណីនេះវាបញ្ហាដដែលៗ ហាក់ដូចជាការគ្រប់គ្រងសវនាការក៏ជួបនឹងបញ្ហាដែរ ព្រោះរឿងវាធំ មិនមែនជារឿងតូចដែលងាយក្នុងការគ្រប់គ្រងទេ ប៉ុន្តែដើម្បីឲ្យបានច្បាស់លាស់ គឺសូមឲ្យភាគីពាក់ព័ន្ធគឺតាំងសំណួរបើកជាមុនសិន ចំពោះសាក្សីឬដើមបណ្តឹងរដ្ឋប្បវេណី ឬក៏គោលដៅណាដែលខ្លួនសួរ ហើយក្នុងករណីខ្លួនចម្លើយតបរបស់មេ របស់គោលដៅដែលបានសួរនោះ ឯងវាមានការខុស ឬក៏ផ្ទុយគ្នាទៅនឹងកំណត់ហេតុដែលខ្លួន ដែលគាត់បានផ្តល់សក្ខីកម្មលើកមុន នោះគឺទើបសំណួរបន្ទាប់មកទៀតអាចលើកយកដកស្រង់នូវកំណត់ហេតុដែលគាត់ឆ្លើយពីមុនៗ ផ្តល់សក្ខីកម្មពីមុនៗ មកផ្ទួផ្ទងជាមួយនឹងចម្លើយរបស់គាត់ដែលគាត់បានឆ្លើយចុងក្រោយដើម្បីបញ្ជាក់ នេះជាការច្បាស់លាស់ជាង។

ទី២ គឺយើងកត់សម្គាល់ឃើញថាបញ្ហាមួយទៀតដែលប្រឈមនឹងការបញ្ហានោះ ប្រសិនបើអាននូវកំណត់ហេតុស្តាប់ចម្លើយដែលមានពីមុនមកតែម្តងនោះ វានឹងអាចមានបញ្ហា វាប្រហាក់ប្រហែលគ្នា

ឬក៏វាខិតជិតគ្នាទៅនឹងសំណួរដឹកមុខ សំណួរនាំមុខ។ ដូច្នេះយល់ទេ ឥឡូវហ្នឹងសូមសំណួររៀបចំសំណួរឡើងវិញគឺសូមឲ្យរៀបចំសំណួរបើក ហើយប្រសិនមានបញ្ហាផ្ទុយគ្នា ដើម្បីចង់សួរច្បាស់លាស់នោះគឺអាចសួរបញ្ជាក់ដោយដកស្រង់ផ្គូផ្គងជាមួយនឹងចម្លើយដែលបានឆ្លើយនៅក្នុងកំណត់ហេតុមុនៗ។

[១៤:៣២:២៤]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រហែលជាមានបញ្ហាបកប្រែទេ។ មានការនិយាយអំពីការយោងទៅនឹងចម្លើយពីមុនៗមក ខ្ញុំគិតថាតាមពិតទៅ គឺថាយើងនិយាយអំពីចម្លើយពីមុនៗរបស់សាក្សីនេះទេ។ អ៊ីចឹងគឺថា សូមឲ្យចោទសំណួរបើកមុននឹងយោងទៅនឹងចម្លើយដែលសាក្សីហ្នឹងបានឆ្លើយពីមុនៗមក។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោកចៅក្រម ឡាវែន៍។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី ថាតើលោកនិងកម្មករដទៃទៀតដែលធ្វើការនៅការដ្ឋានហ្នឹងត្រូវបានគេតាមដានត្រួតពិនិត្យមើលដែរឬទេ?

**លោក ម៉ម សឿម៖**

**ឆ៖** បាទ នៅតាមការដ្ឋានគេតាមដាន គេចង់ដឹងតើយើងធ្វើ មិនធ្វើ។ បើសិនណា ឧបមាថាជីកដីម៉ែត្រគូបអ៊ីចេះ គេដឹងថាយើង ប្រសិនណាយើងជីកយើងធ្វើកម្មការងាររួចក្នុងម្នាក់ ២ម៉ែត្រគូប ឬ ៣ម៉ែត្រគូប គេមើលយើង បើថាយើងធ្វើទៅមិនរួច គេធ្វើរួច អាហ្នឹងគេៗចេះតែថាយើងៗធ្វើលក្ខណៈមិនយកចិត្តទុកដាក់ធ្វើក្នុងអ្វីដែលយើងដូចថាធ្វើទៅមិនយកចិត្តទុកដាក់ ដូចថាៗមិនអស់កម្លាំង ដាក់ ២ ម៉ែត្រគូបទៅអត់រួច ផុតពីនោះគេរួច។ ដូច្នេះ អាមិនរួច និងអារួចនេះ វាពិបាក។ ដូច្នេះ គេមើលយើងថារាល់ពេល រាល់ម៉ោង ដូច្នេះសកម្មភាពដែលគេធ្វើ គេៗៗតាមយើង តាមៗរយៈបណ្ដាញរបស់ -- ក្នុងក្រុមរបស់គេ ឧបមាថាក្នុងក្រុមចល័តវាមានបណ្ដាញគេ។ ដូច្នេះ បណ្ដាញរបស់គេៗអត់ដឹងប្រាប់ថា

អ្នកណាទេ គេអត់ប្រាប់ទេ។ ឧបមាថានៅក្នុងក្រុមខ្ញុំដូចគ្នា មិនដឹងពីណាជាបណ្ដាញទេ ក៏ប៉ុន្តែបើធ្វើការល្អមិនល្អ គេវាយតម្លៃនៅលើពេលដែលប្រជុំទិតៀនគ្នា ថាក្រុមនោះធ្វើការអត់សកម្ម ក្រុមនោះធ្វើការសកម្មអីទៅគេ ឲ្យតម្លៃទៅលើការងារធ្វើរួច មិនរួច។ ហ្នឹងបានគេបានដឹងថាអ្នកដែលរួចគឺអ្នកធ្វើការល្អ ធ្វើការសកម្ម អ្នកដែលមិនរួច គឺអ្នកធ្វើការមិនយកចិត្តទុកដាក់។ ដូច្នេះ ទិតៀនគ្នា។ នៅពេលដែលធ្វើជីកទំនប់ ឬក៏ធ្វើអីក៏ដោយ គឺសុទ្ធតែមានការតាមដានសកម្មភាពនៅពេលដែលបំពេញការងារអត់មានដាក់ចោលបានទេ។

[១៤:៣៥:២១]

**ស៖** តើលោកធ្លាប់ដឹងថាមានសមាជិកណាមួយ នៅក្នុងក្រុម ឬក៏នៅក្នុងកងរបស់លោក ត្រូវបានគេចាប់ខ្លួនដែរឬទេ?

**ឆ៖** បាទ ខ្ញុំនិយាយទៅ វាចូលទៅ វាយូរទៅ វាភ្លេច វាចាំៗ ក៏ប៉ុន្តែខ្ញុំមិនអាចនិយាយបានទេ ព្រោះការចាំហ្នឹង វាភ្លេចទាំងឈ្មោះមនុស្ស ភ្លេចទាំងមនុស្ស ព្រោះមនុស្សវាផ្សេងគ្នា អានេះខ្ញុំមិនអាចនិយាយបាន។

**ស៖** ខ្ញុំមិនចង់សួរឈ្មោះជាក់លាក់ទេ ប៉ុន្តែថាតើលោកចាំអំពីពេលវេលា ឬក៏ក្នុងកាលៈទេសៈអ្វីដែល<លោកបានឃើញ>មនុស្សណាម្នាក់ ត្រូវបានគេចាប់ខ្លួនដែរឬទេ?

**ឆ៖** បាទ ឥឡូវអីចេះ! នៅពេលការងារសម្រុក ឬក៏ដាក់ផែនការនៅពេលសម្រេចផែនការណាមួយ ដូចជាធ្វើទំនប់ សម្រេចផែនការទំនប់ បីថ្ងៃឲ្យរួច ឬក៏ពីរថ្ងៃឲ្យរួច ពេលនោះឯង ដែលមានសកម្មភាពកើតឡើង។ គេអាចធ្វើឲ្យបុគ្គលនោះចេញលេចឡើង ដើម្បីងាយស្រួលក្នុងការតាមដានងាយស្រួលក្នុងការចាប់។ បើសិនជាចង់ចាប់មនុស្ស ស្រួល ដាក់ផែនការវាងខ្លាំងទៅ អ្នកមិនសូវសកម្មគេអាចដឹងថាអ្នកនោះឯង ដែលៗៗមិនពេញចិត្ត ដែល មិនដូចថាធ្វើការមិនយកចិត្តទុកដាក់។ ដូច្នេះនៅពេលនោះ វាមាននៅក្នុងសកម្មភាពនោះមាន។

**ស៖** តើលោកចាំទេថា មានសមាជិកណាមួយនៅក្រុមលោកដែលមានគ្នា១០នាក់នោះ ឬក៏ក្នុងក្រុមដែលមានគ្នា៣០នាក់ហ្នឹង តើមានសមាជិកណាម្នាក់ ធ្លាប់ត្រូវគេចាប់ខ្លួនទេ?

[១៤:៣៧:៣៣]

**ឆ៖** នៅនែ ខ្ញុំក្តាប់មិនបានទេ ព្រោះគេចាប់ មានគេចាប់ ក៏ប៉ុន្តែខ្ញុំភ្លេច សព្វថ្ងៃភ្លេចឈ្មោះអស់ហើយ ភ្លេចទាំងរូប ភ្លេចទាំងឈ្មោះ វាស្រមៃមិនឃើញទេ ព្រោះវានៅក្នុងសម័យកាលនោះ វាមិនសូវ

ចាប់អារម្មណ៍នឹងនេះទេ ទាល់តែជិតស្និទ្ធគ្នាណាស់បានទៅរួច ព្រោះវាមាន១៧មេសា វាមានបងប្អូនភ្នំពេញ ដូចច្រឡូកគ្នាទៅ ខ្ញុំទៅដូចថាវាអត់ស្គាល់បានអស់ទេ។ ហើយជាពិសេសយើងនិយាយរួម ខ្ញុំមិនចាំបណ្តោយ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដកស្រង់នូវកំណត់ហេតុស្តាប់ចម្លើយកន្លងមករបស់សាក្សី ដែលគាត់បាន<រៀបរាប់ថាគាត់បានឃើញ>ការចាប់ខ្លួនមនុស្ស<បី>នាក់។ សូមលោកប្រធានអនុញ្ញាត។

[១៤:៣៨:៣៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៩:០០]

**ប្រធានអង្គជំនុំ៖**

លោកត្រូវតែតាំងសំណួរបើកជាមុន ឬក៏សួរគាត់ពីការចងចាំនូវអង្គហេតុ ព្រឹត្តិហេតុណាមួយដែលលោកមានបំណងសួរជាមុនសិន ហើយបើមុននឹងដកស្រង់យកចម្លើយពីមុនៗមកសួរបញ្ជាក់នោះ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំកំពុងតែព្យាយាមធ្វើបែបនេះ គឺថានៅក្នុងចម្លើយរបស់សាក្សី សាក្សីគាត់បានរៀបរាប់អំពីបទពិសោធន៍របស់គាត់ ដែលថាគាត់ឃើញគេចាប់មនុស្សបីនាក់ ប៉ុន្តែមុននេះ គឺគាត់ឆ្លើយថា គាត់អត់ដែលដឹងអំពីការចាប់ខ្លួននោះទេ។ ហេតុដូច្នេះហើយ ឥឡូវហ្នឹងគឺថាវាមានភាពខុសគ្នារវាងចម្លើយដែលគាត់ផ្តល់នៅក្នុងកំណត់ហេតុជាមួយនឹងអ្វីដែលគាត់ឆ្លើយនៅទីនេះ។ ហេតុដូច្នេះហើយទើបខ្ញុំឆ្លើយសុំអនុញ្ញាតលើកយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ដើម្បីជួយរំឭកដល់ការចងចាំរបស់សាក្សីរូបនេះ។ សូមលោកប្រធានសម្រេច។

**ប្រធានអង្គជំនុំ៖**

នេះចូលក្នុងរឿងដែលអង្គជំនុំជម្រះបានជម្រាបរួចហើយ។ អញ្ជើញ!

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងអាននូវ<ផ្នែកមួយនៅក្នុង>កំណត់ហេតុស្តាប់ចម្លើយរបស់លោក ដើម្បី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<>ជាឯកសារយោងគឺទំព័រខ្មែរ 00279088, អង់គ្លេសមានលេខ 00289999 និងបារាំងមានលេខ 00483959។ នេះគឺជាចម្លើយរបស់លោក លោកសាក្សី៖ “នៅល្ងាចមួយ ខ្ញុំឃើញ<ខ្មែរក្រហម>ចាប់មនុស្សចំនួនបីនាក់នៅក្នុងក្រុមរបស់ខ្ញុំ។ ការចាប់នោះ ខ្ញុំមិនដឹងថាពួកគេមានកំហុសយ៉ាងណាទេ ប៉ុន្តែអ្នកនោះសកម្មការងារ។ អ្នកទាំងបីនោះខ្ញុំមិនចាំឈ្មោះទេ ព្រោះជាអ្នក១៧មេសា គេមកចាប់ដោយមិនឱ្យសមាជិកក្នុងក្រុមយើងដឹងទេ គេយកឡានមកដឹក។ គេចាប់មនុស្សដាក់ឡានបែបនេះ ព្រោះក្រុមរបស់ខ្ញុំ <ចំណុះឱ្យកងចល័ត>តំបន់។ ដូច្នេះ ការចាប់<សមាជិកណាម្នាក់>នៅក្នុងកង<ចល័ត>តំបន់ គេធ្វើឡើងដោយសម្ងាត់។”

តើអ្វីដែលខ្ញុំអានជូនលោកស្តាប់នេះ ធ្វើឱ្យលោកនឹកឃើញឡើងវិញដែរឬទេ លោកសាក្សី?

**លោក ម៉ម សឿម៖**

**ឆ៖** បាទ នឹកឃើញ។ និយាយអ៊ីចឹង នឹកឃើញ ព្រោះនៅនឹងជិតរោង ព្រោះឃើញយកឡានមកមែន បាទ។ ដល់ពេលចាប់យកទៅ ខ្ញុំក៏មិនដឹងដែរនៅពេលដែលគេចាប់ ដល់ពេលចេញមក គេសួរថា៖ គេចាប់រឿងអី? គេថា៖ ឡានគេមកធ្វើអី? គេថា៖ គេចាប់មនុស្ស។ ឡានដាក់ពីក្រោយរោងគេថាចាប់មនុស្ស ហើយក៏មិនសួរថាចាប់អ្នកណាៗទេ គាត់ថា៖ គេចាប់ប៉ុន្មាននាក់? ថា៖ ចាប់បីនាក់។ ដល់ពេលគេដាក់ឡាន គេទៅបាត់ទៅ ខ្ញុំក៏មិនបានសួរថា រឿងយើងយ៉ាងម៉េចៗមិនដឹងទេ គ្រាន់តែថាមនុស្សនោះ ជាមនុស្សដូចថា ការងារអីធ្វើល្អណាស់ មិនសូវដែលមានសៅហ្មង មិនសូវដែលមានអីប៉ុន្តែមិនដឹងថាមាននិន្នាការយ៉ាងម៉េច។ វាមានពាក់ព័ន្ធយ៉ាងណា បានជាត្រូវគេចាប់ វាដូចជាឆ្ងល់ ទាំងខ្ញុំទាំងគេនេះ ឃើញវាដូចថា អ្វីដែលគេចាប់ហ្នឹងគួរឱ្យខ្លាច គួរឱ្យតក់ស្លុត ព្រោះគេចាប់ដោយមិនដឹងថាមូលហេតុយ៉ាងម៉េច។ បើនិយាយពីការដែលនិយាយនេះ អ្វីដែលនិយាយវាភ្លេច បាទ។

[១៤:៤២:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

<សូមអរគុណ លោកប្រធាន។ ខ្ញុំសូមស្នើសុំការអនុញ្ញាត ដើម្បីត្រឡប់ទៅប្រធានបទកាលពី> ព្រឹកមិញនោះ <តែពីរ>នាទី ដើម្បីរកឲ្យឃើញទំនាក់ទំនងទៅនឹងចម្លើយដែលបានឆ្លើយជូនទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសារតែវាពាក់ព័ន្ធ<ផ្ទាល់>ទៅនឹងសាក្សីរូបនេះ បើសិនជាអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំនឹងប្រើពេលតែមួយ ឬក៏ពីរនាទីទេ។ ព្រឹកមិញនេះលោកប្រធាន ខ្ញុំបានលើកឡើងអំពីបញ្ហាពាក់ព័ន្ធទៅនឹងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដែលខ្ញុំបានអានឲ្យសាក្សីស្តាប់កាលពីព្រឹកមិញនេះ ដូចខ្ញុំបានជម្រាបខាងដើមហើយ នេះគឺជាចម្លើយមួយក្នុងចំណោមឯកសារ៦៦ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឥឡូវនេះ យើងបានរកឃើញថាក្នុងចំណោមឯកសារទាំង៦៦របស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ ទាំងអស់នេះគឺមានលេខ E3 <>ហើយក្នុងចំណោមនេះគឺថាមានតែ១៣ឯកសារទេដែលបានបកប្រែទៅជាភាសា<អង់គ្លេស។ ដូចខ្ញុំលើកឡើងកាលពីព្រឹកមិញ គឺឯកសារទាំងអស់ហ្នឹងមិនមានការ>បកប្រែទៅជាភាសាបារាំង<នោះទេ គឺមាន>តែ១៣ទេដែលបកជាអង់គ្លេស។

[១៥:០៣:៤៤]

ដូច្នេះ ខ្ញុំយល់ឃើញថាឯកសារទាំងអស់នេះ គឺពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសាក្សីទាក់ទងទៅនឹងការដ្ឋានលើកទំនប់មួយនេះ។ ហើយកាលពីសប្តាហ៍មុននេះ គឺយើងខ្ញុំបានទទួលសេចក្តីសង្ខេបនៃចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន៦៤។ ដូច្នេះ សំណួរខ្ញុំ សួរថាតើយើងគួរចាប់ផ្តើមជាមួយនឹងឯកសារពាក់ព័ន្ធទៅនឹងផ្នែកនៃកិច្ចដំណើរការនីតិវិធីនេះយ៉ាងណាដែរក្នុងចំណោមឯកសារ១៣ នៃឯកសារ

ទាំង<៦៤> ដែលបានបកប្រែជាភាសាអង់គ្លេសតែ១៣នោះ។ ដូច្នេះ ខ្ញុំសួរថាតើអ្នកណាទទួលខុសត្រូវចំពោះការបកប្រែ ហើយថាតើការបកប្រែឯកសារដែលនៅសេសសល់ទាំង៥១ឯកសារនេះគឺ បកប្រែរយៈពេលៗប៉ុន្មានទើបហើយ។ ឯកសារទាំងអស់នេះវាពាក់ព័ន្ធទៅនឹងការដ្ឋានលើកទំនប់មួយនេះ។ ដូច្នេះបញ្ហាទាំងអស់នេះគឺស្ថិតនៅក្នុងដៃរបស់អង្គជំនុំជម្រះសាលាដំបូងហើយ <ពីព្រោះអង្គជំនុំជម្រះបានផ្តល់លេខ E3 សម្រាប់>ឯកសារទាំង៦៤នេះ <នៅ>ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការលើកឡើងបញ្ហានេះ។ ហើយអង្គជំនុំជម្រះនឹងលើកយករឿង -- លើកយកបញ្ហានេះយកមកពិចារណានៅថ្ងៃស្អែក។ អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី ខ្ញុំនៅសល់សំណួរមួយទៀតពាក់ព័ន្ធទៅនឹងការចាប់ខ្លួន។ បាទ ត្រង់ផ្នែកនេះ តើការចាប់ខ្លួននេះជាការចាប់ខ្លួនសមាជិកកងរបស់លោក ឬក៏យ៉ាងណា?

**លោក ម៉ម សឿម៖**

**ឆ៖** បាទ ព្រោះនៅក្នុងការចាប់ខ្លួននេះ គឺចាប់នៅក្នុងកងរបស់ខ្ញុំបាទ។

**ស៖** ហើយក្រៅពីការចាប់ខ្លួនបីនាក់នេះ មានការចាប់ខ្លួន<អ្នកណាផ្សេងទៀតនៅក្នុង>កងរបស់លោកដែរឬទេ?

**ឆ៖** ក្នុងនោះវាមានកងខ្ញុំបាទហ្នឹងឯង ព្រោះបានឃើញ ឡានដឹកតែម្តង ហើយក្រៅពីហ្នឹងមិនឃើញទេ។

**ស៖** តាមដែលលោកដឹង តើមានការចាប់ខ្លួនប៉ុន្មាននាក់ដែរនៅក្នុងកងលោកទាំងមូលនេះ?

**ឆ៖** ព្រោះក្នុងកងរបស់ខ្ញុំបាទ បើនិយាយពីការចាប់ខ្លួន ខ្ញុំដឹងតែបីនាក់ទេ ព្រោះនេះឃើញជាក់ស្តែង ផុតពីនោះមិនដឹងទេ។ ព្រោះខ្ញុំមិនសូវដែលបាន អារឿងចាស់ៗមិនសូវបានសួរនាំ ឬក៏តាមដាន ឬក៏ម៉េចទេ នៅសម្ងំ បើថាមកពីធ្វើការ គឺចូលកន្លែងសម្ងំស្ងាត់ជ្រាបហើយ មិនដែលបានដើរទៅណា។

**ស៖** តើសមាជិកបីនាក់នេះជាសមាជិកនៅក្នុងក្រុម១០នាក់ ឬក៏ក្រុម<៣០> ឬក៏<នៅក្នុង

ក្រុមធំ ៩០>នាក់<>?

**ឆ៖** ក្នុងកងនេះវាមាន -- ក្នុងកង គេហៅកងតូច ក្នុងកងតូច អង្កាល់នោះគេហៅ ៣០នាក់។

[១៥:០៨:៤៤]

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរលោកអំពីចំនួនម៉ោងការងារ។ តើលោកធ្វើការប៉ុន្មានម៉ោងក្នុងមួយថ្ងៃនៅការដ្ឋានទំនប់ត្រពាំងថ្ម?

**ឆ៖** បាទ និយាយពីការងារម៉ោងនេះ ខ្ញុំសូមជម្រាបផ្ទាល់ថា ពេលវេលាគឺអត់កំណត់ទេ ថ្ងៃណាបើមានការងារខ្លាំងគឺក្រោកពីជិតម៉ោងបីជិតភ្លឺ គឺម៉ោងបួនអី នាំគ្នាដាស់គ្នាហើយ នេះផែនការខ្លាំង។ តែបើផែនការបើមិនខ្លាំង គឺក្រោកនៅម៉ោងប្រាំ ម៉ោងអីបាន បើផែនការខ្លាំង គឺក្រោកពីយប់ម៉ោងបីដាស់គ្នាហើយ បង្គី ចបជាប់លើស្មា ទៅសម្រុក។ ថាបើផែនការវាធូរស្រាល ដូចធម្មតានោះ គឺគ្រាន់តែយើងលីចប បង្គី យើងធ្វើមិន -- វាមិនៗដូចថាមានពេលវា។ យើងឧបមាថាម៉ោង ប្រហែលម៉ោងប្រាំព្រឹកអីចេះទៅដល់តែម៉ោងដប់មួយទៅ យើងឈប់ហូបបាយទៅ, ល្ងាច យើងម៉ោងពីរទៅដល់ម៉ោងប្រាំទៅ, ល្ងាចតែម៉ោងប្រាំមួយដល់ម៉ោងប្រាំបួនទៅ។ ដូច្នេះ ក្នុងមួយថ្ងៃធ្វើការបីដង មានពេលព្រឹក ពេលយប់ និងពេលថ្ងៃ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺលោកធ្វើនៅល្ងាចពីម៉ោងប្រាំមួយល្ងាចដល់ម៉ោងប្រាំបួនយប់ហ្នឹង គឺធ្វើជារៀងរាល់យប់ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំសូមជម្រាបថាម៉ោងប្រាំមួយ ដល់ម៉ោងប្រាំបួនយប់នេះ គឺជាពេលវេលាដែលផែនការដែលត្រូវសម្រុក ឬផែនការដែលត្រូវរៀបចំអាណាដែលខូចខាត ដូចទំនប់អីដែលវាបាក់អី គេឲ្យយើងរយៈពេលប៉ុន្មានថ្ងៃឲ្យហើយ យើងសម្រេចទៅតាមកង តាមក្រុមរបស់យើង។ ដូច្នេះយើងទទួលខុសត្រូវយើងទៅធ្វើ គឺអត់មានដូចថារហូតទេ អានេះទៅតាមផែនការសម្រេច ថ្ងៃណាដែលគេត្រូវដាក់ផែនការឥឡូវលោកឯងត្រូវតែធ្វើនេះឲ្យហើយក្នុងពេលនេះ ចាប់ពីថ្ងៃនេះដល់ថ្ងៃនេះ ត្រូវតែធ្វើឲ្យហើយ។ ដូច្នេះក្នុងក្រុមហ្នឹងឯងមិនអាចនេះបានទេ ត្រូវតែធ្វើឲ្យរួចឲ្យគេ។

[១៥:១១:៣០]

**ស៖** លោកទើបតែនិយាយអំពីផែនការដែលគេដាក់ឲ្យលោកធ្វើហ្នឹង។ តើផែនការហ្នឹងគេឲ្យលោកធ្វើប៉ុន្មានម៉ែត្រគូបអីដែរក្នុងមួយថ្ងៃៗ?

**ឆ៖** ការធ្វើ -- ការឲ្យធ្វើនេះ បើនិយាយពីរឿងផែនការរបស់គេ គេកំណត់។ មុនដំបូងគេឲ្យ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងធ្វើ ២ម៉ែត្រគូបមួយថ្ងៃ។ តែបើសិនមួយថ្ងៃរួចពីថ្ងៃ គេថែម១គូបដើម្បីឲ្យបាន ៣គូប ក្នុងមួយថ្ងៃ។ ដូច្នេះគេធ្វើដេញយើងឲ្យយើងធ្វើ។ តែបើសិនជាធ្វើ៣ ហើយរួចទៀត ហើយអាអ្នក៣ ហើយតាមក្រោយគេមិនរួច អាហ្នឹងមានការទិតៀនពីក្រុមក្រៅ អាចសន្និដ្ឋានថា ក្រុមខ្លះក៏រួច ក្រុមខ្លះក៏មិនរួច។ បើរួចគឺមកពីអី បើមិនរួចគឺមកពីអី គេរកមូលហេតុយើងអ្នកៗធ្វើក្នុងការជីកម៉ែត្រគូបនេះ។

**ស៖** តើលោកត្រូវរែក ត្រូវជីក រែកដីពីៗៗប្រឡាយហ្នឹង ហើយមកខ្ទងទំនប់ហ្នឹងចម្ងាយប៉ុនណា?

**ឆ៖** ឆ្ងាយ ចូលប្រហែលជា ១០ម៉ែត្រឡើងទៅលើ ចាក់លើខ្នង កម្ពស់ប្រមាណចូល ៤, ៥, ៦, ៧ ម៉ែត្រ កម្ពស់ដាក់ទៅលើ រែកម៉ែត្រគូបឡើង។

**ស៖** តើលោកដឹងទេ <ការ>រែកដីមួយអម្រែកៗហ្នឹង ទម្ងន់ប្រហែលជាប៉ុន្មានគីឡូក្រាមដែរ?

[១៥:១៣:៣៤]

**ឆ៖** បើរឿងថាទម្ងន់ៗ ស្មានមិនដឹងទេ វាស៊ីសងនឹងថាចង់លឿនទៅ គេដាក់ដីឲ្យច្រើនទៅ បើថាមិនចង់ -- ដូចថាធ្វើល្មមៗ ឲ្យគេដាក់ល្មមៗទៅ។ វាមិនអាចថា ដាក់ឲ្យច្រើនហួសប្រមាណទេ ដាក់តែមួយកម្លាំងធ្វើម៉េចឲ្យ ដូចថាធ្វើល្មមៗកម្លាំង។ បើថាចង់លឿន គេដាក់ឲ្យច្រើនទៅ បើថាមិនធ្វើឲ្យលឿនទេ គេដាក់ល្មមៗទៅរែកឡើង។ តែបើយូរៗវាអាចចេះតែសោទៅៗ មុនដំបូងខ្លាំង យូរៗចេះតែខ្សោយទៅៗ។

**ស៖** ចុះរបបអាហាររបស់លោកវិញ តើដើម្បីរែកដីបានអ៊ីចឹងហ្នឹង លោកទទួលបានរបបអាហារប៉ុន្មានដងដែរក្នុងមួយថ្ងៃ?

**ឆ៖** របបមួយថ្ងៃបានៗ ពីរៗពេលហ្នឹងឯង ព្រឹកនិងល្ងាចហ្នឹងឯង។ ហើយរបបក្នុងម្នាក់ -- ក្នុងពីរនាក់មួយកំប៉ុងឲ្យហូប។ ហើយសេដ្ឋកិច្ចគេអ្នកដាំ។ បើនិយាយរួមគេពួកសេដ្ឋកិច្ចគេអ្នកដាំឲ្យយើង ក្នុងក្រុមអីគេឲ្យដាំប៉ុន្មានបានគេ ឧបមាថាការដ្ឋាននៅឆ្ងាយ កន្លែងដែលត្រូវនេះឆ្ងាយ គេដាំបាយឆ្អិនទៅគេរែកយកទៅឲ្យយើងហូបនៅកន្លែង កុំឲ្យយើងដើរមកធ្វើ ដើរមកវាខាតការងារវាយូរ។ នេះចំពោះការងារដែលត្រូវធ្វើឲ្យៗរួចឲ្យសម្រុកឲ្យខ្លាំង គឺគេមានក្រុមគេដាំបាយឲ្យយើងហូបនៅការដ្ឋាននោះ។

**ស៖** នេះពី -- តើចំនួនរបបអាហារនេះគ្រប់គ្រាន់ទេ វាធ្វើឲ្យលោកបាត់ឃ្លានបាត់អីទេ ឆ្អែតទេ?

**ឆ៖** ការហូបចុកវាមិនអាចឆ្អែតទេ ខ្ញុំធ្វើបណ្តើរ ខ្ញុំមិនចង់និយាយទេនិយាយទៅវាចេះតែវែងឆ្ងាយ ព្រោះការហូបនេះមិនមានអីនឹងឆ្អែតទេ ព្រោះមួយកំប៉ុងវាពីរនាក់ទៅ ពេលណាហុតបបរ គេបបរ

ឲ្យផង កាលណាទៅក៏គេបន្ថយអង្ករពីបបរមក សល់គេដាំបាយឲ្យខ្លះទៅ ដូច្នេះការហូបចុកវាមិនគ្រប់គ្រាន់ទេ ចេះតែតស៊ូទៅ។

[១៥:១៦:២៥]

**ស៖** តើលោកអាចប្រាប់អំពីៗអនាម័យនៅកន្លែងការដ្ឋាននោះបានទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបដែរថា នូវបញ្ហាអនាម័យនេះ បើនិយាយអំពីកន្លែងខ្ញុំបាទ គឺមិនមានទេ ដូចជាការបត់ជើង ដូចជាការហូបចុក ក៏វាមានការរាករូស វាមានការចុកហើមអ៊ីចឹងទៅ វាឈឺ ដូច្នេះចល័តនៅក្នុងក្រុម ឬក៏ក្នុងកងនេះឯង តែងជួបការលំបាកក្នុងការអនាម័យនេះ។ វាពិបាកអត់មានទេ ពិបាកណាស់ ព្រោះរោងការដ្ឋានកន្លែងវា -- វាអត់មានកន្លែងដេកដឹក កាប់រនាបឬស្សីដាក់បានដេក ខ្លះក៏មានជាអង្រឹងបាវ ខ្លះក៏មានជា ឫស្សីអីទៅ មានខ្លះវាអត់ ភាគច្រើនៗតែអង្រឹងបាវ ហើយនិងដេកផ្ទាល់ដីបណ្ដាយ។ ជាក់ស្ដែងដូចពួកខ្ញុំបាទនេះ មិនដែលមានអីទេ មានតែអង្រឹងបាវហ្នឹងឯង បោះបង្គោលត្រង់នេះ ត្រង់នោះបានចងបានដាក់ដេកទៅ ក្នុងក្រុមជាមួយគ្នាខាងក្នុងអ៊ីចឹងទៅ។ ហើយពេលធ្វើរោងធ្វើអីទៅដាក់សម្រាប់ដេកខ្លួនឯង អីខ្លួនឯងទៅ គ្មានពិបាកអ្នកណាដោះស្រាយឲ្យអ្នកណាទេ ដោះស្រាយរឿងខ្លួនធ្វើយ៉ាងម៉េចឲ្យបានតែនៅ។

**ស៖** ចម្លើយរបស់លោកមួយ<ចុងក្រោយ>នេះ គឺលោកនិយាយអំពី<ជំងឺ រួមទាំងជំងឺ>រោគរាករូស។ ថាតើ<កម្មករដែលលោកស្គាល់ និងធ្វើការជាមួយហ្នឹង មានប្រភេទជំងឺទាំងអស់ហ្នឹងញឹកញាប់ដែរ ឬទេ>?

**ឆ៖** ព្រោះការហូបចុកអីដូចថាអត់មាន ដូចថាវាអត់បានទៅតាមអនាម័យ ឬក៏វាអត់មានអនាម័យហូបៗឲ្យតែរស់ ឲ្យតែបាន ឲ្យតែឆ្អែតៗទៅ បើនិយាយពីរឿងថាសម្រាប់ឲ្យ វាដូចថាផ្សងព្រេងទៅតាមអីនេះ និយាយពីរឿងផ្សងព្រេងបណ្ដោយ មិនដឹងថាម៉េច មិនដឹងថាទៅរកយ៉ាងម៉េច បើវាមិនមានប៉ុណ្ណោះទៅហើយ ចេះតែស៊ូទៅ។ ទាំងគេទាំងខ្ញុំ ខ្លះក៏ចុះមួល ខ្លះក៏រាក ខ្លះក៏ហើម ខ្លះវាគិតឲ្យដល់ទៅ វាពិបាកដែរមិនដឹងចង់ថាម៉េចទេ ព្រោះនៅ វាមិនដឹងទៅរក មិនដឹងទៅធ្វើអី ព្រោះវាអត់មានទៅហើយ នៅៗកន្លែងខ្ញុំ វាអត់ដឹងទៅរកអីឯណាផង។

[១៥:១៩:២០]

**ស៖** តើលោកដឹងថា មានអ្នកណាម្នាក់នៅក្នុងកងរបស់លោកស្លាប់ដោយសារតែជំងឺដែរឬទេ នៅឯការដ្ឋានលើកទំនប់ហ្នឹង?

**ឆ៖** មានតើ ព្រោះអ្នកដែលស្លាប់នៅក្នុងជំងឺរាកមួលមាន។ សួរយ៉ាងម៉េចបានថា ព្រោះវាអត់មានថ្នាំព្យាបាល ងាប់ មានងាប់ម្នាក់ដោយសារជំងឺ ព្រោះជំងឺរាករូសអត់មានថ្នាំព្យាបាលទេនៅក្នុងអង្គភាព អ្នកដូចថាគ្នាឈឺទៅក៏វាយ៉ាប់ដែរនោះ មិនដឹងទៅរកពេទ្យឯណា។ បើសិនជាទៅពេទ្យ ទាល់តែពេទ្យចេញទៅក្រៅ ហើយបើសិនបើបញ្ជូន ទាល់តែយើងទៅតាម ទៅដូចថា ពេទ្យនៅខាងក្រៅ ពេទ្យនៅតាមសហករណ៍អី គេមាន។ ដល់ពេទ្យប្រចាំតំបន់ ដូចអត់មានទេកន្លែងហ្នឹង អត់មានពេទ្យទេ។

**ស៖** ត្រឡប់ទៅនិយាយអំពីចំនួនម៉ោងការងារ និង ផែនការការងារ។ តើលោកអាចសម្រេចផែនការកំណត់នេះបានញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ការធ្វើផែនការហ្នឹងមិនសូវដែលបានទេ ច្រើនតែគេទិតៀន ថ្ងៃណាក៏រួច ថ្ងៃណាក៏មិត្តភក្តិជួយ ថ្ងៃណាក៏បានរួចកណ្តាលទេ ព្រោះកម្លាំងយើងវាតូច ធ្វើអីមិនសូវដែលបានទាន់គេទេ គ្រាន់តែថាចេះតែតស៊ូទៅ ចេះតែដូចតែថា ពេលគេរួចពីថ្ងៃទៅ គឺគេជួយម្នាក់ពីរបីអម្រែក ក៏រួច ក៏បានរួចជាមួយគេទៅ។ ពេលខ្លះទៅគេមិនជួយ ក៏ខំខ្លួនឯងទៅ ក៏រួច រួចដូចថារួចក្រោយគេ ព្រោះម៉ែត្រគូប មិនមែននេះទេ វារែកយូរៗទៅ កាន់តែដុនទៅៗ ហើយការងារនោះវាចេះតែធ្ងន់ទៅៗ កម្លាំងចេះតែខ្សោយ។

**លោក ត្រាវីស ហ្សារ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតផ្តល់ពេលវេលានេះ ជូនតំណាងសហព្រះរាជអាជ្ញាជាតិ។ សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។

[១៥:២២:០០]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ។ ខ្ញុំមានសំណួរបន្ថែមមួយចំនួនសាកសួរទៅលោក។ មុននេះ លោកបានប្រាប់ទៅតុលាការថា លោកបានទៅដល់ទំនប់ត្រពាំងថ្មនៅក្នុងឆ្នាំ៧៦ គឺនៅចុងឆ្នាំ ពេលដែលច្រូតកាត់ហើយ។ ចុះលោកចាំទេថា លោកនៅដល់ឆ្នាំ៧៧ហ្នឹង នៅពេលដែលលោកឆ្លើយថា៧៧ហ្នឹង តើនៅដើមឆ្នាំ ពាក់កណ្តាល ឬក៏ចុងឆ្នាំ? ហើយបើសិនជាមិនអាចចាំបាន សូមជួយបញ្ជាក់ផង។

**លោក ម៉ម សឿម៖**

**ឆ៖** ព្រោះនៅ ខ្ញុំជម្រាបអ៊ីចឹងថា ការចាំថ្ងៃខែ ឬក៏ គ្រាន់តែឆ្នាំទេ បើសិនតែថ្ងៃខែ ឬក៏ពេលវេលា ខ្ញុំបាទមិនចាំទេ។

**ស៖** អ៊ីចឹង៧៧ហ្នឹង នៅដល់៧៧ហ្នឹង នៅមុនចូលឆ្នាំខ្មែរ ឬក៏ចូលឆ្នាំខ្មែរហើយ ឬក៏នៅក្នុងរដូវវស្សា ពេលដែលលោកចេញទៅហ្នឹង លោកនៅចាំទេ?

**ឆ៖** ព្រោះនៅក្នុងខែ០១ ខែ០១ ឆ្នាំពីរ -- ឆ្នាំ៧៧។ បើចុងឆ្នាំ ព្រោះខ្ញុំនិយាយថាចុងឆ្នាំ។ បានន័យថា នៅឆ្នាំ៧៦នោះ គឺនៅពេលដែលខ្ញុំច្រូត ច្រូតស្រូវដណ្ដើមនៅក្នុងដើមខែ១១, ១២ ខែ០១ គេប្រមូលមកអានោះ ខ្ញុំមកធ្វើនៅក្នុងដើមឆ្នាំ៧៧ ក្នុងខែ០១។ បានន័យថា ខ្ញុំមកអាងត្រពាំងថ្មហើយ ព្រោះពេលវេលានេះ ខ្ញុំមកៗអនុវត្តនៅអាងត្រពាំងថ្ម។ ព្រោះពេលវេលាខ្ញុំវាចល័តច្រើនកន្លែង ដូច្នេះបានន័យថា ខ្ញុំជម្រាបថា ពេលដែលខ្ញុំមកពីច្រូតស្រូវថ្មពួក នៅចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ គឺខ្ញុំមកនៅក្នុងអាងត្រពាំថ្ម ធ្វើ បាទ ប៉ុណ្ណេះ។

[១៥:២៤:១៧]

**ស៖** អ៊ីចឹង ដើម្បីឲ្យមានភាពច្បាស់លាស់ អ៊ីចឹងរយៈពេលដែលលោកធ្វើការនៅៗទំនប់អាងត្រពាំងថ្មតែម្ដង ខ្ញុំនិយាយកាលអំឡុងពេលដែលធ្វើការនៅក្នុងទំនប់ហ្នឹងទេ តើរយៈពេលប៉ុន្មានខែ?

**ឆ៖** បាទ ក្នុងការធ្វើហ្នឹង បើគិតឲ្យដល់ទៅ អត់មាននេះទេ នៅឆ្នាំ -- ក្នុងឆ្នាំ៧៧ ខ្ញុំបាទនៅៗរហូតដល់ជិតចុងឆ្នាំ៧៧ បានខ្ញុំចេញ។ បានន័យថា ចង់នៅមួយឆ្នាំបណ្ដោយ។

**ស៖** ចាស សូមអរគុណ។ ចុះនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មជិតមួយឆ្នាំហ្នឹង តើប្រជាជនដែលធ្វើការនៅក្នុងទំនប់ហ្នឹងតែម្ដងហ្នឹង មាន លោកថាមានចំនួនច្រើន។ លោកស្មានបានទេថាប្រហែលជាប៉ុន្មាន? រយ ពាន់ ឬក៏ដល់រាប់ពាន់ រាប់ម៉ឺននាក់ដែរ?

**ឆ៖** បើសិនជារាប់ចំនួន ឬក៏ឲ្យខ្ញុំក្ដាប់មិនបានទេ ព្រោះមនុស្សនៅលើទំនប់ដូចផ្សារអ៊ីចឹងឯង។ វានៅតកន្ទុយគ្នាល្អឹន មានប្រវែងប៉ុន្មានគីឡូម៉ែត្រគឺនៅការដ្ឋានអាងត្រពាំងថ្មគឺនៅរហូត ប៉ុន្មានគីឡូម៉ែត្រគូបគឺនៅពេញហ្នឹង ចែកតាមតំបន់ តាមកន្លែងៗ អង្គភាពចល័ត គឺនៅចល័ត អង្គភាពប្រជាពលរដ្ឋ នៅប្រជាពលរដ្ឋ។ ដូច្នេះ បានន័យថា ការដ្ឋានអាងត្រពាំងថ្ម គឺចែកដាច់តាមផ្នែកៗ មានក្រុមចល័ត មានក្រុមសហករណ៍ មានក្រុមផ្សេងៗតាមស្រុកតាមភូមិ។ ដូច្នេះ វាដាច់ៗពីគ្នា។ ដូច្នេះ ខ្ញុំមិនអាចក្ដាប់ចំនួនរបស់ប្រជាពលរដ្ឋដែលនៅក្នុងអាងត្រពាំងថ្មបានទេ។

**ស៖** ចាស អរគុណ។ មុននេះដែរលោកបានប្រាប់ទៅតុលាការថា មានការប្រជុំទិតៀន។ អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់លោកថា តើការប្រជុំទិតៀនហ្នឹងគេធ្វើញឹកញាប់ប៉ុនណាដែរ ហើយធ្វើឡើងនៅពេលណា?

[១៥:២៦:៥៥]

**ឆ៖** បាទ ហ្នឹងខ្ញុំជម្រាប ប៉ុន្តែខ្ញុំជម្រាបម្តងហើយ។ ការទិតៀន នឹងធ្វើនៅពេលដែលដាក់ផែនការ ការងារ រួចមិនរួច គឺក្នុងនោះឯងដែលក្នុងសមាជិក ក្នុងកង ឬក៏ក្នុងក្រុម ទិតៀនទៅលើក្រុម ទិតៀនទៅលើកង ទិតៀនទៅលើបុគ្គល។ បានន័យថា គេៗចង់ឲ្យក្នុងក្រុមនោះមានសកម្មក្នុងការងារ។ បើសិនជាក្រុមនោះសកម្មនឹងការងារ ក្រុមដែលទិតៀនទៅលើបុគ្គលនោះ ឲ្យសកម្មនឹងការងារ។ ដូច្នេះ បានន័យថា គេធ្វើឲ្យបុគ្គលនោះកុំឲ្យមានសតិអារម្មណ៍ងាករេ ឲ្យធ្វើម៉េចឲ្យយកចិត្តទុកដាក់លើការងារ បាទ។

**ស៖** ចុះគេប្រជុំរាល់ថ្ងៃ ឬក៏ញឹកញាប់ប៉ុន្មានដែរ? មួយថ្ងៃ រៀងរាល់ល្ងាច ពេលណា? សូមឲ្យលោកជួយបញ្ជាក់ពីពេលវេលា។

**ឆ៖** ការប្រជុំក្នុងកងក្នុងក្រុមអត់មានកំណត់ទេ ព្រោះនេះវាជាផែនការរបស់ក្នុងកងក្នុងក្រុមទេ បើសិនថាការងារដាក់ទៅហើយខ្លាំង បានគេតាមដានហើយគេទិតៀនគ្នា តែបើសិនជាថា ក្នុងប៉ុន្មានថ្ងៃគេទិតៀន ប៉ុន្មានខែគេទិតៀនអត់ទេ នេះការងារដែលត្រូវធ្វើ គេតាមដាននៅពេលដែលធ្វើហ្នឹងឯង។

**ស៖** ចុះអ្នកណាជាអ្នកដឹកនាំការប្រជុំទិតៀនហ្នឹង?

**ឆ៖** ក្នុងការទិតៀន គឺក្នុងកង ក្នុងក្រុម ចំណុះឲ្យក្នុងកង ព្រោះគេប្រមូលប្រជុំហើយ គេណែនាំយើង។ ដូចខ្ញុំបានជម្រាបហើយថា ដូចថាធ្វើអីមួយ គឺមានកង មានអីគេសម្រាប់ណែនាំយើង គេប្រជុំ បើថាធ្វើអីមិនប្រក្រតី ធ្វើអីមិនសកម្ម គឺគេណែនាំយើងក្នុងកងរបស់ក្រុមដែលអនុវត្តនោះ។

**ស៖** មេកងមេក្រុមជាអ្នកប្រជុំទិតៀន គាត់អ្នកដឹកនាំអង្គប្រជុំហ្នឹង ឬក៏សមាជិកហ្នឹងគាត់ប្រជុំខ្លួនឯង? មានអ្នកដឹកនាំអង្គប្រជុំដែរ? មេកង មេក្រុម ឬក៏យ៉ាងម៉េច?

**ឆ៖** ពួកមេកង ពួកមេកងគេប្រជុំរួច គេឲ្យពួកមេក្រុមយើងប្រជុំបន្ថែម ប៉ុន្តែនេះជាការងាររបស់គេ គេឲ្យកងពង្រឹងក្រុម ក្រុមពង្រឹងកង ហ្នឹងតគ្នា។ បាទ ដូច្នេះវាអ៊ីចេះឯង ពង្រឹងតគ្នាដើម្បីឲ្យក្នុងក្រុមរបស់ខ្លួនយើងរឹងមាំ ឲ្យកងរបស់ខ្លួនរឹងមាំ។ ដូច្នេះ មេក្រុមគឺពង្រឹងកូនក្រុម មេកងពង្រឹងក្នុងកង បាទ។

[១៥:៣០:១៧]

**ស៖** ចាស អរគុណ។ ខ្ញុំចូលដល់ប្រធានបទថ្មីមួយទៀតទាក់ទងទៅនឹងកងករណី។ តើកងករណីហ្នឹងយ៉ាងម៉េចទៅ សូមលោកជួយពន្យល់ប្រាប់តុលាការផង?

**ឆ៖** បាទ ខ្ញុំសូមជម្រាបដែរថា ពាក្យ "កងករណី" ខ្ញុំបាទក៏មិនយល់ដែរ គ្រាន់តែថាពាក្យថា "កងករណី" គឺជាកងមួយដែលដូចថារឹងទទឹង កងមួយដែលមិនព្រមធ្វើតាមគេ ហើយគេយកទៅដាក់មួយកន្លែងដើម្បីគេៗដូចថាអ្វីដែលៗអ្នកដែលមិនស្ម័គ្រសកម្មនឹងការងារ គេមានក្រុមគេ – ក្រុមគេសម្រាប់ ណែនាំ ក្រុមគេសម្រាប់ដូចថា បើនិយាយរួម ធ្វើនៅយើងដូចថាមិនស្ម័គ្រសកម្មនឹងការងារទេ ធ្វើដូចមិនយកចិត្តទុកដាក់ទេ ដូច្នេះគេដឹងថាយើងនេះ វាមិនល្អទេ ដូច្នេះគេត្រូវបញ្ជូនទៅដាក់មួយកន្លែងទៅដើម្បីឲ្យក្រុមនោះឲ្យៗខំ ឲ្យធ្វើ បើនិយាយរួមបើថាអាៗករណីនេះ បើនិយាយភាសាមិនដឹងថាយ៉ាងម៉េចទេ គ្រាន់តែថាខ្ញុំដល់ឮថា "ករណី" ថាករណីតាមទៅ ព្រោះគេថាពួកកន្លែងដែលពិបាក។ បើគិតឲ្យដល់ទៅ ថា "កងករណី" គឺកងដែលពិបាកធ្វើ កងដែលៗយ៉ាប់ ដែលពិបាកបំផុត បានគេដាក់មួយកន្លែងសម្រាប់លត់ដំ នេះកងករណី បាទ។

**ស៖** ចុះគេធ្វើយ៉ាងម៉េចខ្លះចំពោះមនុស្សដែលនៅក្នុងកងករណីហ្នឹង?

**ឆ៖** ព្រោះថាបើគេបញ្ជូនទៅហើយ ថាអ្នកឯងចង់មិនចង់ គឺត្រូវតែចង់ ធ្វើមិនធ្វើ ត្រូវតែធ្វើ។ គឺកន្លែងនោះគេថាកន្លែងខ្លាំងតែម្តង កន្លែងគេលត់យើង គេធ្វើបាបយើង ព្រោះកងករណីវាមានកងរបស់គេផ្សេង មិនមែនកងនៅខ្ញុំទេ គ្រាន់តែថាខ្ញុំដឹងថា គេថាអ្នកឯងមិនសកម្មការងារ គេបញ្ជូនទៅកងករណី ខ្ញុំគ្រាន់ៗតែដឹងថា ឮកងករណីភ្លាមថា អ៊ូ! កងករណីនេះមិនមែនធម្មតាទេ កងករណីនេះខ្លាំងណាស់។ ដូច្នេះបានន័យថា អ្នកដែលចង់មិនចង់គឺគេបញ្ជូនទៅកងករណី។ ដូច្នេះបានខ្ញុំថាកងករណីជាកងមួយដែលពិបាកបំផុតដែលត្រូវតែៗ បើចង់មិនចង់ ក៏ត្រូវតែចង់។

[១៥:៣២:៥៦]

**ស៖** លោកថា "កងករណី" ហ្នឹងលំបាកបំផុត ហើយគេលត់ គេធ្វើបាប លោកដឹងទេថាគេធ្វើយ៉ាងម៉េចខ្លះ គេប្រព្រឹត្តយ៉ាងម៉េចខ្លះចំពោះមនុស្សនៅក្នុង "កងករណី" ហ្នឹង?

**ឆ៖** ព្រោះខ្ញុំក៏មិនបានចូលប្រឡូកនៅក្នុងកងនោះដែរ ព្រោះគ្រាន់តែអ្វីដែលគេនិយាយឲ្យខ្ញុំដឹង ហើយខ្ញុំក៏មិនដែលបានប្រឡូកនៅក្នុងកងករណីនោះដែរ គ្រាន់តែខ្ញុំដឹង បានដឹងថា និយាយត និយាយពីដូចថាគេប្រាប់ខ្ញុំថា កងករណីនេះមិនបានទេវ៉ើយ ខ្លាំងណាស់ណា តែហ៊ានថាធ្វើខុស អ្អែងដឹងតែយ៉ាប់

ហើយ គេបញ្ជូនទៅកងករណីដឹងតែយ៉ាប់ហើយ។ ដូច្នេះ បានជាខ្ញុំថាកងករណីនេះ យ៉ាប់មិនដឹងថាយ៉ាប់យ៉ាងម៉េចទេ ពិបាកយ៉ាងម៉េចទេ មិនដែលបានទៅដូចថា និយាយរួមខ្ញុំវាមិនដែលបានប្រឡូកក្នុងកងករណី ឮតែគេថាកងករណី ខ្ញុំថាច្បាស់ជាយ៉ាប់មែន មិនដឹងថាយ៉ាប់គេធ្វើបាបយ៉ាងម៉េចក៏មិនដឹងទេ។

**កញ្ញា សុង ផវ័ន្ត៖**

ចាស សូមអរគុណ សម្រាប់លោកសាក្សី សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ សូមបន្តវេទិកានេះឲ្យទៅតំណាងមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ មេធាវីនាំមុខសូមអនុញ្ញាតផ្ទេរសិទ្ធនេះជូនលោកស្រី ស៊ីន សុវ៉ន សម្រាប់សួរសាក្សីរូបនេះ ក៏ប៉ុន្តែជាបឋម ខ្ញុំបាទចង់សូមសួរលោកប្រធានដោយសារថា ល្ងាចនេះមានការចាប់ផ្ដើមសួររបស់លោកប្រធានទៅលើសាក្សី ក៏ដូចជាមានការជំទាស់ ហើយនិងការលើកសំណើផ្សេងៗរបស់ភាគី ថាតើខាងភាគី -- ដើមបណ្ដឹងរដ្ឋប្បវេណីយើងខ្ញុំមានពេល រយៈពេលប៉ុន្មាន សម្រាប់ដែលសេសសល់សម្រាប់សួរសាក្សីនេះ? សូមលោកប្រធានបញ្ជាក់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មានពេលត្រឹមម៉ោងបួនរសៀលនេះអស់ហើយ ចប់មិនចប់ក៏ត្រឹមហ្នឹង គ្មានពេលថែមទេ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន សូមគោរពលោកចៅក្រម សូមគោរពអង្គសវនាការទាំងមូល។

[១៥:៣៥:១០]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

01483206



**ស៖** ចាស សូមជម្រាបសួរដែរលោកសាក្សី។ ចាស ខ្ញុំឈ្មោះ ស៊ីន សុវ៉ន ជាមេធាវីនៅអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហើយខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។ ចាស ពេលនេះ ខ្ញុំសូមសួរសំណួរលោកមួយចំនួន ហើយសូមលោកមេត្តាសហការឆ្លើយតបនឹងសំណួរដែលខ្ញុំសួរលោកចាស។ ចាស សំណួរទី១ ខ្ញុំចង់ជម្រាបសួរលោកថា។ តើលោក -- តើទំនប់អាងត្រពាំងថ្មគេចាប់សម្ពោធក្នុងឆ្នាំណាដែរ? ហើយតើលោកមានបានចូលរួមក្នុងការសម្ពោធទំនប់អាងត្រពាំងថ្មហ្នឹងទេ?

**លោក ម៉ម សឿម៖**

**ឆ៖** បាទ នៅក្នុងការសម្ពោធអាងត្រពាំងថ្ម ខ្ញុំបាទមិនបានសម្ពោធទេ ព្រោះខ្ញុំទៅក្រោយគេ ព្រោះខ្ញុំចាប់ផ្ដើមធ្វើតែម្ដង។ បើនិយាយពីរឿង បើសិនជាសន្និបាតមាន ខ្ញុំបានចូល សន្និបាតនៅអាងត្រពាំងថ្ម។ ព្រោះសន្និបាតខ្ញុំបានចូលរួម បើថា បើសិនជា ដែលសួរសំណួរអំមិញ គឺខ្ញុំមិនដែលបានចូលនោះទេ ព្រោះចាប់ផ្ដើមបើក ខ្ញុំមិនទាន់បានចូលទេ ព្រោះខ្ញុំអត់ទាន់បានមកចូលទេ ព្រោះគេរៀបចំមុន។

**ស៖** ចាស អរគុណ។ ចាស អ៊ីចឹងប្រហែលជាសន្និបាត មិនមែនជាការសម្ពោធទេអ៊ីចឹង។ ចាស ចុះហេតុអ្វីដែរបានជាពេលក្នុងសន្និបាតហ្នឹងគេឲ្យពលករៗ ដែលធ្វើការនៅក្នុងទំនប់អាងត្រពាំងថ្មហ្នឹង ពលករដែលធាត់ៗគេឲ្យឈរខាងមុខ ដើម្បីធ្វើសន្និបាត ហើយអ្នកស្គមៗនៅខាងក្រោយ។ តើលោកមានការកត់សម្គាល់ម៉េចដែរបានគេធ្វើរបៀបហ្នឹង?

[១៥:៣៧:២៩]

**ឆ៖** ដូចរូបខ្ញុំបាទផ្ទាល់ ខ្ញុំជម្រាបជូនថា នៅពេលដែលគេសន្និបាតម្ដងៗ គេតែងតែប្រជុំធំៗ ហើយពេលនោះគេមិនសូវយកអ្នកស្គមៗឈរពីមុខទេ ហើយគេយកអ្នកល្អ អ្នកធាត់ៗ ដូចខ្ញុំបាទអីតែងឈឺហើមអី ស្គមអី គេ ដូចថាជួរមានពីរ មានបីអ៊ីចឹង គេឲ្យយើងឈរបន្ទាប់ពីក្រោយគេអ៊ីចឹងទៅ។ ព្រោះអានេះវាជារឿងមួយ មិនដឹងថាគេម៉េចទេ គ្រាន់តែថា ខ្ញុំចាប់អារម្មណ៍ខ្លួនខ្ញុំថា ពេលអ្នកឯងបរោគេមិនឲ្យឈរមុខទេ បរោវាលំបាកណាស់ វាពិបាកគេមើល។ ដូច្នេះ ខ្ញុំនៅក្រោយគេ ព្រោះមនុស្សបរោគេអត់ដែលឲ្យនៅមុខ។

**ស៖** ចាស អរគុណ។ ចាស ខ្ញុំជម្រាបសួរលោកបន្តទៀតថា ក្នុងពេលដែលសន្និបាតហ្នឹង តើអ្នកណាជាអធិបតីក្នុងពេលសន្និបាតហ្នឹង?

**ឆ៖** បាទ ក្នុងពេលសន្និបាតហ្នឹងនៅក្នុងតំបន់ និងគណៈតំបន់ៗ គេឈ្មោះ ដូចនៅតំបន់៥ មាន

ដូចឈ្មោះតាជាល – ឈ្មោះ តាជាល គាត់នៅក្នុងការប្រជុំសន្និបាតហ្នឹង គាត់មកបង្ហាញ គាត់ឡើងសុន្ទរកថាអី ជូនដល់ពួកចល័តក្នុងការដ្ឋាននោះ។

**ស៖** ចាស អរគុណ។ ចាស ចុះឈ្មោះតា មូល សម្បត្តិ ហ្នឹងជានរណាដែរលោកមានដឹងទេ?

**ឆ៖** បាទ តា មូល សម្បត្តិ នេះគ្រាន់តែ ខ្ញុំមិនមែនជាអ្នកស្គាល់គាត់ទេ ក៏ប៉ុន្តែជាដូចថាអ្នកក្រៅៗ គេនិយាយថា តា មូល សម្បត្តិៗ គាត់ជាអ្នកប្រធានភូមិភាគ។ ខ្ញុំគ្រាន់តែឮតាមមិត្តភក្តិនិយាយប្រាប់ថា តាភូមិភាគ ក៏មិនដឹងថាគាត់មុខម៉េចអីម៉េច ខ្ញុំមិនដែលស្គាល់គាត់ មិនបានស្គាល់គាត់ផង។

**ស៖** ចាស សូមអរគុណ។ ចាស ចុះពេលដែលសន្និបាតហ្នឹង តើគណៈអធិបតី គេមាននិយាយពីគោលបំណងនៃការលើកទំនប់អាងត្រពាំងថ្មក្នុងគោលបំណងអីទេ ប្រាប់ឲ្យពលករយើងហ្នឹង?

[១៥:៤០:០២]

**ឆ៖** គោលបំណងរបស់ -- កាលនោះគឺគេដាក់ពាក្យស្រុកស្រេចតើ ថាធ្វើស្រែ គឺឲ្យបានប៉ុន្មានតោនហើយ ប្រជាជនត្រូវហូបឲ្យបានប៉ុន្មានដង ហើយមានផែនការ -- បើនិយាយរួម គេធ្វើការផ្សព្វផ្សាយ ឲ្យប្រជាពលរដ្ឋ ថាអត់ឲ្យប្រជាពលរដ្ឋភ័យទេ។ ស៊ីគ្រប់គ្រាន់មានប្រព័ន្ធប្រឡាយធ្វើស្រែក្នុងមួយឆ្នាំ ឲ្យបានប៉ុន្មានតោនៗ នេះជាដូចថា លើកទឹកចិត្តអ្នកដែលទៅសន្និបាត។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងការបោសសម្អាត។ តើការបោសសម្អាតពី ដែលបន្តបន្ទាប់ពីថ្នាក់លើ រហូតដល់ថ្នាក់ក្រោមហ្នឹង តើលោកដឹងពីការបោសសម្អាតហ្នឹងលោកដឹងពីណាដែរ?

**ឆ៖** ព្រោះការបោសសម្អាតនេះ ខ្ញុំដឹងតាមរយៈ ព្រោះក្នុងកងនីមួយៗគេកំពុងតែភ័យ ដល់ពេលគ្នាដឹងនាំទៅ ឮថាពួកកងនិរតីចុះមក ស្រាប់តែបាត់ម្តងមួយៗៗទៅ ហើយកងចល័តប្រធានកងប្រធានអីចេះតែរត់បាត់បណ្តើរៗ ដល់តិចទៅចេះតែខ្សឹបតៗគ្នាទៅ។ ដល់ពេលអ៊ីចឹងទៅ រហូតក្នុងតំបន់ក្នុងកង ក្នុងក្រុមចល័តដែលខ្ញុំបាននិយាយរួចហើយ ដល់ពេលអ៊ីចឹងទៅ បាត់ប្រធានកង ប្រធានអ្នកដឹកនាំបណ្តើរៗទៅ វាចូលដំណើរពួកខ្ញុំដែលតូចតាចហ្នឹងភ័យខ្លួនដែរ រត់ដូចគេដែរទៅ។ បានខ្ញុំតែងជម្រាបថា រឿងត្រង់នេះឯងដែល គេថាបើសិនគេថាគេធ្វើ គេថាបោសៗពីលើដល់ក្រោម ទាល់តែអស់។ នឹកឃើញថាអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនោះ ប្រហែលជាដូចថាត្រូវបាត់ៗខ្លួន។ ដូច្នេះ បានខ្ញុំថាដូច្នោះហើយអ្នកដែលធ្វើប្រធានកងធំ កងតូច ឬក៏ធ្វើជាស្អីៗបាត់ខ្លួន។ ដល់ពេលនោះស្រាប់តែប្រធានឃើញបាត់ប្រធានបណ្តើរៗទៅ បាននឹកឃើញ អ៊ូ! រឿងនេះមិនស្រួលទេ ពួកដែលកង ដូចថាកងនិរតី?

បាទកងនិរតីបាទ ខ្ញុំមិននេះទេ គ្រាន់តែថាស្គាល់តែកងនិរតី ព្រោះវាផ្លាស់មុខ។

[១៥:៤២:៣៨]

**ស៖** ចាស សូមអរគុណ។ ចាស អ៊ីចឹង ពាក្យដែលលោកនិយាយថា "បាត់ខ្លួនជាបន្តបន្ទាប់" ហ្នឹង បាត់ខ្លួនហ្នឹងបាត់ដោយគេរត់ ឬក៏បាត់ដោយស្លាប់? ចាស សូមលោកបញ្ជាក់ជូនអង្គសវនាការ។

**ឆ៖** បាទ បាត់ហ្នឹងមិនមែនបាត់រស់ទេ បាត់នោះបាត់លើយ បាត់រកនិយាយគ្នាមិនឃើញមិនដឹងទៅឯណាទេ។ ព្រោះអ្នកដែលកងៗនៅជាមួយដែលថាធ្លាប់ ដូចថាស្គាល់ថាអីហ្នឹង ក៏មិនដឹងជានៅឯណា បាត់ទៅលើយៗៗៗបណ្តោយ។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់ជម្រាបសួរលោកបន្តដែរពាក់ព័ន្ធនឹងពលករនៅអាងត្រពាំងថ្ម។ តើពលករនៅអាងត្រពាំងថ្មទាំងអស់ ទាំងលោក និងពលករផ្សេងៗ តើមានរបបនៃការឈប់សម្រាកប្រចាំខែ ឬក៏ប្រចាំឆ្នាំទេ?

**ឆ៖** បាទ ចំពោះកងខ្ញុំបាទ ដូចគ្មានឈប់ទេ ព្រោះម៉េចបានថាមិនឈប់ ព្រោះយើងសូម្បីតែបើយើងមិនបាននេះ យើង បើសិនថាយើងលើកទំនប់រួចហើយ យើងត្រូវជួសជុលថែ ដូច្នេះគ្មានពេលឈប់ទេ។ តែបើប្រជាពលរដ្ឋ គាត់លើកមួយសាឲ្យរួចទៅ គាត់អាចទៅនៅតាមភូមិវិញ។ ដោយឡែកចំពោះខ្ញុំដែលនៅនឹងទំនប់ បើគេរួចហើយដើរជួសជុលធ្វើស្ពាន ដូចថាអត់ទៅណាបានទេ ព្រោះយើងប្រចាំនៅកន្លែងនោះតែម្តង។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់សួរលោកបន្តទៀត តើនៅក្នុងការដ្ឋានទំនប់អាងត្រពាំងថ្មហ្នឹង តើធ្លាប់ដែលមានគ្រោះថ្នាក់ពលករដែលធ្វើការនៅនោះ ដូចជាការគ្រោះថ្នាក់ ដូចជាការកាប់ដីត្រូវនឹងចប ទី១, ទី២ ដូចជាការបាក់ទំនប់ឬក៏បាក់ដី ឬក៏ទឹកបុកមកខ្លាំងហ្នឹង មានពលករស្លាប់ទេ នៅពេលដែលពលករកំពុងតែធ្វើការនៅការដ្ឋានទំនប់អាងត្រពាំងថ្មនោះ?

[១៥:៤៥:០០]

**ឆ៖** បាទ នៅពេលកាលធ្វើនៅអាងត្រពាំថ្ម បើនិយាយដូចរូបខ្ញុំដែលអនុវត្តនៅនោះផ្ទាល់ គឺអត់មានឃើញមានបញ្ហាអីទេ អត់មានអីទេ ព្រោះម៉េចបានថាអ៊ីចុះ? ព្រោះការងារ ការឡើង ការដឹងមុនហើយ ទប់ស្កាត់មិនឲ្យគ្រោះថ្នាក់បានទេ ដូចថាអាងនោះបាក់អ៊ីចេះទៅ នាំគ្នាទៅដេកនៅលើទំនប់ទៅជីកទាំងយប់ទៅ ធ្វើបិទ ដេកប្រចាំនៅកន្លែងនោះតែម្តង ការពារ។ ដូច្នេះបានន័យថា អ្វីដែលធ្វើ គឺគិតស្រេចរួច បានចាប់ផ្តើមធ្វើ ហើយមិនឲ្យមានបញ្ហាគ្រោះថ្នាក់អីកើតឡើងទេ។ នេះពួកដែលក្នុងកងដែល

យើងខ្ញុំដែលនៅប្រចាំនោះ គឺមិនមានគ្រោះថ្នាក់។ ហើយដោយឡែក ក្រុមកងផ្សេង ក៏យើងខ្ញុំក៏មិនអាចដឹងថាយ៉ាងម៉េច ពីព្រោះវាផ្សេងៗគ្នា ហើយវាច្រើន មិនអាចក្តាប់បានទេ។

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់សួរលោកបន្តទៀតថា តើពលករទាំងអស់ ដែលធ្វើនៅលើទំនប់អាងត្រពាំងថ្មហ្នឹង ពួកគេហ្នឹងមានការពេញចិត្ត សប្បាយរីករាយក្នុងការលើកទំនប់អាងត្រពាំងថ្មហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

កុំអាលទាន់ឆ្លើយតប!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសាក្សីអាចនិយាយថា គាត់សប្បាយ ឬមិនសប្បាយ ប្រហែលជាគាត់និយាយជាមួយនឹងសមាជិកកងរបស់គាត់ថា សប្បាយពេលនោះ ប៉ុន្តែគាត់មិនអាចឆ្លើយជំនួសឲ្យមនុស្សរាប់រយពាន់នាក់ ដែលថាគេសប្បាយ មិនសប្បាយបានទេ។ ដូច្នេះខ្ញុំសូមឲ្យមេធាវីសួរអំពីការដឹងពិតប្រាកដ ពីសំណាក់សាក្សីរូបនេះ។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។ ខ្ញុំនឹងរៀបសំណួរសាជាថ្មីចាស។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចំពោះលោក តើលោកពេញចិត្ត ឬក៏លោកសប្បាយចិត្ត ក្នុងការលើកទំនប់អាងត្រពាំងថ្មហ្នឹងទេ?

**លោក ម៉ម សឿម**

**ឆ៖** បាទ ខ្ញុំសូមជម្រាបចុះថា ការលើកវាគិតឲ្យដល់ទៅ ប្រជាពលរដ្ឋដល់យើង -- និយាយរួមដោយឡែកយើងខ្ញុំផ្ទាល់ ដូចថា ថាមិនពេញចិត្តបណ្តោយ ព្រោះវាមើលទៅ វាមិនដែលជួបប្រទះ ដល់ពេលអ៊ីចឹងទៅវាមិនអាចថាពេញចិត្ត។ ប៉ុនមិនពេញចិត្ត ក៏ត្រូវតែពេញចិត្ត ត្រូវតែធ្វើ រឿងហ្នឹងវាមិនពេញចិត្ត ក៏ត្រូវតែធ្វើ។ បើគិតតែគិតមិនពេញចិត្ត ក៏ត្រូវតែធ្វើ រឿងវាត្រឹមប៉ុណ្ណឹងឯង វាគិតមិនចេញទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:៤៧:៥២]

**ស៖** ចាស១ សូមអរគុណ ចាស។ តាមការកត់សម្គាល់របស់លោកកន្លងមក ខ្ញុំចង់ជម្រាបសួរថា តើកន្លងមកហ្នឹង មានគណៈប្រតិភូ ដូចជាគណៈប្រតិភូចិន ឬក៏មេដឹកនាំជាន់ខ្ពស់ធំៗហ្នឹង ដែល -- ពួកគាត់ដែលមកចូលទស្សនកិច្ចនៅទំនប់អាងត្រពាំងថ្មហ្នឹងដែរ លោកដែលឃើញទេ?

**ឆ៖** បាទ ឃើញ ៗមានតើ ឃើញមានពួកក្រុមចិនដែលៗ ខ្ញុំបាទមិនដែលស្ទូវស្គាល់ពួកបរទេសដល់ពេលឃើញមក ធំៗធាត់ៗ មកថតខាងក្រោមអាងក្រោមអី ថតសកម្មភាព ថតទំនប់ថតអី។ មកបរឡានមក ចុះមកថតចុះអី។

**ស៖** ចាស សូមអរគុណ។ ចុះកន្លងមក ដែលមានខាងអ្នកភាពយន្តគេចុះថតភាពយន្ត ចុះថតកុននៅតំបន់អាងត្រពាំថ្មហ្នឹង ថតជាខ្សែភាពយន្តនៅនឹងកន្លែងនុ៎ង? មានទេលោក?

**ឆ៖** រឿងថត រឿងអី ខ្ញុំបាទមិនដឹងទេៗ។

**ស៖** សូមអរគុណ។ ចាស អ៊ីចឹងខ្ញុំចូលប្រធានបទថ្មី ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំនៅទំនប់អាងត្រពាំថ្ម។ ចាស តាមការកត់សម្គាល់របស់លោក ពីព្រោះថាអាងទំនប់អាងត្រពាំងថ្ម បានចាប់ផ្ដើមចុងឆ្នាំពីរ -- ចុងឆ្នាំ១៩៧៦ និងបញ្ចប់នៅឆ្នាំ១៩៧៧ ហើយយើងឃើញហើយថាតាមកំណត់ហេតុរបស់លោកឃើញហើយថា កម្លាំងដែលធ្វើការនៅក្នុងអាងត្រពាំថ្ម ជាកម្លាំង១វ័យកណ្ដាល ជាកម្លាំងយុវជន កម្លាំងយុវនារី និងកម្លាំងកុមារដែរ ប៉ុន្តែមួយចំនួនតូច។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកថា តាមការកត់សម្គាល់របស់លោក ឬលោកដែលបានឃើញទេ កន្លងមកដែលបានឃើញថា ពលករដែលជាយុវជន យុវនារី ដែលមានធ្លាប់រៀបការនៅក្នុងទំនប់អាងត្រពាំងថ្មហ្នឹងទេ?

**ឆ៖** បាទ បើនិយាយពីរឿងរៀបការមាន មានច្រើនគូណាស់ ម្ដងៗមានរាប់សិបគូ រាប់មិនអស់។ ខ្លះការរួចមិនស្គាល់ប្រពន្ធខ្លួនឯង មិនដឹងឯណាប្ដី ឯណាប្រពន្ធ ចេញវង្វេងគ្នា។ មានៗនៅក្នុងអាងត្រពាំងថ្ម មានរៀបការ។

[១៥:៥០:៤៦]

**ស៖** អរគុណ។ ដែលលោកជម្រាបថា រៀបការច្រើនរាប់សិបគូ។ លោក១អាចគិតឡើងវិញមើល តើចាប់ពីប៉ុន្មានគូឡើងទៅ ១០, ២០, ៣០, ១០០, ១៥០ ឬក៏ម៉េចដែរ ចាស?

**ឆ៖** បាទ ខ្ញុំមិនបានរៀបការនឹងគេនោះដែរ ខ្ញុំគ្រាន់បានទៅមើលគេ រឿងថាប៉ុន្មានគូ១មិនដឹងដឹងតែថាឃើញគេរៀបការច្រើនហើយ ខ្ញុំមិនបានរៀបការនឹងគេដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ចាស សូមអរគុណ។ តាមការសង្កេតរបស់លោក ដែលលោកបានជម្រាបអង្គសវនាការអម្បាញ់មិញលោកថា មានអ្នកខ្លះមិនស្គាល់មុខគ្នាក្រោយពេលរៀបការ រៀបការហើយ។ អ៊ីចឹង ខ្ញុំចង់សួរលោកបន្តថា តើមានពលករជាយុវជន យុវនារី ដែលអង្គការតម្រូវ ឬអង្គការផ្សំផ្គុំឱ្យធ្វើជាគូស្វាមីភរិយានឹងគ្នាហ្នឹង មានគូណាដែរប៉ានប្រកែកមិនព្រមទទួលគូដែលអង្គការផ្សំផ្គុំហ្នឹងទេ?

**ផ៖** បាទ នៅក្នុងការរៀបការមាន មានបង្ខំ។ ឧបមាថាក្នុងយុវជនស្រឡាញ់នារីមួយ ដូច្នេះអត់បាននិយាយទេ ក៏ប៉ុន្តែគេអាចបង្ខំឱ្យនារីនោះរៀបការជាមួយយុវជននោះ ក៏ប៉ុន្តែរៀបបាន ក៏ប៉ុន្តែដល់ពេលមកចុងក្រោយគឺអត់បាននៅជាមួយគ្នាទេ។ គេដូចថាព្រាត់ប្រាសគ្នា វាអាចទៅជាខុសនឹងច្បាប់ វាអាចដូចថាបែកបាក់គ្នា ឬក៏គ្រោះថ្នាក់ដូចជាស្លាប់ក៏មាន ព្រោះធម្មតាមនុស្សមិនស្រឡាញ់គ្នាឱ្យរៀបការ។ នៅសម័យនោះ គឺភាគច្រើន ច្រើនតែបង្ខំ បើត្រូវគ្នាអត់សួរអីទេ ច្រើនតែបង្ខំ ហើយនៅពេលដែលខ្ញុំចង់និយាយថា ដែលភ្លេចមុខគ្នានេះ ម៉្យាងគឺច្រើនថា នៅពេលដែលរៀបការរួច ចេញមកគឺអត់មានភ្លើង ហើយកន្លែងដែលស្នាក់នៅដែលក្រុមគ្រួសារដែលបានរៀបហើយហ្នឹង ក៏មិនដឹងទៅដេកកន្លែងណា។ ដូច្នេះ មកវាបែកបាក់គ្នាទៅ យើងច្រឡំរបស់គេ គេច្រឡំរបស់យើង។ នេះចំពោះបងប្អូនខ្ញុំដែលគាត់បានរៀបការ ហើយគាត់និយាយប្រាប់ខ្ញុំ បាទ។

**ស៖** ចាស សូមអរគុណ។ អ៊ីចឹង ដែលលោកនិយាយថាច្រឡំគូ ច្រឡំដោយសារអត់មានភ្លើង។ អ៊ីចឹង លោកចង់មានន័យថា ការរៀបការហ្នឹង រៀបការនៅពេលយប់មែនទេលោក?

**ផ៖** បាទៗ រៀបការនៅពេលយប់។

[១៥:៥៣:២៣]

**ស៖** ចាស សូមអរគុណ។ ចុះគូស្វាមីដែលក្រោយពេលរៀបការហើយ ឧទាហរណ៍ដូចជាពួកគាត់ហ្នឹងមិនព្រមរួមដំណេកជាមួយគ្នាជាប្តីប្រពន្ធ។ តើលោកមានការសង្កេតឃើញថា តើពួកគាត់ហ្នឹងបានជួបហេតុការណ៍អីទេ?

**ផ៖** បាទ ចំពោះក្នុងបញ្ហារៀបការហើយ បើបុគ្គល ឬក៏យុវជននារីដែលមិនស្ម័គ្រគ្នា ដែលមិនពេញចិត្តនឹងគ្នា វាអាចគ្រោះថ្នាក់ដល់ទៅស្លាប់។ ទី១ គឺយើងមិនគោរពច្បាប់របស់អង្គការ អង្គការចាត់តាំង។ បានន័យថា គេស្នើឱ្យយើងបានជាប្តីប្រពន្ធ យើងមិនព្រមធ្វើតាម។ ដូច្នេះ វាអាចស្លាប់ភាគីបុរសក៏អាចស្លាប់បើសិនជាមិនតាម តែបើសិននារី ខាងនារីមិនស្ម័គ្រ ឬមិនពេញចិត្តក៏អាចស្លាប់នារី។ ដូច្នេះ បានន័យថា ក្នុងបញ្ហារៀបការនៅពេលនោះ វាមានបញ្ហាកើតឡើង មាន។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01483212



**ស៖** ចាស អរគុណ។ ចាស ពាក្យដែលលោកនិយាយថា "បើយើងមិនស្ម័គ្រគឺត្រូវតែស្លាប់" ហ្នឹង ចុះការដែលថា ដែលគេដឹងៗថាយើងមិនព្រមរួមដំណេកជាមួយគ្នា ដឹងដោយសារអី ដោយសារឈ្លបគេឈ្លបមើលពេលយប់ឬក៏យ៉ាងម៉េចដែរ? ចង់សូមលោកបញ្ជាក់ចំណុចហ្នឹងឲ្យបានច្បាស់បន្តិចចាស។

**ឆ៖** ធម្មតាក្នុងសម័យនោះ គេធ្វើអ្វីគេចង់លម្អិត គេចង់តាមដានណាស់ គេមិនៗអាចមើលស្រាលបានទេ ដូច្នេះបានន័យនារីតាមនារី យុវជនតាមយុវជន ដើម្បីក្តាប់បាននូវអ្នកដែលត្រូវ មិនត្រូវគេចង់ដឹង ព្រោះបានន័យថាបើសិនជាមិនត្រូវគ្នា ផ្នែកនារីដឹងខាងនារី ផ្នែកបុរស -- ផ្នែកយុវជនដឹងខាងយុវជន ដូច្នេះបានន័យថាគេតាមដានទាំងសងខាង ដើម្បីងាយស្រួលអ្នកទាំងពីរត្រូវគ្នាមិនត្រូវ។ នេះបានន័យថាវាហេតុការណ៍ដឹងតាមរយៈការតានដាននៅពេលរៀបការរួច។ ដូច្នេះបានន័យថាគេចមិនបានទេនៅក្នុងការរៀបការនោះ។

[១៥:៥៥:៤៦]

**ស៖** ចាស អរគុណ។ អ៊ីចឹងតាមការកត់សម្គាល់របស់លោក ក្រោយពេលដែលយុវជន យុវនារីដែលអង្គការផ្សំផ្គុំហើយហ្នឹង ពេលយប់ហ្នឹងដែលមានឈ្លបគេឈ្លបតាមដានមើល តើពួកគាត់ព្រមរួមដំណេកជាមួយគ្នា ឬក៏មិនព្រមទេ លោកដែលបានសង្កេតឃើញទេ?

**ឆ៖** បាទ អារឿងត្រង់នេះ ខ្ញុំមិនអាចជម្រាបបាន ព្រោះខ្ញុំមិនបានចូលជ្រៅក្នុងបញ្ហាអ្នកដែលរៀបការនៅពេលនោះ ខ្ញុំមិនអាចទៅជិតគេបាន។

**ស៖** ចាស អរគុណ។ ចាស អ៊ីចឹងខ្ញុំសូមសួរលោកមួយសំណួរទៀតចាស ហើយខ្ញុំចង់សួរលោកថាតើលោកធ្លាប់ដែលបានសង្កេតឃើញមានករណីរំលោភសេពសន្ថវៈក្រៅការរៀបការដោយបង្ខំហ្នឹងនៅក្នុងទំនប់អាងត្រពាំងថ្ម តើមានករណីចាប់រំលោភស្ត្រីនៅទីនោះទេ?

**ឆ៖** បាទ នៅកន្លែងនោះ ខ្ញុំបាទ ដូចៗខ្ញុំជម្រាបអ៊ីចឹងថាខ្ញុំដូចមិន--

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញលោកស្រីមេធាវី!

[១៥:៥៨:៥៤]

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោកបន្ត។ តាមការសង្កេតរបស់លោក តើលោកធ្លាប់ដែលឃើញមានករណីរំលោភសេពសន្ថវៈ ឬដែលក្រៅចំណងអាពាហ៍ពិពាហ៍ ឬក្រៅការរៀបការដោយបង្ខំនៅៗក្នុងទំនប់អាងត្រពាំងថ្មទេលោក?

**ឆ៖** បាទ ខ្ញុំមិនដែលបាននេះទេ បើនិយាយរួមមិនដែលបានឃើញបានអីទេ និយាយទៅមិនដែលបានជួបប្រទះ។

**ស៖** ចាស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បញ្ហាបកប្រែភាសាទៀតហើយ បញ្ហាប្រព័ន្ធសំឡេង។ ខាងៗបកប្រែភាសាអត់មានទេ ភាសាបារាំងអត់មានទេអំមិញ។

បាទ អញ្ជើញតទៀត! អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមឆ្លៀតពេលនិយាយដើម្បីនិយាយពីបញ្ហាសំណួរចុងក្រោយ ដែលសាក្សីបានឆ្លើយរួចមកហើយ ក៏ប៉ុន្តែគឺចម្លើយហ្នឹងវានៅខាងក្រៅវិសាលភាព។

**សួរដោយលោកស្រី ស៊ីន សុវ៉ែន៖**

**ស៖** ចាស សូមអរគុណ។ ចាស ខ្ញុំចង់សួរលោកបន្តពាក់ព័ន្ធនឹងការទស្សនកិច្ចរបស់គណៈអធិបតី។ ក្រៅពីការទស្សនកិច្ចដែលថាគណៈអធិបតីចិនចូលរួមទស្សនកិច្ចថត និងមើលទំនប់អាងត្រពាំងថ្ម តើមានមេដឹកនាំជាតិយើងហ្នឹង មេដឹកនាំ ឬក៏ថ្នាក់ដឹកនាំធំៗជាតិយើងដែលបានមកទស្សនកិច្ចនៅអាងត្រពាំងថ្មទេលោក?

**លោក ម៉ម សឿម៖**

**ឆ៖** ខ្ញុំមិនស្គាល់ទេ មិនដឹងនិយាយថាស្មានត្រូវទេ ឃើញតែឡាន ក៏មិនដែលស្គាល់គេអ៊ីចុះ។

**ស៖** ចាស អរគុណ។ ចុះលោកដែលបានសង្កេតមើល តើលោកមានបានសង្កេតមើលឃើញលោក ខៀវ សំផន ដែលពេលនេះលោកបានមើលឃើញ កាលពីមុនគាត់នៅក្មេង ដល់បច្ចុប្បន្នគាត់ចាស់ តើលោកមើលមុខប្រហែលៗគាត់ដែលបានធ្លាប់ទៅទស្សនកិច្ចនៅទំនប់អាងត្រពាំងថ្មទេចាស?

[១៦:០១:៣៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប! អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

ក្នុងដំណាក់កាលនេះ ខ្ញុំមិនដឹងថា តើខ្ញុំត្រូវជំទាស់ ឬក៏យ៉ាងម៉េច។ សាក្សីគាត់ឆ្លើយថា គាត់មិន <មិនស្គាល់មេដឹកនាំកំពូលៗនោះទេ។ គាត់មិន>ដឹងថា <មានអ្នកណាម្នាក់>មកទស្សនកិច្ចទេ ហើយមេធាវីក៏បានរៀបសំណួរថា តើបានឃើញលោក ខៀវ សំផន ឬក៏អត់? ដូច្នេះ សំណួរនេះ បើសិនសួរបែបនេះ ខ្ញុំសូមជំទាស់ ហើយបើគាត់នៅតែសួរបែបនេះទៀត ខ្ញុំសូមឱ្យគាត់ចូលទៅសំណួរសារធាតុទៅ ព្រោះថាគាត់នៅសល់ពេលវេលាតិចណាស់។

**លោកស្រី ស៊ីន សុវ៉ាន៖**

សូមអរគុណ។ ខ្ញុំអស់សំណួរហើយ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ ចាស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

លោក វ៉ិចទ័រ កូប៉េ អង្គជំនុំជម្រះដូចជាមានភាពមិនទាន់ច្បាស់លាស់ ដើម្បីសម្រួលដល់ការពិនិត្យពិចារណារបស់អង្គជំនុំជម្រះលើសំណើសុំរបស់លោកមេធាវីដែលពាក់ព័ន្ធនឹងឯកសារ ស៊ី.ឌី.ខេម ដែលលោកបានលើកឡើងនៅថ្ងៃនេះ ដើម្បីឱ្យអង្គជំនុំជម្រះនឹងមានមូលដ្ឋានក្នុងការពិចារណាលើបញ្ហានេះឱ្យបានច្បាស់លាស់ អង្គជំនុំជម្រះសូមឱ្យលោកផ្ដល់នូវបញ្ជីឯកសារទាំងនេះ រួមទាំងលេខ ERN ផងមកអង្គជំនុំជម្រះតាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៅរសៀលនេះ នៅល្ងាចនេះ ដើម្បីអង្គជំនុំជម្រះមានការពិនិត្យពិចារណា ដោះស្រាយបញ្ហានេះឱ្យបានទាន់ពេលវេលានៅថ្ងៃស្អែក។

[១៦:០៣:១៧]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានគឺថាក្នុងរយៈពេលប្រាំនាទីទៀត គឺយើងនឹងបញ្ជូននូវសារអេឡិចត្រូនិករួមជាមួយនឹងឧបសម្ព័ន្ធ។ ដូច្នេះ ខ្ញុំគិតថាយ៉ាងយូរប្រាំនាទី <ឬដប់នាទី>ទៀត អង្គជំនុំជម្រះនឹងទទួលបានអ៊ីម៉ែលហើយមានឧបសម្ព័ន្ធស្រេចនៅក្នុងហ្នឹងតែម្ដង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**អ្នកបកប្រែ៖**

លោកប្រធាន លោកចៅក្រមគាត់អត់បើកមីក្រូ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ តើលោកអាចបញ្ជាក់បានទេ ឯកសារដែលពាក់ព័ន្ធនឹង គឺឯកសារ <E353.1>ហ្នឹងមែនទេ? ប្រសិនបើមែននោះគឺថា ឯកសារនេះគឺយោងទៅលើចម្លើយ៦៦របស់ ស៊ី.ឌី. ខេម។ ហើយវាមិនមានបញ្ជាក់អំពីលេខយោង ERN ឬក៏លេខ E3 ដែលប្រហែលជាអាចចាត់ចូលហើយនោះទេ។ ដូច្នេះហើយបានជាយើងចង់បានការបញ្ជាក់ឲ្យច្បាស់ពីលោកបន្ថែមទៀត។

[១៦:០៤:៣៣]

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំសូមអភ័យទោស ខ្ញុំមានឯកសារ៦៦ <ទាំងអស់ហ្នឹង គឺមានលេខទាំងអស់។> ដូច្នេះសូមលោកចៅក្រមមេត្តាអនុញ្ញាតអានលេខ<> មួយសាទៀត ខ្ញុំចាំអត់ទាន់អំមិញ។

**<កញ្ញា អង់តា ហ្គីសសេ៖>**

ដើម្បីបំភ្លឺឲ្យច្បាស់ សហភាតារបស់ខ្ញុំបានបញ្ជាក់ថា ឯកសារហ្នឹងកំពុងតែរៀបចំ គាត់កំពុងតែធ្វើការស្រាវជ្រាវទៅលើឈ្មោះដែលលោកចៅក្រមបញ្ជាក់ហ្នឹង ហើយស្វែងរកនៅក្នុងហ្វាយឡេប នូវឈ្មោះដែលពាក់ព័ន្ធទៅនឹងចម្លើយទាំងអស់ហ្នឹង ហើយយើងឃើញថា ចម្លើយទាំងអស់ហ្នឹង គឺថាមានតែមួយភាសា ហើយមានលេខ E3។ អ៊ីចឹងវាមិនមែន<បញ្ជីមួយដែល>ភ្ជាប់ទៅនឹងឯកសារដែលលោកចៅក្រមលើកឡើងទេ <វាគឺជាបញ្ជីមួយដែលរៀបចំឡើងដោយ>ខាងក្រុម នួន ជា។ <ហេតុដូច្នេះហើយបានជាខ្ញុំឡើងកាត់ផ្តាច់ ហើយនិយាយឲ្យច្បាស់ជាភាសាបារាំង ដោយសារយើងយោងទៅលើស្ថានភាពមុនហ្នឹង។ ដូច្នេះ>នេះគឺជាការបំភ្លឺ បញ្ជីនេះគឺបញ្ជីដែលធ្វើឡើងដោយក្រុមមេធាវី នួន ជា បន្ទាប់ពីគាត់ធ្វើការស្រាវជ្រាវហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំកត់សម្គាល់ថា យើងប្រហែលជាត្រូវការពេលវេលាមួយថ្ងៃពេញ ដើម្បីឲ្យបានច្បាស់អំពីសំណើដែលលើកឡើងជូនអង្គជំនុំជម្រះនោះ។

**លោក វិចទ័រ កូប៉េ៖**

នេះ គឺជាឯកសារទាំងអស់ដែលយើងគ្រោងនឹងផ្ញើជូនអង្គជំនុំជម្រះ ហើយវាទាំងអស់នេះ គឺជាឯកសារ<>ទាំង៦៦ មានទាំងលេខ<ឯកសារដើម គឺ> E305 និង<បន្ទាប់មក គឺដាក់លេខ> E3។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយ<កូឡោន>បន្ទាប់ គឺយើងបានបញ្ជាក់ថា<ឯកសារទាំង៦៦ហ្នឹង> គឺមានតែ <១៣>ឯកសារទេ ដែលបកប្រែជាភាសាអង់គ្លេស។ ដូច្នេះ ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយថាក្នុងរយៈពេល ប្រាំនាទីទៀតខ្ញុំនឹងបញ្ជូនអ៊ីម៉ែលជូនទៅអង្គជំនុំជម្រះ <អំពីតារាងអ៊ិចស្សែលបញ្ជាក់អំពីឯកសារណាខ្លះបានបកប្រែរួចហើយ>។

[១៦:០៦:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ សវនាការថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៩ ខែកក្កដា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ម៉ម សឿម ហើយបន្ទាប់មក បន្ទាប់ពីស្ដាប់សាក្សី ម៉ម សឿម អង្គជំនុំជម្រះនឹងធ្វើសវនាការផ្ដើមស្ដាប់សក្ខីកម្ម សាក្សីដែលមានរហស្សនាម 2-TCW-866 ពាក់ព័ន្ធនឹងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណ លោក ម៉ម សឿម ដំណើរការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ ឥឡូវនេះលោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ និងសូមឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួម សវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការ នៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក៕

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៨ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*